ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Dec-2015, 11:45
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៦នាទី**

**សវនាការលើកទី៣៤០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍ *(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង) *(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ាង

លោក ហ្វីលីព រ៉ូជឺ *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន *(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវិន្ត

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

PURL: http://www.legal-tools.org/doc/431d2b/

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

PURL: http://www.legal-tools.org/doc/431d2b/

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក 2-TCW-918 | ខ្មែរ |

PURL: http://www.legal-tools.org/doc/431d2b/

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក 2-TCW-918**

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................................................ ទំព័រ ១២
សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ..................................................................... ទំព័រ ១៥

PURL: http://www.legal-tools.org/doc/431d2b/

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការលើសំណុំរឿង០០២/០២។ ដូចដែលអង្គជំនុំជម្រះបានជម្រាបជូនដំណឹងដល់ភាគីរួចហើយថា នៅថ្ងៃនេះ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីមួយរូបដែលមានរហស្សនាម 2-TCW-918 ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ការដ្ឋានទំនប់ត្រពាំងថ្ម។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពអំពីវត្តមាន អវត្តមានភាគី និងបុគ្គល ដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-918។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ សាក្សីមានមេធាវីប្រឹក្សាគឺលោក ម៉ម រិទ្ធា។ លោក និងមេធាវីប្រឹក្សាមានវត្តមានរួចហើយនៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា

ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភ័ស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៩:៣៦]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាព សុខភាពរបស់ជនជាប់ចោទ នួន ជា នៅថ្ងៃនេះមានអាការៈឈឺចង្កេះខ្លាំងពេលអង្គុយយូរ និងបានផ្តល់នូវអនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីសាលខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលហេតុនេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ដោយសារបញ្ហានៃកិច្ចដំណើរការសវនាការទៅតទៅមុខទៀតនេះ មានការពាក់ព័ន្ធទៅនឹងកិច្ចដំណើរការការងារស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ដែលជាដំណើរការសវនាការជាសម្ងាត់ ហើយក៏អង្គជំនុំជម្រះបានទទួលនូវឯកសារចំនួនមួយចំនួន ជាពិសេស គឺឯកសារដែលមានអត្តសញ្ញាណលេខ E319/35 និង E319/35/2 ហើយបើប្រៀបធៀបទៅនឹងខ្លឹមសារនៃឯកសារ ដែល

PURL: http://www.legal-tools.org/doc/431d2b/

អង្គជំនុំជម្រះសាលាដំបូងបានចេញ ឯកសារ E319/7 និង E319/7/3 ឃើញថាវាមានបញ្ហាដែលមាន ការប្រែប្រួល ហើយមុននឹងស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីតទៅមុខទៀតនេះ អង្គជំនុំជម្រះមានបំណងស្តាប់នូវមតិយោបល់របស់ភាគី ដោយស្តាប់បន្ថែមទៀត។ អង្គជំនុំជម្រះបានទទួលនូវសំណើសុំរបស់ការិយាល័យសហព្រះរាជអាជ្ញា ហើយនិងមេធាវីការពារក្តីលោក ខៀវ សំផន លើបញ្ហានេះហើយ ប៉ុន្តែក៏វាមានបញ្ហាថ្មីបន្ថែមបញ្ជាក់បន្ថែមទៀតពីការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើបញ្ហានេះដដែល។ ដើម្បីបានច្បាស់លាស់ និងមានមូលដ្ឋានក្នុងការគ្រប់គ្រងកិច្ចដំណើរការសវនាការប្រព្រឹត្តទៅបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ហើយនិងច្បាស់លាស់ ចៀសវាងនូវកំហុសផ្សេងៗដែលកើតមានឡើងដូចកាលដែលអនុវត្ត យើងមានការខុសឆ្គងបន្តិចបន្តួចក្នុងការអនុវត្តកន្លងមកនេះ ពាក់ព័ន្ធនឹងការងារសម្ងាត់នៃការងារស៊ើបអង្កេត អង្គជំនុំជម្រះចង់ស្តាប់ភាគីលើបញ្ហានេះជាមុនសិន ដើម្បីអង្គជំនុំជម្រះមានមូលដ្ឋានសម្រេចបញ្ហានេះ ឲ្យបានសមស្របជាមុន ហើយមុននឹងស្តាប់សក្ខីកម្មសាក្សីដែលបានកំណត់ស្តាប់សក្ខីកម្មនៅថ្ងៃនេះ គឺ 2-TCW-918។ ហើយជាដំបូងនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅការិយាល័យសហព្រះរាជអាជ្ញាមុនគេ។ សូមអញ្ជើញ បាទ!

[០៩:១២:៥២]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនទាន់ទទួលបានសេចក្តីសម្រេចជាក់លាក់មកពីការិយាល័យសហចៅក្រមស៊ើបអង្កេត -- ការិយាល័យសហចៅក្រមនៅឡើយទេ ប៉ុន្តែខ្ញុំសូមធ្វើការលើកឡើងនូវមតិជាទូទៅ។ ជាដំបូង គោលជំហររបស់យើង គឺថាគោលជំហររបស់យើង គឺនៅដដែល ដូចពីលើកមុន។ យើងជឿជាក់ថា កិច្ចដំណើរការនីតិវិធីដែលកំពុងតែអនុវត្ត គឺគ្រប់គ្រាន់ ហើយនិងនៅតែគ្រប់គ្រាន់ក្នុងការធានាពីភាពសម្ងាត់នៃការស៊ើបអង្កេត។ ដូច្នេះហើយគឺមិនមានអ្វីដែលយើងអាចធ្វើបានទេ គឺថាយើងមិនអាចធានាឲ្យបានមួយរយភាគរយ ដោយធានាថាគ្មានកំហុសឆ្គង សូម្បីតែបន្តិចបន្តួចនោះក៏ដោយ។ ប៉ុន្តែយ៉ាងណាក្តី យើងមិនទាន់ឃើញថាមានការខូចខាត ឬក៏មានព្យសនកម្មណាមួយដែលបណ្តាលមកពីកិច្ចដំណើរការនីតិវិធីនោះឡើយ។ ដូច្នេះអ្វីដែលខ្ញុំចង់បញ្ជាក់ឡើងវិញដដែលៗទៀត គឺថាវាជាកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលសាលាដំបូងត្រូវសម្រេច ថាតើមានការសម្របសម្រួលអ្វីចំពោះការធ្វើសវនាការជាសាធារណៈ គឺថាយើងផ្អែកទៅតាមករណីជាក់ស្តែង សាក្សីម្នាក់ៗ។ ដូច្នេះអង្គជំនុំជម្រះ អាចធ្វើការសម្រេចទៅតាមករណីជាក់ស្តែងនីមួយៗ។ ហើយខ្ញុំគិតថា អង្គជំនុំជម្រះនេះ

PURL: http://www.legal-tools.org/doc/431d2b/

មិនអាចធ្វើប្រតិភូកម្មទៅឲ្យចៅក្រមដទៃទៀតឡើយ គឺជាសិទ្ធិ និងកាតព្វកិច្ចរបស់អង្គជំនុំជម្រះ ដែលត្រូវសម្រេចទៅលើសវនាការ ថាតើសាធារណៈ ឬក៏អត់។

ដូច្នេះខ្ញុំគិតថា អង្គជំនុំជម្រះអាចពិចារណាទៅតាមករណីមួយៗ។ វាជាការពិតហើយថា ចៅក្រមស៊ើបគាត់ចង់ឲ្យមានការធានាអំពីភាពសម្ងាត់ ហើយយើងក៏ព្យាយាមធ្វើការធានាដែរ ប៉ុន្តែយ៉ាងណាក៏ដោយ យើងមិនគួរសម្របសម្រួលរហូតដល់ធ្វើឲ្យប៉ះពាល់ដល់សាធារណជននោះឡើយ។

សូមអរគុណ។

[០៩:១៥:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញាអន្តរជាតិ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើមានមតិយោបល់អ្វីដែរទេ លើបញ្ហានេះ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំមិនមានការជំទាស់អ្វីទៅលើឯកសារ E319/35 ហើយនិងប្រភេទផ្សេងៗនៃដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលត្រូវបានស្នើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិអ្វីនោះទេ។ អ៊ីចឹងអ្វីៗគឺសម្រេចទៅលើតុលាការពាក់ព័ន្ធនឹងចំណុចទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណហើយជាបន្តទៅទៀត អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា តើមានមតិយោបល់អ្វីដែរទេ ពាក់ព័ន្ធនឹងបញ្ហានេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម យើងក៏មិនបានត្រៀមខ្លួនដើម្បីលើកជាសារណាណាមួយឲ្យជាក់លាក់ហ្នឹងឡើយ ប៉ុន្តែក្នុងពេលនេះយើងមិនមានមតិអ្វីត្រូវលើកឡើងនោះឡើយ ពាក់ព័ន្ធទៅនឹងអនុស្សរណៈមកពីសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែខ្ញុំចង់បញ្ជាក់បន្តិចថា ចំពោះអ្វីដែលព្រះរាជអាជ្ញាបានលើកឡើងនៅពេលអម្បាញ់មិញនេះ គឺទាក់ទងនឹងសិទ្ធិធ្វើសវនាការជាសាធារណៈរបស់ជនជាប់ចោទនោះ គឺថាក្នុងពេលឥឡូវនេះ ខ្ញុំមិនមានអ្វីជាមតិយោបល់បន្ថែមនៅឡើយទេ។

[០៩:១៦:៤២]

PURL: http://www.legal-tools.org/doc/431d2b/

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយជាចុងក្រោយអង្គជំនុំជម្រះប្រគល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដី លោក ខៀវ សំផន តើមានមតិយោបល់អ្វីបន្ថែមលើឯកសារដែលដាក់ជូនដល់អង្គជំនុំជម្រះរួចហើយ លើបញ្ហានេះ ដែរឬទេ? សូមអញ្ជើញបាទ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ យើងរក្សាជំហរដដែល ដូចដែលយើងបានលើកឡើងនៅក្នុងសារណារបស់យើងពាក់ព័ន្ធទៅនឹងប្រធានបទនេះ ហើយនិងពាក់ព័ន្ធនឹងភាពចាំបាច់នៃសវនាការជាសាធារណៈ។ ខ្ញុំបានអាននូវសេចក្ដីណែនាំរបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធទៅនឹងចំណុចនេះ ក៏ប៉ុន្តែខ្ញុំដូចជាមិនយល់ ថាយ៉ាងម៉េចទេ ខ្ញុំ បើតាមខ្ញុំគិតគឺថា ប្រហែលជាមានព័ត៌មានជាក់លាក់អាស្រ័យទៅតាមសាក្សីនីមួយៗ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ពាក់ព័ន្ធទៅនឹងសាក្សីដែលបានឆ្លើយជាសាធារណៈនោះដូចជាខ្ញុំមិនយល់ថា ហេតុអ្វីបានជាយើងមិនអាចធ្វើសវនាការជាសាធារណៈបាន។ ហើយចំពោះចម្លើយផ្សេងទៀតនោះ ខ្ញុំគិតថា យើងគួរតែគោរពទៅតាមការកំណត់ពីមុនទៅគឺគ្រប់គ្រាន់ណាស់ទៅហើយ។

[០៩:១៨:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវរាល់មតិយោបល់ដែលលើកឡើងដោយភាគី ពាក់ព័ន្ធនឹងបញ្ហានៃឯកសារសេចក្ដីណែនាំអនុវត្តចំពោះការស្ដាប់សក្ខីកម្មសាក្សី និងការប្រើប្រាស់ឯកសារពីសំណុំរឿង កំពុងតែស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ហើយនិងបញ្ហាដែលលើកឡើង និងផ្ដល់ជាមតិយោបល់ជាវិធានការដែលមានការប្រែប្រួលដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើបញ្ហានេះ។ ហើយដោយសារសាក្សី ដែលយើងនឹងស្ដាប់សក្ខីកម្មនេះ ក៏មានការពាក់ព័ន្ធនឹងបញ្ហានេះផងដែរ ហើយក៏មានបញ្ហាផ្សេងៗទៀត ដែលអាចមានការពាក់ព័ន្ធទៅនឹងការនីតិវិធីនៃការអនុវត្តរបស់យើងផងដែរ។ ដើម្បីបានច្បាស់លាស់ហ្នឹង អង្គជំនុំជម្រះអរគុណនូវមតិយោបល់ ហើយនិងសម្រេចថា ដកខ្លួនដើម្បីថយទៅពិចារណាសម្រេចលើបញ្ហានេះឲ្យបានច្បាស់លាស់ជាមុនសិន ដើម្បីបន្តនីតិវិធីទៅខាងមុខនេះ ឲ្យមានប្រសិទ្ធភាព និងត្រឹមត្រូវជាអតិបរមា។

ឥឡូវនេះអង្គជំនុំជម្រះប្រកាសសម្រាក២៥នាទី ដើម្បីថយទៅពិចារណាសម្រេចលើបញ្ហានេះ

PURL: http://www.legal-tools.org/doc/431d2b/

ហើយម៉ោងប្រាំបួន សែសិបនាទីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការរបស់យើង។

បាទ សម្រាកសិនចុះ!

*(សវនាការសម្រាកពីម៉ោង ០៩:១៩ នាទី ដល់ម៉ោង ១០:០០ នាទី)*

[១០:០០:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

តទៅនេះ អង្គជំនុំជម្រះសម្រេចផ្ទាល់មាត់លើសំណើសុំលុបចោលនូវសេចក្ដីបង្គាប់ E319/7/3 អង្គជំនុំជម្រះបានទទួលបាននូវសំណើរបស់មេធាវី ខៀវ សំផន ដែលបានទទួលការគាំទ្រពីសហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឲ្យលុបចោលសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះ ឯកសារ E319/7/3 សេចក្ដីបង្គាប់នោះ ១) តម្រូវថា ការផ្ដល់សក្ខីកម្មទាំងឡាយរបស់បុគ្គលណាដែលបានផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង០០៣ និង០០៤ ត្រូវធ្វើឡើងក្នុងសវនាការអសាធារណៈ។ និង២) តម្រូវថាការសួរសំណួរសាក្សីដោយផ្អែកលើចម្លើយនៃសំណុំរឿង០០៣ និង០០៤ក៏ត្រូវធ្វើឡើងក្នុងសវនាការអសាធារណៈដែរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពីដំបូងឡើយបានស្នើសុំឲ្យមានសេចក្ដីបង្គាប់នេះ ប៉ុន្តែពេលក្រោយមក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ថា ការកំណត់បែបនេះលែងមានភាពចាំបាច់ទៀតហើយ។ សហព្រះរាជអាជ្ញា និងសហមេធាវីការពារក្ដី ខៀវ សំផន បានបញ្ជាក់ដោយផ្ទាល់មាត់ថាខ្លួននៅតែរក្សានូវសេចក្ដីសន្និដ្ឋានរបស់ខ្លួនពីមុននៅដដែល រីឯភាគីដទៃទៀតមិនមានមតិយោបល់អ្វីឡើយ។

អនុលោមតាមវិធាន៣៤ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធាន ៧៩(៦) នៃវិធានផ្ទៃក្នុង ជនជាប់ចោទមានសិទ្ធិជាសារវន្តក្នុងការទទួលបានការជំនុំជម្រះដោយសាធារណៈ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ជាផលប្រយោជន៍យុត្តិធម៌ និងជាគោលការណ៍សុខដុមស្ថាប័នតុលាការត្រូវគោរពចំពោះលក្ខខណ្ឌនៃការរក្សាការសម្ងាត់ចំពោះការស៊ើបអង្កេត ដែលកំពុងដំណើរការនាពេលបច្ចុប្បន្ន។

ដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា មិនមានភាពចាំបាច់ទៀតឡើយក្នុងការស្ដាប់សក្ខីកម្មដែលបានពិភាក្សាខាងលើនេះនៅក្នុងសវនាការជាអសាធារណៈនោះ អង្គជំនុំជម្រះពិចារណាឡើងវិញ និងកែប្រែសេចក្ដីបង្គាប់របស់ខ្លួននៅក្នុងឯកសារ E319/7/3។ ការសម្រេចពីមុន

របស់អង្គជំនុំជម្រះនៅក្នុងឯកសារ E319/7 នៅតែចូលជាធរមាន និងមានសុពលភាពដោយត្រូវអនុលោមតាមសេចក្តីណែនាំបន្ថែមដូចខាងក្រោម៖

[១០:០៣:៥៣]

បន្ថែមទៅលើនីតិវិធីដែលបានកំណត់នៅក្នុងឯកសារ E319/7 សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានស្នើឱ្យអង្គជំនុំជម្រះតម្រូវឱ្យប្រើប្រាស់រហស្សនាមសម្រាប់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០៣, ០០៤ ដែលផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២។ សំណើនេះគ្រាន់តែជាវិធានការការពារបន្តិចបន្តួចប៉ុណ្ណោះ ហើយអនុញ្ញាតឱ្យអង្គជំនុំជម្រះបន្តសវនាការជាសាធារណៈ ហើយមិនបានដាក់កំហិតដោយមិនត្រឹមត្រូវនូវការសួរសំណួរសាក្សីឡើយ (មើលឯកសារ E319/2 កថាខណ្ឌ១១ និង១២)។ ដូច្នេះអង្គជំនុំជម្រះបង្គាប់ឱ្យប្រើប្រាស់រហស្សនាមសម្រាប់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានលើកឡើងផងដែរថា គាត់នឹងស្នើឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញធ្វើការវាយតម្លៃលើបុគ្គលដែលគាត់យល់ឃើញថាអាចតម្រូវឱ្យមានវិធានការការពារបន្ថែមដើម្បីធានាសុវត្ថិភាព និងសន្តិសុខរបស់គាត់។

អង្គជំនុំជម្រះកត់សម្គាល់ថា សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈត្រូវតែមានតុល្យភាពទៅនឹងសម្រួលការក្នុងការការពារអត្តសញ្ញាណរបស់សាក្សី និងជនរងគ្រោះ។ អនុលោមតាមវិធាន២៩នៃវិធានផ្ទៃក្នុង និងមាត្រា៤(១) នៃសេចក្តីណែនាំអនុវត្តស្តីពីវិធាការការពារ អង្គជំនុំជម្រះនឹងអនុវត្តរាល់វិធានការការពារទាំងអស់ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបង្គាប់ឱ្យមានសម្រាប់សាក្សីនៃសំណុំរឿង០០៣ និង០០៤។

[១០:០៥:៥១]

ចុងក្រោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្នើសុំឱ្យស្តាប់សក្ខីកម្មនៅក្នុងសវនាការអសាធារណៈចំពោះសាក្សីមួយក្រុមតូចដែលត្រូវបង្ហាញអត្តសញ្ញាណនៅពេលខាងមុខ និងស្នើឱ្យអង្គជំនុំជម្រះគោរពវិធានការដែលមិនបានបញ្ជាក់ជូនផ្សេងៗទៀតសម្រាប់បុគ្គលខាងលើនេះ។

អង្គជំនុំជំនុំជម្រះនឹងជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងភាគីទាំងអស់នៅក្នុងសំណុំរឿង០០២/០២ អំពីបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនានាដែលត្រូវបានជ្រើសរើសឱ្យមកផ្តល់សក្ខីកម្មទៅលើប្រធានបទនីមួយៗ។

អង្គជំនុំជម្រះមិនអាចវាយតម្លៃឲ្យបានពេញលេញលើសំណើចុងក្រោយនេះបានទេ បើសិនជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនទាន់បានបង្ហាញអត្តសញ្ញាណបុគ្គលណាខ្លះ ក្នុងចំណោមបុគ្គលទាំងនេះ ដែលគួរផ្តល់សក្ខីកម្មនៅក្នុងសវនាការជាអសាធារណៈនោះ។ នេះជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងឯកសារ E336 និង E336/1។

តទៅនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការជាសាធារណៈស្តាប់នូវសក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-918 ហើយមុននឹងកោះហៅសាក្សីចូលមកចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីរូបនេះត្រូវបានស្តាប់ចម្លើយនៅក្នុងកិច្ចដំណើរការស៊ើបអង្កេតដែលកំពុងបន្តដំណើរការ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានស្នើថា សាក្សីរូបនេះគួរមានរហស្សនាមដើម្បីការពារនូវភាពសម្ងាត់នៃកិច្ចស៊ើបអង្កេត។

[១០:០៧:០៨]

អង្គជំនុំជម្រះយល់ឃើញថា វិធានការការពារដែលមានកម្រិតនេះ គឺត្រឹមត្រូវតាមច្បាប់នៅក្នុងករណីបែបនេះ ហើយការបង្គាប់នេះគឺត្រូវធ្វើឲ្យមានតុល្យភាពរវាងតម្រូវការនៃសវនាការជាសាធារណៈជាមួយនឹងតម្រូវការក្នុងការការពារសុចរិតភាពនៃកិច្ចស៊ើបសួរ។ ភាគីត្រូវបានរំឭកឲ្យគោរពតាមការបង្គាប់នៅក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដែលដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤។

បាទ ជាបន្តទៅនេះបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី រួមទាំងមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មចំពោះអង្គជំនុំជម្រះ។

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ សូមសួរបញ្ជាក់តែមួយចំណុចទេ សម្រាប់សាក្សីនៅពេលខាងមុខទាក់ទងទៅនឹងប្រភេទ១ទី១ ដែលត្រូវបានកំណត់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហើយនិងការប្រើរហស្សនាម។ សំណួររបស់យើងខ្ញុំ គឺក្នុងករណីដែលសាក្សីនេះ ត្រូវបានវ៉េស្វ៊ស្នើសុំ តើអង្គជំនុំជម្រះបដិសេធមិនឲ្យប្រើប្រាស់ឈ្មោះជាសាធារណៈឬក៏យ៉ាងណា បើសិនណាជាខាងវ៉េស្វ៊ បញ្ជាក់ថាមិនមានការជំទាស់អ្វីក្នុងការប្រើប្រាស់ឈ្មោះរបស់សាក្សីជាសាធារណៈនោះទេ។ ដូច្នេះ យើងខ្ញុំសូមឲ្យអង្គជំនុំជម្រះបញ្ជាក់អំពីចំណុចនេះ ដោយសារថារហស្សនាមនេះ គឺវាមិនជាចាំបាច់ទេ ហើយសាក្សី

PURL: http://www.legal-tools.org/doc/431d2b/

ខ្លួនឯងផ្ទាល់ក៏អាចនឹងជម្រាបជូនអង្គជំនុំជម្រះមិនបញ្ហាអ្វីទេ ក្នុងការប្រើប្រាស់ឈ្មោះរបស់គាត់ជាសាធារណៈនោះ។ ដូច្នេះនេះខ្ញុំស្នើសុំពាក់ព័ន្ធទៅនឹងសិទ្ធិនៅក្នុងសវនាការជាសាធារណៈក៏ដូចជាសិទ្ធិរបស់ជនជាប់ចោទក្នុងការស្នើសុំបែបនេះដែរ។ ក្នុងវិធាន២៦(៦) គឺជនជាប់ចោទអាចស្នើសុំ -- សាក្សីអាចស្នើសុំឲ្យមានសវនាការអសាធារណៈ ដើម្បីការពារទៅដល់សន្តិសុខរបស់គាត់នៅក្នុងសវនាការជាសាធារណៈ ដូចជានៅក្នុងតុលាការសិទ្ធិមនុស្សអឺរ៉ុប នៅក្នុងករណី អ៊ិនអ័រ ប្រទេសអ៊ីតាលី នៅក្នុងឆ្នាំ១៩៨៤។ សូមអរគុណលោកប្រធាន។

[១០:១០:០៧]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញសហមេធាវីការពារក្តីលោក ខៀវ សំផន អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ បន្ទាប់ពីការស្នើសុំបំភ្លឺនោះ គឺថាខ្ញុំមិនដឹងថាតើខ្ញុំជាអ្នកស្តាប់ច្រឡំ ឬក៏យ៉ាងម៉េច។ អ៊ីចឹងមានន័យថា--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*(គ្មានការបកប្រែ)*

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមចាប់ផ្តើមម្តងទៀត។ ខ្ញុំមានការស្នើសុំបំភ្លឺទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ ខ្ញុំមិនដឹងថា ខ្ញុំស្តាប់ច្រឡំ ឬក៏យ៉ាងម៉េច។ អ៊ីចឹងមានន័យថា យើងឯកភាពគ្នាទេថា សាក្សីនៅក្នុងសំណុំរឿង០០២/០២ មុនពេលដែលចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយហ្នឹង គឺថាអត់មានប្រើរហស្សនាមទេ ពីព្រោះថា សាក្សីហ្នឹងគឺនៅក្នុងសំណុំរឿងហើយ។ អ៊ីចឹងមែន ឬក៏យ៉ាងម៉េច? ខ្ញុំស្តាប់អត់យល់ អំពីសេចក្តីសម្រេចមុននេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំស្តាប់អត់យល់ការបក ការនិយាយរបស់លោកស្រីទេ ដោយសារតែមិនមានការបកប្រែពេញលេញ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមនិយាយជាលើកទី៣ ការសុំបំភ្លឺរបស់ខ្ញុំហ្នឹង គឺពាក់ព័ន្ធនឹងសាក្សីដែលផ្តល់សក្ខីកម្មនៅក្នុង

សំណុំរឿង០០២/០២ ដែលមិនទាន់ត្រូវបានសហចៅក្រមស៊ើបអង្កេតសួរ។ ខ្ញុំចង់ដឹងថា តើរហស្សនាមមិនចាំបាច់ទេពេលហ្នឹង មែនទេ ពីព្រោះថាគាត់ជាសាក្សីនៅក្នុងសំណុំរឿង០០២/០២ រួចទៅហើយ ហើយគាត់មានកំណត់ហេតុ -- កំណត់ស្តាប់ចម្លើយរបស់គាត់ហ្នឹង គឺមិនមានរក្សាជាការសម្ងាត់ទេ ព្រោះថាគាត់ត្រូវបានបញ្ជូនមកចំពោះមុខអង្គជំនុំជម្រះហ្នឹង ជាសាក្សីនៅក្នុងសំណុំរឿង០០២/០២រួចទៅហើយ។ អ៊ីចឹងបានខ្ញុំចង់បានការបញ្ជាក់អំពីចំណុចនេះ។

[១០:១២:៤២]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១២:៤៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្ថែមទៅលើបញ្ហាដែលមេធាវីការពារក្តីក្រុម ខៀវ សំផន ទើបតែលើកឡើង។ អង្គជំនុំជម្រះបានសួរបញ្ហានេះទៅកាន់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅក្នុងអនុស្សរណៈមួយដែលអង្គជំនុំជម្រះបានផ្ញើទៅ ដែលខ្ញុំក៏មានដែរ ថាតើយើងប្រើរហស្សនាមសម្រាប់សំណុំរឿង០៣, ០៤ ទាំងអស់តែម្តង ឬក៏សម្រាប់តែសាក្សីជាក់លាក់ណាម្នាក់។ នៅក្នុងអនុស្សរណៈ គឺថាវា ការប្រើប្រាស់នេះ គឺសម្រាប់តែអ្នកណាម្នាក់ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតដឹងដោយខ្លួនឯង ប៉ុន្តែមិនមែនសម្រាប់ករណីផ្សេងទៀតនោះទេ។ ដូច្នេះស្ថានភាពនាពេលនេះ គឺថាខ្ញុំមិនទាន់បានស្តាប់ឮពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីជំហររបស់គាត់ ទៅលើសាក្សីជាក់លាក់មួយចំនួននេះទេ ដែលថានៅក្នុងកាលៈទេសៈនោះ គឺអង្គជំនុំជម្រះនឹងចាប់ផ្តើមប្រើកិច្ចដំណើរការនីតិវិធីដោយប្រើប្រាស់រហស្សនាម។ ក៏ប៉ុន្តែយើងខ្ញុំស្នើសុំឱ្យមន្ត្រីរបស់យើងខ្ញុំ ក៏ដូចជាក្រឡាបញ្ជីរបស់សាលាដំបូង ដើម្បីទំនាក់ទំនងជាមួយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមើល តើអំពីបញ្ហានេះ។ ហើយតាមរយៈមជ្ឈ-មណ្ឌលឯកសារកម្ពុជា ក៏ដូចជាយើងផងដែរ គឺយើងថាការសម្ភាសជាសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺគេៗដឹងហើយ។ ហេតុដូច្នេះឯង គេឮថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺថាគាត់មិនមានការព្រួយបារម្ភអ្វីចំពោះប្រើប្រាស់ឈ្មោះជាសាធារណៈនោះទេ។ មានតែខាងយើង ភាគីទាំងអស់គ្នានេះទេ។ ដូច្នេះ យើងខ្ញុំក៏សុំថាបន្ថែមចំណុចនេះទៅលើអ្វីដែលបានលើកឡើងដោយមេធាវី

PURL: http://www.legal-tools.org/doc/431d2b/

ការពារក្តីក្រុម ខៀវ សំផន ផងដែរ។

[១០:១៤:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៥:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមបញ្ជាក់ថា ការអនុវត្តគឺជារួម គឺអង្គជំនុំជម្រះផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេចដែលអង្គជំនុំជម្រះបានសម្រេចរួចហើយអម្បាញ់មិញនេះ។ ហើយបញ្ហាទី២ គឺចំពោះសាក្សីអម្បាញ់មិញនេះ គឺអង្គជំនុំជម្រះកំណត់យកជាមូលដ្ឋានមួយ ដើម្បីធានាសុវត្ថិភាពរវាងកិច្ចដំណើរការសវនាការជាសាធារណៈ ហើយនិងដំណើរការនៃការស៊ើបអង្កេត ការងារការសម្ងាត់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបានស្នើ យើងកំណត់រួចហើយ ថាសាក្សីរូបនេះ ត្រូវធ្វើសវនាការជាសាធារណៈ តែឲ្យប្រើប្រាស់នូវរហស្សនាម ដោយមិនអាចឲ្យប្រើឈ្មោះរបស់គាត់នោះទេ។ ហើយបញ្ហាមួយទៀត គឺបញ្ហាជាក់ស្តែងដែលនឹងមានកើតឡើងនាពេលខាងមុខ អង្គជំនុំជម្រះនឹងពិនិត្យ និងដោះស្រាយទៅតាមករណីជាស្តែងនីមួយៗ ដូចដែលសហាមេធាវី អ៎ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់ដល់អង្គជំនុំជម្រះឲ្យរៀបចំតាមរបៀបនេះ ហើយតាមការប្រមើលមើលរបស់អង្គជំនុំជម្រះថា ទៅថ្ងៃខាងមុខ ស្ថានភាពដែលថាសាក្សីនឹងប្រឈមចំពោះការធ្វើសវនាការជាអសាធារណៈនោះស្ទើរតែមិនមាន ឬបើសិនជាមាន ក៏តិចតួចបំផុត ហើយតែមានផ្នែកណាមួយនោះប៉ុណ្ណោះ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបន្ធូរបន្ថយនូវលក្ខខណ្ឌតឹងរ៉ឹងដែលសហព្រះរាជអាជ្ញា -- អ៎! សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរឹតបន្តឹងកាលពីដំបូង។ ហើយមកចុងក្រោយបញ្ចប់នេះ ឃើញការមានការប្រៀបធៀបទៅ គឺថាវិធានការដែលស្នើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានការបន្ធូរបន្ថយមែនទែន ប៉ុន្តែបន្ធូរបន្ថយក្នុងដែនកំណត់មួយ មិនថាឲ្យធ្វើសាធារណៈទាំងអស់ ដោយប្រលែងមិនតាមដាន ពិនិត្យលើស្ថានភាពនៃដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង០០២/០២ ដោយមិនគិតគូរអំពីផលប៉ះពាល់នៃកិច្ចដំណើរការសាធារណៈនេះ ទៅលើកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង០០៣, ០០៤ នោះឡើយ។

[១០:១៨:៣៩]

ដំបូងនេះ យើងសួរអំពីអត្តសញ្ញាណនូវសាក្សីដែលមានរហស្សនាម 2-TCW-918 ដោយសារ

PURL: http://www.legal-tools.org/doc/431d2b/

មានការការពារនូវអត្តសញ្ញាណ ហើយនិងប្រើរហស្សនាមនោះ ឥឡូវនេះ អង្គជំនុំជម្រះសូមឲ្យសាក្សីដែលមានរហស្សនាម 2-TCW-918 ដែលនៅចំពោះមុខអង្គជំនុំជម្រះនេះ ពិនិត្យមើលលើអត្តសញ្ញាណរបស់ខ្លួន ដែលបង្ហាញនៅក្នុងឯកសារ E319/19.3.17 ទំព័រទី២គឺលេខ ERN 01003840។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ៉ង យកឯកសារនេះទៅជូនសាក្សីពិនិត្យ ហើយពិនិត្យហើយមិនបាច់បញ្ជាក់ទេ គ្រាន់តែឆ្លើយតបថា ត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ ត្រង់ចំណុចណាដែលមិនត្រឹមត្រូវ គ្រាន់តែបញ្ជាក់ថាមិនត្រឹមត្រូវ។ បើត្រឹមត្រូវទាំងអស់ បញ្ជាក់ថាត្រឹមត្រូវទាំងអស់។ ហើយមេធាវីអាចជួយសម្រួលការងារនេះដល់សាក្សីផង។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** យ៉ាងម៉េចទៅសាក្សី ពិនិត្យមើលចំណុចដែលមានហាយឡាយហ្នឹង តើត្រឹមត្រូវដែរឬទេ ឬក៏វាមិនត្រឹមត្រូវទេ វាខុសកន្លែងណា?

**លោក 2-TCW-918៖**

**ឆ៖** ជម្រាបសួរលោកប្រធាន ហើយសូមគោរពលោកប្រធានជាទីគោរព។ សំណួរនេះ គឺពិតជាត្រឹមត្រូវហើយ។

**ស៖** បាទ អរគុណ។ ហើយក្រឡាបញ្ជីសវនាការ ដកនូវឯកសារអម្បាញ់មិញនេះ ហើយដាក់ចូលទៅក្នុងសំណុំរឿង។ លោកសាក្សី តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលទាំងឡាយដែលទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះទេ។ តើត្រឹមត្រូវដែរឬទេ?

[១០:២១:៥៩]

**ឆ៖** បាទ សំណួរនេះគឺត្រឹមត្រូវហើយ ព្រោះខ្ញុំគ្មានជាប់ពាក់ព័ន្ធអីទេ។

**ស៖** ហើយមុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែកនៅខាងកើតសាលសវនាការនេះរួចហើយឬនៅ?

**ឆ៖** បាទ បានធ្វើពាក្យសម្បថសច្ចា គឺរួចស្រេចហើយ។

**ស៖** តទៅនេះ យើងប្រាប់អំពីសិទ្ធិ និង ករណីយកិច្ចចំពោះលោក ក្នុងឋានៈលោកជាសាក្សីនៅ

PURL: http://www.legal-tools.org/doc/431d2b/

ចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិលោកសាក្សីនៅក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏សូមឲ្យលោកធ្វើអត្ថាធិប្បាយណាមួយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬសេចក្ដីអត្ថាធិប្បាយរបស់លោកនោះ នាំឲ្យលោកនឹងត្រូវប្រឈមនឹងការចោទ -- ទទួលរងការប្រកាន់។

[១០:២៣:០៣]

អំពីករណីយកិច្ច លោកសាក្សីក្នុងឋានៈលោកជាសាក្សីនៅ ដែលត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយតបរបស់លោកនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈលោកជាសាក្សីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញបានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោកសាក្សី តើលោកធ្លាប់ផ្ដល់សក្ខីកម្ម ឬផ្ដល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ហើយប្រសិនធ្វើ ធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា?

**ឆ៖** បានធ្វើនៅស្រុកព្រះនេត្រព្រះ ហើយក៏នឹងផ្ទះខ្ញុំផ្ទាល់ ពីរ ឬបីដង ខ្ញុំភ្លេចដែរ វាមិនចាំទាំងអស់ ភ្លេច។ ច្រើនសាដែរ។

**ស៖** បាទ អរគុណ។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកសាក្សីបានពិនិត្យមើល បានអាននូវកំណត់ហេតុដែលលោកផ្ដល់ចម្លើយកាលពីពេលមុន លោកថា ពីរ ឬបីដង នៅនឹងផ្ទះរបស់លោក នៅស្រុកព្រះនេត្រព្រះនេះ ដើម្បីរំឭកការចងចាំដែរឬទេ?

[១០:២៤:៥៣]

**ឆ៖** បាទ ក្នុងនោះ ក្នុងការចងចាំរបស់ខ្ញុំ វាជួនកាលមានភាំងខ្លះ ជួនកាលចាំមិនបាន ព្រោះខ្ញុំសុខភាពអត់ស្រួលសព្វថ្ងៃនេះ។

**ស៖** យើងចង់ដឹងអ៊ីចេះទេ ថាតើមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោក

PURL: http://www.legal-tools.org/doc/431d2b/

បានអាន ឬក៏ស្តាប់ការអានន្ទូវសក្ខីកម្មដែលលោកបានផ្តល់ទៅឲ្យអ្នកស៊ើបអង្កេតនៅនឹងផ្ទះរបស់លោក នៅស្រុកព្រះនេត្រព្រះ ពីរ ឬបីដងកន្លងមកនេះ ដើម្បីរំឭកការចងចាំ។ សួរថាតើលោកបានអាន ហើយ ឬក៏ស្តាប់ការអានន្ទូវព័ត៌មានដែលលោកបានផ្តល់សក្ខីកម្មពីមុននោះដែរឬទេ?

**ឆ៖** បាទ នោះបានអានពីម្សិលមិញ ហើយក៏មានប្អូនម្នាក់អានឲ្យស្តាប់ដែរ។ បាទ ខ្ញុំក៏មានការចងចាំច្រើន។

**ស៖** បាទ អរគុណ។ ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុដែលស្តាប់ចម្លើយដែលលោកបានអាន និងស្តាប់ការអានដើម្បីរំឭកការចងចាំហ្នឹង ពិតជាត្រឹមត្រូវ ស៊ីសង្វាក់ស្របគ្នាទៅនឹងចម្លើយ ដែលលោកផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននៅនឹងផ្ទះរបស់លោកនោះដែរឬទេ?

**ឆ៖** បាទ ក្នុងនោះវាបានស្របៗគ្នាមួយចំនួន តែខ្លះដូចជាមិនពិតដែរ។

[១០:២៦:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោកសាក្សី នាពេលនេះលោកបានទទួលជំនួយមេធាវីប្រឹក្សាសាក្សីដែលអង្គជំនុំជម្រះបានផ្តល់ឲ្យតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញតាមសំណើរបស់លោក គឺលោកមេធាវីប្រឹក្សា លោកមេធាវី ម៉ម រិទ្ធា។

ក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមអញ្ជើញ!

សូមបញ្ជាក់ថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខហ្នឹងមានរយៈពេលមួយថ្ងៃក្នុងការសួរសាក្សីរូបនេះបាទ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

អរុណសួស្តីលោកសាក្សី! ខ្ញុំឈ្មោះ ឌេល លីសាក់ ខ្ញុំនឹងសួរសំណួរខ្លះៗទៅកាន់រូបលោកនូវក្នុង

PURL: http://www.legal-tools.org/doc/431d2b/

ព្រឹកនេះ។ ខ្ញុំសូមចាប់ផ្ដើមសួរអំពីជីវប្រវត្តិ ប្រវត្តិរូបរបស់លោក តួនាទីរបស់លោក ប្រវត្តិការងាររបស់លោកទាំងពីមុន ក៏ដូចជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយខ្ញុំក៏នឹងសួរសំណួរខ្លះៗអំពីការដ្ឋានទំនប់ត្រពាំងថ្ម ប៉ុន្តែដំបូងនេះ ខ្ញុំសូមសួរលោកអំពីបទពិសោធន៍របស់លោកធ្វើការនៅការដ្ឋាននានាមុនការដ្ឋានទំនប់ត្រពាំងថ្ម។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ តើមានឈ្មោះទំនប់ប៉ុន្មានដែរ ដែលលោកធ្លាប់ទៅលើកទំនប់ទាំងនោះ រាប់តាំងពីឆ្នាំ១៩៧៤, ៧៥, ៧៦ គឺអំឡុងពេលមុនដែលលោកទៅធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម?

[១០:២៨:៥៨]

**លោក 2-TCW-918៖**

**ឆ៖** ខ្ញុំលើកទី១ គឺបានចាប់ផ្ដើមលើកទំនប់នៅភ្នំកំបោរ ចាប់ពីកំបោរមកទល់ស្រែះ បណ្ដោយចំនួន១៣គីឡូម៉ែត្រ ហើយក្នុងនោះក៏បានរៀបចំដំណើរការជំហានទី១។ ដល់ជំហានទី២ ចាប់ដំណើរការទំនប់គោករំចេក ចេញទៅទល់ស្នាច់ចារ-គោកទៀម ខាងកើត។ ខាងលិចទល់ឃុំទានកាំ ជាព្រំដែនស្រុកព្រះនេត្រព្រះហើយនិងស្រុកភ្នំស្រុក។ ក្រោយមកដំណាក់កាលទី៣ ក៏បានដកកម្លាំងទៅរៀបចំជួយដាំកប្បាសតាមការដ្ឋានតំបន់៥។ ដំណាក់កាលទី៤ ក៏ខាងលើពិភាក្សាឲ្យខ្ញុំទៅវាស់ធ្វើផ្លូវចាប់ពីសំរោង-កាណាំង ទៅទល់ដូនណូយ ព្រំប្រទល់ខាងលិចជាប់ស្រុកថៃ ប៉ុនមិនជាប់ទេ វាមានចន្លោះឆ្ងាយដែរ។ ក្រោយមក ក៏រៀបចំនៅអាងត្រពាំងថ្ម ទីបញ្ចប់ក្រោយគេ។

**ស៖** សូមអរគុណលោក ខ្ញុំនឹងត្រឡប់មកសួរលោកអំពីការដ្ឋានពីរ មុនការដ្ឋានទំនប់ត្រពាំងថ្ម គឺការដ្ឋានកំបោរ និងគោករំចេក។ ខ្ញុំក៏ចង់សួរលោកផងដែរថា ថាលោកធ្លាប់បានធ្វើការនៅការដ្ឋានមួយនៅក្នុងឆ្នាំ១៩៧៤ ការដ្ឋានឈ្មោះថា "តាគាវ" គឺដែលស្ថិតនៅក្នុងស្រុកមង្គលបុរី។ តើលោកធ្លាប់បានធ្វើការនៅការដ្ឋានមួយដែលខ្ញុំនិយាយឈ្មោះអម្បាញ់មិញនេះទេ?

**ឆ៖** បាទ កន្លែងហ្នឹងធ្វើពីឆ្នាំ៧៤ ធ្វើតូចទេ មិនមែនធំ គ្រាន់តែបិទដៃអូរ ដើម្បីយកទឹកសម្រាប់ដោះស្រាយតែប៉ុណ្ណោះ។

**ស៖** ហើយថាតើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាខ្មែរក្រហមនេះ ប្រមូលកម្លាំងពលកម្មមកពីណា ដើម្បីមកជួយលើកទំនប់នុ៎ង?

[១០:៣២:៣៣]

**ឆ៖** លើកទំនប់កំបោរនុ៎ង? លើកទំនប់កំបោរ គឺប្រមូលកម្លាំងតាមស្រុក តាមឃុំ យុវជន និង យុវនារី ហើយក៏កម្លាំងចេញទៅពីភ្នំពេញមួយចំនួនដែលជម្លៀសចេញពីភ្នំពេញទៅ នៅតាមភូមិ តាមសហករណ៍ គឺប្រមូលទៅជាកម្លាំងចល័តតំបន់។

**ស៖** ប្រហែលជាមានការយល់ច្រឡំគ្នាហើយ។ ខ្ញុំអត់សួរអំពីការដ្ឋានទំនប់កំបោរទេ គឺសួរអំពីការដ្ឋានទំនប់តាគារ ដែលលោកធ្លាប់បានទៅលើកវាហ្នឹង នៅក្នុងឆ្នាំ១៩៧៤។ តើលោកអាចជម្រាបជូនតុលាការបានទេថា ខ្មែរក្រហមនោះ ប្រមូលកម្លាំងពលកម្មទាំងអស់នោះមកពីណា ដើម្បីទៅលើកទំនប់តាគារនេះ?

**ឆ៖** បាទ អានោះ គឺកម្លាំងដែលរស់នៅក្នុងព្រៃនេះឯង ព្រោះកម្លាំងចាស់ទុំដូចថា ក្មេង វ័យកណ្តាលអី ដូចថាជាសមរភូមិក្រោយ សមរភូមិក្រោយក៏ជួយលើក មិនមែនជាកម្លាំងច្រើនទេ ព្រោះកម្លាំងដែលយើងរំដោះបាន។

**ស៖** តើប្រជាជនដែលគេចាប់ខ្លួន តើមានប្រជាជនត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅឲ្យលើកទំនប់នោះផងដែរទេ?

[១០:៣៤:៣០]

**ឆ៖** បាទ មានប្រជាជនមួយចំនួនដែលទៅបង់ត្រី ដែលរស់នៅជាមួយរបប លន់ នល់។ បានទៅបង់ត្រីទៅ ក៏ពួកក្រុមខ្មែរក្រហមកៀរទៅ ដើម្បីជួយលើកទំនប់បានប្រហែលជាបួនប្រាំថ្ងៃ ក៏នាំគ្នារត់ចេញអស់។

**ស៖** លោកចាំទេ ថាគេចាប់ខ្លួនប្រជាជនហ្នឹងបានប៉ុន្មាននាក់ដែរ ប្រជាជនដែលគេចាប់ខ្លួន ហើយបញ្ជូនទៅជួយលើកទំនប់តាគារហ្នឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដោយសារវាមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងដែលយើងត្រូវយកមកស៊ើបអង្កេតជេញដោលនៅពេលនេះទេ ហើយម្យ៉ាងទៀតទាំងពេលក៏ខុសគ្នា ទីតាំងក៏ខុសគ្នាទៀត ដែលកើតឡើងតាមសាក្សីបញ្ជាក់អម្បាញ់មិញថា ឆ្នាំ

PURL: http://www.legal-tools.org/doc/431d2b/

១៩៧៤។ ដូច្នេះមិនស្ថិតនៅក្នុងវិសាលភាពនៃពេលវេលាដែល អង្គតុលាការយើងនេះមានសមត្ថកិច្ចនោះទេ។ បាទ សូមអរគុណ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ សំណួរនេះ គឺវាៗពាក់ព័ន្ធទៅលើខាងគោលនយោបាយ ហើយនិងការអនុវត្តរបស់ខ្មែរក្រហម។ គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងការកំណត់អំពី ដាក់ទិសដៅលើកទំនប់នេះ។ អ៊ីចឹងឯងបានវាពាក់ព័ន្ធទៅនឹងការចាប់ខ្លួនប្រជាជន និងបញ្ជូនទៅលើកការដ្ឋាននោះ។ វាពាក់ព័ន្ធទៅនឹងទាសភាពនៃការប្រមូលកម្លាំងទៅឲ្យលើកទំនប់ទាំងអស់នោះ អ៊ីចឹងយើងខ្ញុំមិនចង់ចំណាយពេលច្រើនទៅលើចំណុចនេះទេ គ្រាន់តែចង់ឲ្យសាក្សីបញ្ជាក់ អំពីវិសាលភាពទំហំនៃការចាប់ខ្លួនមនុស្សដើម្បីបញ្ជូនកម្លាំងពលកម្មទៅឲ្យលើកទំនប់តែប៉ុណ្ណោះ។ សូមអរគុណ។

[១០:៣៧:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៧:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក ខៀវ សំផន ដោយសារអង្គជំនុំជម្រះក៏គិតពិចារណាលើបញ្ហាថា ក្រៅវិសាលភាពនៃអង្គហេតុចោទប្រកាន់ដែរ ទាំងពេលវេលាទាំងទីកន្លែង ក៏ប៉ុន្តែសំណួរនេះ វាពាក់ព័ន្ធជាមួយនឹងការអនុវត្តគោលនយោបាយ ហើយចំពោះបញ្ហានេះ នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយទោះបីជាយ៉ាងណាក៏ដោយគឺសូមសហព្រះរាជអាជ្ញារងអន្តរជាតិ ក្នុងការតាំងសំណួរពាក់ព័ន្ធនឹងបញ្ហាបរិបទនេះ សូមកម្រិតជាមូលដ្ឋានគោលៗ បានហើយ ជៀសវាងការសួរលម្អិត ពីព្រោះវាមានឆ្ងាយពីអង្គហេតុដែលចោទប្រកាន់ដោយផ្ទាល់ ដែលអង្គជំនុំជម្រះមានបំណងចង់ស្ដាប់ផ្ទាល់លើបញ្ហាទំនប់ត្រពាំងថ្ម ជាជាងបញ្ហាដទៃទៀត។

សាក្សីឆ្លើយតបនឹងសំណួរអម្បាញ់មិញនេះ ប្រសិនបើលោកនៅចងចាំ បើមិនចាំទេ សហព្រះ-រាជអាជ្ញារងអន្តរជាតិ តាំងសំណួរថ្មីអម្បាញ់មិញនេះ សាជាថ្មីម្ដងទៀត។

**លោក 2-TCW-918៖**

**ឆ៖** ស្ដាប់អត់បាន។

**លោក ខេល លីសាក់៖**

លោកប្រធានអនុញ្ញាតឲ្យខ្ញុំ សាក្សីផ្តោតទៅលើចម្លើយដែលគាត់បានផ្តល់ជាក់លាក់ឲ្យបានញាប់បន្តិច។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ ដែលលោកបានឆ្លើយជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាឯកសារ E3/9094ៗ ERN ជាភាសាខ្មែរ 00734039 ដល់ 040, អង់គ្លេស 00728647 ដល់ 648, បារាំង 00123611 ដល់ 12។ លោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាដូចតទៅ ហើយនេះទាក់ទងការដ្ឋានទំនប់តាគារ។ "នៅពេលដែលគេលើកទំនប់ហ្នឹងអស់មួយរយៈនោះ អ្នកដែលមកពីព្រៃនោះគឺថាត្រូវបានគេចាប់ខ្លួន។ នៅពេលពួកគេត្រូវបានចាប់ខ្លួននោះ តើគេនាំអ្នកទាំងនោះទៅទីណា? ឆ្លើយ៖ គេយកអ្នកទាំងនោះទៅឲ្យជួយលើកទំនប់។" ហើយនៅទំព័រខាងក្រោម សូមដកស្រង់៖ "នៅពេលដែលគេចាប់ប្រជាជនពីព្រះនិព្វាន -- ពីព្រៃព្រះនិព្វានច្រើនមកៗ គេក៏យកមកឲ្យជួយលើកទំនប់នោះ។" បញ្ចប់ការដកស្រង់។ តើកន្លែងដែលខ្ញុំអាននេះ ជួយរំឭកដល់ការចងចាំរបស់លោក លោកនឹកឃើញអំពីចំនួនប្រជាជនដែលគេចាប់មកពីព្រៃមួយនោះ ហើយបញ្ជូនមកឲ្យជួយលើកទំនប់ហ្នឹង វាជួយរំឭកដល់ការចងចាំរបស់លោកទេ?

[១០:៤១:៣០]

**ឆ៖** ខ្ញុំចាំអត់បានទេ ព្រោះមិនដឹងចំនួនមនុស្សប៉ុន្មាន។

**ស៖** ឥឡូវសូមឲ្យខ្ញុំបន្តទៅកាន់តួនាទីរបស់លោកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កិច្ចសម្ភាសន៍ឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកឆ្លើយថា ដំបូងឡើយៗគឺលោកទទួលខុសត្រូវក្នុងការចាត់តាំងយុវជនឲ្យធ្វើការងារពីខែកក្កដា ដល់ខែកញ្ញា ១៩៧៦។ នៅពេលនោះ លោកក៏ត្រូវបានចាត់តាំងឲ្យធ្វើអនុប្រធានតំបន់ -- កងចល័តតំបន់៥។ សំណួររបស់ខ្ញុំសួរថា អ្នកណាជាអ្នកចាត់តាំងលោកឲ្យធ្វើជាអនុប្រធានកងចល័តយុវជនតំបន់៥?

**ឆ៖** ខ្ញុំមិនមានអ្នកណាចាត់តាំងឲ្យធ្វើអនុប្រធានទេ គ្រាន់តែគេឲ្យខ្ញុំធ្វើជា ហៅថាបញ្ញាការសមរភូមិ គឺសម្រាប់វាស់វែងដី ដើរមើលដី រៀបចំផែនការក្នុងចល័តតែប៉ុណ្ណោះទេ តែខ្ញុំជាអនុប្រធានគឺអត់មែនទេ ព្រោះខ្លាចលោខាងស្តាប់មិនយល់ ទៅថាខ្ញុំជាអនុប្រធាន ព្រោះវាអត់មែនជាអនុប្រធានទេ គ្រាន់តែការងារអីដែល តាវ៉ាល់ គាត់មិននៅ គាត់ផ្តាំផ្ញើឲ្យខ្ញុំជួយមើលតែប៉ុណ្ណោះ។

**ស៖** ឥឡូវនេះ ខ្ញុំសូមអានសម្រង់មួយចំនួនដែលលោកបានឆ្លើយដើម្បីរំឭកដល់ការចងចាំ។ នៅក្នុងចម្លើយមួយឆ្លើយជូនសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/9483 ត្រង់សំណួរចម្លើយលេខ១។ លោកបានឆ្លើយដូចតទៅ សូមដកស្រង់៖ "ខ្ញុំគឺជាប្រធានកងចល័តតំបន់ -- អនុប្រធានកងចល័តតំបន់៥ ហើយមានប្រធានតំបន់គឺឈ្មោះតាហុង -- តាហ៊ីង្សា"។ ហើយលោកក៏បានឆ្លើយដូចគ្នាដែរជូនមជ្ឈ-មណ្ឌលឯកសារកម្ពុជាគឺ E3/9094 ERN ជាភាសាខ្មែរ 00734049, អង់គ្លេស 00728654, បារាំង 01123618។ លោកបានឆ្លើយដូចតទៅ៖ "សួរ៖ នៅក្នុងខែមករា ១៩៧៦ លោកត្រូវបានជ្រើសតាំងឱ្យធ្វើជាអនុប្រធានកងចល័តតំបន់ នៅពេលនោះអ្នកណាជាអ្នកចាត់តាំងលោក? ឆ្លើយ៖ សហការីសមមិត្តរបស់ខ្ញុំ មិនមែនអ្នកណាទេ។ យើងត្រូវបានគេកោះហៅទៅឱ្យជួបជាមួយនឹងប្រធានតំបន់ ហើយយើងធ្វើការនៅសមរភូមិទាំងអស់គ្នាកាលនោះ។ គាត់បានឆ្លើយថា អាស្រ័យទៅលើៗលោកទេថាលោកអាចធ្វើការគ្រប់គ្រងបាន បើសិន តាវ៉ាល់ មិននៅទេ។ បើ តាវ៉ាល់ នៅទីនោះ តាវ៉ាល់ គឺជាអ្នកគ្រប់គ្រង ហើយបើ តាវ៉ាល់ មិននៅទេ ខ្ញុំគឺជាអ្នកគ្រប់គ្រង។" បញ្ចប់ការដកស្រង់។

តើចំណុចនេះវាជួយរំឭកដល់ការចងចាំរបស់លោកទេ ហើយវាត្រឹមត្រូវដែរទេ ដែលថាលេខាតំបន់ចាត់តាំងលោកឱ្យធ្វើជាអនុប្រធានកងចល័តនៅក្រោម តាវ៉ាល់ ហើយអនុញ្ញាតនោះឱ្យលោកធ្វើការគ្រប់គ្រងកម្លាំងទាំងអស់ហ្នឹង នៅពេលណាមិនមានវត្តមាន តាវ៉ាល់ ទេ។ ត្រឹមត្រូវដែរទេលោក?

[១០:៤៦:២១]

**ឆ៖** បាទ ពេលនោះគឺថាមិនមែនចាត់ខ្ញុំជាអនុប្រធានទេ គឺគ្រាន់តែការងារដែល តាវ៉ាល់ គាត់មិននៅ គាត់តែងផ្តាំផ្ញើទុកដាក់ឱ្យខ្ញុំជួសមុខ។ ការជួសមុខនោះ ក៏ខ្ញុំគ្មានតួនាទីទៅបញ្ជាលើកម្លាំងទេ ព្រោះកម្លាំងគេមានប្រធានកង ប្រធានក្រុមគេគ្រប់គ្នាទាំងអស់ហើយ គឺខ្ញុំគ្រាន់តែជួសមុខ មើលថែទាំឱ្យគេលើកដាក់យ៉ាងណាឱ្យត្រង់ ឱ្យអី កុំឱ្យវៀចតែប៉ុណ្ណោះទេក្នុងតួនាទីរបស់ខ្ញុំ ព្រោះគេហៅថាបញ្ជាការសមរភូមិ គឺត្រូវមើលគ្រប់កន្លែងដែលបងប្អូនលើកទំនប់។ គឺគ្រប់កន្លែងទាំងអស់ គឺមិនមែនដែលអនុប្រធានទេ។

**ស៖** លោកសាក្សី លោកអាចជម្រាបជូនតុលាការបានទេ អ៊ីចឹងនៅក្នុងកងចល័តតំបន់៥នេះ លោកគឺជា លោកមានតួនាទីអ្វីដែរ លោកជាមេវរៈ ឬក៏មេកងធំ ឬក៏ជាមេកងតូច?

**ឆ៖** ខ្ញុំគឺថា គេហៅថាមេបញ្ជាការសមរភូមិក្នុងអង្គភាពចល័តតំបន់ ហើយបញ្ជាការសមរភូមិនេះ គឺមានកម្លាំងខ្ញុំតែប្រាំមួយនាក់ទេ គឺតែប្រាំមួយនាក់គត់ អត់មានរាប់រយ ក្តោបក្តាប់ដោយខ្លួនឯង គឺ

PURL: http://www.legal-tools.org/doc/431d2b/

អត់មានទេ គឺកម្លាំងគេ ពលកម្ម កម្លាំងគេប្រយុទ្ធ កម្លាំងគេលើក អានោះគឺកម្លាំងគេមានប្រធានវរៈ ជាវរសេនាតូច វរសេនាធំ មានកងតូច កងធំ ចំពោះខ្ញុំគឺមានតែប្រាំមួយនាក់ប៉ុណ្ណោះឯង គ្រាន់ដើរមើលទៅតាមសមរភូមិដែលបងប្អូនលើក។

**ស៖** ក្នុងឆ្នាំ១៩៧៦ នៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់កំបោរ និងគោករំចេក ហើយនៅឆ្នាំ១៩៧៧ លោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម។ នៅពេលនុ៎ង តើលោកមានទំនាក់ទំនងអ្វីជាមួយ តាវ៉ាល់ ដែរទេ? ហើយតើលោកបានជួប តាវ៉ាល់ និងរាយការណ៍ជូន តាវ៉ាល់ ហ្នឹងញឹកញាប់ប៉ុនណាដែរ?

[១០:៤៩:១៥]

**ឆ៖** ព្រោះខ្ញុំពេលនោះ គឺចាប់ផ្ដើមរៀបអាងត្រពាំងថ្មនៅឆ្នាំ៧៧ គឺខ្ញុំល្ងាចឡើង គឺខ្ញុំបានរាយការណ៍ជូនគាត់ពីរឿងកម្លាំងពលកម្មក្នុងមួយវរៈបានប៉ុណ្ណោះម៉ែត្រ មួយវរៈបានប៉ុណ្ណោះម៉ែត្រ។ បាទ ខ្ញុំរាយការណ៍ជូនគាត់រាល់ល្ងាច។

**ស៖** នៅក្នុងឆ្នាំ១៩៧៦ លោកត្រូវរាយការណ៍ជូន តាវ៉ាល់ ដែរទេ នៅពេលលោកធ្វើការនៅការដ្ឋានទំនប់កំបោរ និងការដ្ឋានគោករំចេកនោះ?

**ឆ៖** នៅទំនប់កំបោរ ខ្ញុំមិនបានរាយការណ៍ជូនគាត់ទេ ព្រោះគាត់ចុះផ្ទាល់នឹងសមរភូមិនោះ។ ហើយបើនៅទំនប់គោករំចេក ដែលខ្ញុំ គាត់បញ្ជូនឲ្យខ្ញុំនៅជួសមុខ គឺខ្ញុំបានរៀបចំដំណើរការ តែមិនបានទៅរាយការណ៍ឲ្យគាត់ទេ។ ពេលណាដែលគាត់មក បញ្ជាក់ហេតុការណ៍នោះប្រាប់គាត់ នៅពេលដែលគាត់មក។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ចំណុចនេះ ឲ្យបានលម្អិតបន្តិចលោកសាក្សី។ ខ្ញុំកំពុងតែផ្ដោតទៅឆ្នាំ១៩៧៦ ពេលលោកធ្វើការនៅការដ្ឋានកំបោរ និង គោករំចេក។ នៅការដ្ឋានទំនប់ទាំងពីរហ្នឹង ក្នុងឆ្នាំ៧៦ហ្នឹង អ្នកណាជាមេរបស់លោក តាវ៉ាល់ ឬក៏ជាអ្នកណាមួយផ្សេង?

**ឆ៖** នៅក្នុងការដ្ឋានទាំងពីរនេះ ទំនប់គោករំចេក ហើយនិងទំនប់កំបោរនេះ គឺតាវ៉ាល់ ជាប្រធានខ្ញុំ។

**ស៖** ចុះ តាវ៉ាល់ មានតួនាទីជាអ្វីដែរ ក្នុងឆ្នាំ១៩៧៦ និង៧៧?

**ឆ៖** តាវ៉ាល់ គាត់ តួនាទីគាត់ជាប្រធានចល័តតំបន់៥។ គាត់គ្រប់គ្រងចល័តតំបន់៥។

[១០:៥២:០៦]

PURL: http://www.legal-tools.org/doc/431d2b/

**សះ** តើលោកគឺជាអនុប្រធានម្នាក់ក្នុងចំណោមអនុប្រធានដទៃទៀតរបស់ តាវ៉ាល់ នោះដែរឬទេ?

**ឆះ** ខ្ញុំមិនមែនអនុប្រធានទេ គឺខ្ញុំគ្រាន់តែដូចខ្ញុំបញ្ជាក់ប្រាប់លើកមុនអ៊ីចុះឯង គឺថាគ្រាន់ជាមេបញ្ជាការសមរភូមិនៅក្នុងចល័តតំបន់៥ តែប៉ុណ្ណោះទេ។

**សះ** ខ្ញុំសូមអានចម្លើយរបស់លោកឆ្លើយកាលពីមុនៗម្តងទៀត គឺឯកសារឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/9094 ERN ជាភាសាខ្មែរ 00734044, អង់គ្លេស 00728651, បារាំង 01123615។ "សំណួរ៖ តាវ៉ាល់ គឺជាប្រធាន តើមានអនុប្រធានប៉ុន្មាននាក់? ឆ្លើយ៖ មានតែខ្ញុំម្នាក់ឯងជាអនុប្រធាន។" លោកសាក្សី បើសិនណាជាលោកជាអនុរបស់ តាវ៉ាល់ ក្នុងឆ្នាំ៧៦-៧៧ បើលោកមិនមែនជាអនុរបស់ តាវ៉ាល់ ក្នុងឆ្នាំ៧៦-៧៧ ទេ តើអ្នកណាជាអនុរបស់ តាវ៉ាល់?

**ឆះ** បាទ ដូចក្នុងអង្គភាព តាវ៉ាល់ នោះគឺគ្មានអនុគាត់ទេ។ គឺគាត់មានតែគាត់ប្រធាន ហើយខ្ញុំគ្រាន់តែបញ្ជាការសមរភូមិ គ្រាន់តែជួសមុខគាត់ម្តងម្យាមទេ។ ត្រង់អនុគាត់អត់មាន តាំងពីខ្ញុំធ្វើទៅគឺឃើញគាត់តែម្នាក់ អត់មានអនុ អត់មានអីទេ។ មានតែប្រធាន តាវ៉ាល់ ហ្នឹងព្រោះ តាវ៉ាល់ គេថា តឹងក៏នៅវ៉ាល់ ធូរក៏វ៉ាល់។ តែគាត់ចង់តឹង គាត់រឹតឲ្យតឹងទៅ គាត់ចង់ធូរ គាត់បន្ធូរឲ្យធូរទៅ។ បានជាគាត់ដាក់ឈ្មោះ វ៉ាល់ ហ្នឹង។ មានតែគាត់ម្នាក់ឯងប៉ុណ្ណោះ។

[១០:៥៤:៣០]

**សះ** តើមានអ្នកណាម្នាក់ត្រូវជំនួស តាវ៉ាល់ ដែរឬទេនៅពេល តាវ៉ាល់ មិននៅ ឬក៏មានតែលោកទេ ដែលត្រូវជំនួសតួនាទីរបស់ តាវ៉ាល់ នេះពេល តាវ៉ាល់ មិននៅ?

**ឆះ** ពេលដែល តាវ៉ាល់ មិននៅ នៅការដ្ឋានទីមួយៗមានប្រធានវរៈគេ។ ប្រធានវរៈគេគ្រប់គ្រងក្នុងវរសេនាធំគេ គេគ្រប់គ្រងតាមវរសេនាធំគេ នេះពេលដែល តាវ៉ាល់ មិននៅ។ គ្រប់កន្លែងទាំងអ៊ីចុះឯង។

**សះ** លោកបាននិយាយខ្លួនឯងថា លោកគឺជាមេបញ្ជាការសមរភូមិ។ តើលោកអាចជម្រាបជូនតុលាការបានទេ ហេតុអ្វីបានជាគេយកពាក្យពេចន៍កងទ័ពនេះ យកទៅប្រើជាមួយនឹងគម្រោងលើកទំនប់នេះទៅវិញ?

**ឆះ** បាទ អានេះ ខ្ញុំក៏អត់ដឹងដែរ ព្រោះខ្ញុំមិនដែលបានធ្លាប់ធ្វើទ័ព ប៉ុន្តែពេលដែលគេរៀបចំទៅគេនិយាយទៅជាភាសានោះទៅវិញ ក៏នៅសម័យនោះ គឺយើងចេះតែតាមគេទៅ។ សូម្បីតែអ្នកធ្វើធំ

PURL: http://www.legal-tools.org/doc/431d2b/

ក្មេងអាយុ២១, ២២ ក៏យើងហៅគេ "តាៗ" ឲ្យតែអ្នកណាធំ គឺត្រូវហៅ "តា"។ ម្ល៉ោះហើយក្នុងការរៀបចំដំណើរលើកទំនប់អីចុះ គេហៅថា "សមរភូមិ" ដែរ។ គេវៃនៅសមរភូមិនេះ សមរភូមិនោះ ឲ្យមានមេបញ្ជាការរៀបចំនូវសមរភូមិ វរសេនាតូច វរសេនាធំ។ ឲ្យមានមេបញ្ជាការសមរភូមិវាស់វែងដីរុកមើលត្រង់ណាភក់ ត្រង់ណាជ្រៅ ត្រង់ណារាក់ ទឹកស្មើណា អីស្មើណានោះ គឺមានអីចុះឯង គេនិយាយទៅជាទ័ពទៅវិញ។ ហើយខ្ញុំក៏មិនដែលស្គាល់ទេ ប៉ុន្តែគេនិយាយទៅចុះ ចេះតែតាមគេទៅ។ ឲ្យតែអ្នកធំ ហៅតា តាៗទៅ ក្មេងយ៉ាងណាក៏តា។

[១០:៥៦:៥៤]

**ស៖** ខ្ញុំសូមអានចម្លើយដំបូងដែលឆ្លើយទៅនឹងសំណួររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/9094 ខ្មែរ 00734050, អង់គ្លេស 00728655, បារាំង 01123619 គឺជាសម្ដីរបស់លោក ឬក៏ជាការពន្យល់របស់លោក ក្នុងការឆ្លើយទៅនឹងសំណួរដែលពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ សូមដកស្រង់៖ "យើងទើបតែនិយាយអំពីការប្រើប្រាស់ពាក្យកងទ័ព។ ចុះបើយើងនិយាយអំពីកងទ័ពវិញ គឺយើងគ្រប់គ្រងកងចល័ត គឺក៏ដូចជាយើងក៏គ្រប់គ្រងកងទ័ពអីចឹងដែរ។ ក្នុងការប្រយុទ្ធនៅសមរភូមិកំបោរ គឺការលើកទំនប់ ជីកប្រឡាយ គេហៅថា សមរភូមិ។ យើងប្រយុទ្ធនៅសមរភូមិទី១ នៅទំនប់កំបោរ ប៉ុន្មានខែឲ្យដាច់ គឺថាយើងត្រូវប្ដេជ្ញា ហើយយើងត្រូវធ្វើក្នុងរយៈពេលប៉ុន្មានខែ ហើយយើងដឹកនាំកម្លាំងធ្វើឲ្យរួច ដូចដែលមានផែនការយ៉ាងដូច្នេះដែរ។ អ្នកឯងមិនអាចមិនបញ្ចប់បាននោះទេ"។ លោកសាក្សី តើលោក ហើយនិង តាវ៉ាល់ បានទទួលការណែនាំឲ្យគ្រប់គ្រងកងចល័តតំបន់៥ ឲ្យដូចគ្នាទៅនឹងការគ្រប់គ្រងកងទ័ពដែរឬទេ?

[១០:៥៨:៤៤]

**ឆ៖** នៅពេលរៀបចំសមរភូមិទំនប់កំបោរនេះ ក៏ផែនការខាងលើគេដាក់ថា ឧទាហរណ៍ ថាគេដាក់ថា ៤ខែ ឬក៏៥ខែ។ ដូច្នេះហើយនៅផែនការខាងក្រោម ដូចតាវ៉ាល់ គាត់បានប្រមូលប្រធានវរសេនាធំទាំងអស់ប្រជុំ ប្រាប់ថា ឥឡូវផែនការខាងលើ ចង់បានតែ៤ខែឲ្យរួច ឧទាហរណ៍។ តើយើងទាំងអស់គ្នាហ៊ានប្ដេជ្ញាទេ។ ពួកប្រធានកងធំពេលនោះ គេចង់បានអំណាច គេចង់បានតួនាទី គេប្ដេជ្ញា៣ខែឲ្យរួច។ ថ្នាក់លើ គឺមិនបានបង្ខំចិត្តអ្នកក្រោមទេ ក៏ប៉ុន្តែថ្នាក់ក្រោម ត្រឹមប្រធានវរសេនាធំ គេចង់បានកិត្តិយសគេ តំណែងគេឲ្យបានគង់វង្ស គេប្ដេជ្ញា៣ខែឲ្យរួច។ ក្នុងការប្ដេជ្ញា៣ខែនេះ វាតែងប៉ះពាល់ដល់កម្លាំងខាងក្រោម។ ម្ល៉ោះហើយ គឺថ្នាក់លើមិនមែនបង្ខំទេ តែខាងត្រឹមវរសេនាធំគេប្ដេជ្ញាចង់បានមុខ

PURL: http://www.legal-tools.org/doc/431d2b/

មាត់ គេខ្លាចថា មេណាមិនចេះថែកូន តែងតែរើមេស៊ី ហើយជួនកាល គេថា “មេមាន់កូនទា” នេះជាពាក្យមួយដែលធ្លាប់ឮគេនិយាយ។ ម៉្លោះហើយគេប្ដេជ្ញា៣ខែ។

**ស៖** លោកទើបតែនិយាយថា លោកព្យាយាមសម្រេចកសាងទំនប់៣ខែ ប្រសិនបើមិនអ៊ីចឹងទេ វាអាចមានផលប៉ះពាល់អវិជ្ជមានដល់កម្មករ។ ដូច្នេះខ្ញុំចង់ដឹងថា តើផលប៉ះពាល់អវិជ្ជមាន ឬក៏ផលប៉ះពាល់ហ្នឹង តើជាអ្វីដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១១:០១:៣៦]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមឱ្យសហព្រះរាជអាជ្ញាបញ្ជាក់ពីទីតាំងកន្លែងដែលសាក្សីមានប្រសាសន៍ថាអម្បាញ់មិញផង ព្រោះកន្លងមកសាក្សីមិនទាន់បាននិយាយពីចំណុចនេះនៅឡើយទេ។ បាទ សូមអរគុណ។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំសួរជាសាក្សីជាសំណួរទូទៅ អំពីទំនប់ដែលគាត់ចូលរួមក្នុងការកសាង។ ដូច្នេះគាត់មកផ្ដល់សក្ខីកម្មអំពីទំនប់ទូទៅ មិនមែនទំនប់ជាក់លាក់ណាមួយនោះទេ គឺនិយាយអំពីបទពិសោធន៍របស់គាត់នៅក្នុងការកសាងទំនប់។ ដូច្នេះខ្ញុំមិនបានសួរអំពីទំនប់ជាក់លាក់ណាមួយនោះទេ គ្រាន់តែចង់សួរគាត់អំពីការដែលគាត់ធ្លាប់ធ្វើការសង់ទំនប់ជាច្រើន ពេលដែលគាត់នៅតំបន់៥នោះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី លោកបាននិយាយថា គឺថាត្រូវធ្វើទំនប់ឱ្យហើយក្នុងរយៈពេល៣ខែ។ ប្រសិនបើមិនអ៊ីចឹងទេ វាមានផលប៉ះពាល់ដល់ អវិជ្ជមានដល់កម្មករ។ ចង់សួរថា ផលប៉ះពាល់អវិជ្ជមានហ្នឹងអីគេដែរ?

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅលោកមេធាវី គង់ សំអុន?

[១១:០២:៥៩]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះដដែល ដោយហេតុថា ការតាំងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិបង្ហាញពីភាពជាឧបមាណវិធី។ ហើយសាក្សីបានឆ្លើយខាងមុននោះ ខាងដើម គឺគ្រាន់តែជាឧទាហរណ៍ដើម្បីបញ្ជាក់ពីចំណុចនេះ។ ហើយលើក -- ហើយលោកបានសួរបញ្ជាក់អំពីថា តើបន្ទាប់ពី៣ខែ បើមិនហើយទេ វានឹងកើតរឿងអី? អានេះជាប្រភេទសំណួរឧបមាណវិធី ដែលតុលាការនេះមិនអនុញ្ញាតឲ្យសួរទេ។ បាទ សូមអរគុណ។

**លោក ឌេល លីសាក់៖**

លោកប្រធាន។ ខ្ញុំសួរសាក្សីឲ្យពន្យល់អំពីពាក្យរបស់គាត់ផ្ទាល់ ដែលគាត់និយាយថា នឹងមានផលវិបាកអវិជ្ជមាន។ ដូច្នេះខ្ញុំចង់ដឹងថា តើគាត់និយាយថា ផលវិបាកអវិជ្ជមានហ្នឹង មានន័យយ៉ាងម៉េច? ខ្ញុំគ្រាន់តែចង់ឲ្យគាត់ពន្យល់ពាក្យរបស់គាត់តែប៉ុណ្ណោះឡើងវិញ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់នេះ។ បញ្ហាសំណួរនេះមិនមែនជាឧបមាណវិធីទេ ជាការសង្កេត ឬការកត់សម្គាល់របស់សាក្សីដែលគាត់បានចូលរួម និងបានដឹងរឿងហេតុទាំងនោះ។ ដូច្នេះគាត់អាចឆ្លើយបំភ្លឺបាន ហើយអង្គជំនុំជម្រះចង់ ត្រូវការស្តាប់ចម្លើយរបស់សាក្សីចំពោះសំណួរនេះ។ សាក្សីឆ្លើយតបនឹងសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញារងអម្បាញ់មិញនេះ!

[១១:០៤:២៧]

**លោក 2-TCW-918៖**

**ឆ៖** ការប៉ះពាល់ដល់កម្លាំង គឺមកអំពីយើងប្តេជ្ញា ចង់បានមុនផែនការ ម៉្លោះហើយត្រូវប្រើប្រាស់កម្លាំងនឿយ នឿយលំបាក។ ឧទាហរណ៍ថា យើងត្រូវលើកក្នុងម៉្ងៃ២ម៉ែត្រ យើងគិតសាច់ដី២ម៉ែត្រមិនរួច យើងត្រូវបង្ខំ៣ម៉ែត្រ។ ម៉្លោះហើយវាដូចជាកម្លាំងនោះ វាខំហួសមាឌ។ អានេះគ្រាន់តែការពិចារណា និងការវិភាគរបស់ខ្ញុំទេ។ ក្នុងការអនុវត្តទៅគឺឃើញថាអ៊ីចុះមែន ព្រោះអង្គការថ្នាក់លើគាត់មិនបានកំណត់ថាប៉ុណ្ណេះខែ ប៉ុណ្ណោះខែទេ គាត់ទាញឧទាហរណ៍ ខ្ញុំឧទាហរណ៍ប្រាប់ហើយថាគាត់ឧទាហរណ៍ថា ចំនួន៤ៗខែ ប៉ុន្តែយើងៗប្តេជ្ញាខ្លួនយើងថា៣បីខែ។ បើសិនជាយើងលើក៤ខែកម្លាំងយើងអត់សូវនឿយ ទៅតាមទិសរបស់អង្គការ យើងអត់នឿយទេ។ ក៏ប៉ុន្តែដល់យើងចង់បានអំណាចយើងៗ លើកយក៣ខែ ត្រូវកម្លាំងនោះវានឿយបន្តិច ត្រូវនឿយ។ នេះប៉ះពាល់ដល់ការលំបាកគឺ

អ៊ីចឹងឯង។

**ស៖** សូមអរគុណ។ លោកបានឆ្លើយតបដូចគ្នានៅក្នុងឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាគឺនៅទំព័រដដែល ដូចដែលខ្ញុំបានអានឯកសារ E3/9094 គឺលោកនិយាយអំពីស្ថានភាព គឺថាគេធ្វើផែនការ៤ខែ ប៉ុន្តែមេបញ្ជាការគាត់ប្តេជ្ញាយក៣ខែ។ ហើយនៅចុងក្រោយនៃចម្លើយរបស់លោកគឺលោកបានឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "គេចង់ឲ្យខ្លាំង ដូច្នេះហើយប្រជាជនត្រូវលំបាកខ្លាំងដែរ។" សូមបញ្ចប់ការដកស្រង់។ ពាក់ព័ន្ធទៅនឹងបញ្ហាកសាងទំនប់ក្នុងរយៈពេល៣ខែ គឺមិនមែនធ្វើ៤ខែហ្នឹង តើលោកមានន័យយ៉ាងម៉េច នៅពេលដែលលោកនិយាយថា "គេចង់យកអាខ្លាំង"? តើកាលដែលលោកប្រើពាក្យថា "គេចង់យកអាខ្លាំងហ្នឹង" ចង់មានន័យយ៉ាងម៉េចដែរ?

[១១:០៧:១៥]

**ឆ៖** ខ្លាំងនោះមានន័យថា ដូចថាប្រធានវរៈមួយៗ គេចង់បានរួចមុនផែនការ គេបានធ្វើជាប្រធានវរៈដដែល គេហៅថា "កម្លាំងខ្លាំង កម្លាំងពិសេស" កុំឲ្យធ្លាក់លើដកគេចេញពីប្រធាន ខ្លាចលោចេញទៅកូនក្រុមពិបាករែកដី។

**ស៖** មេបញ្ជាការៗដែលអាចសង់ទំនប់៣ខែ ទទួលបានការដំឡើងឋានៈឬនៅក្នុងរបបនោះ?

**ឆ៖** នៅក្នុងរបបនោះពួកដឹកនាំកម្លាំងធ្វើការដូចថា អ្នកណាគេធ្វើបានត្រូវបានគ្រប់តាមផែនការ គេឡើងទៅជា បើវរសេនាតូច គេបានឡើងដល់វរសេនាធំ គេហៅថា "កងពិសេស"។ កងពិសេសនោះកន្លែងត្រង់ណាដែលលំបាក កន្លែងត្រង់ណាដែលទឹកភក់ គេរុញកងពិសេសនេះឯងទៅ ព្រោះកម្លាំងមាំ។

**ស៖** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកធ្លាប់ឮ ឬក៏ធ្លាប់ដឹងអំពីគណៈមជ្ឈិមបក្សដែរឬទេ? តើលោកធ្លាប់ឮអំពីគណៈមជ្ឈិមបក្សដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ឮគេនិយាយដែរ ប៉ុន្តែខ្ញុំអត់ដឹងថាមជ្ឈិមបក្សហ្នឹងជាស្អី ខ្ញុំអត់ដឹងទេ។ ឮៗថាមជ្ឈិមបក្ស គណៈមជ្ឈិមបក្សក៏ខ្ញុំអត់ដឹងថាស្អីទេ គណៈមជ្ឈិមបក្ស មិនដឹងថាមនុស្ស ក៏មិនដឹងជាសត្វ ខ្ញុំអត់ដឹង ដឹងថាគណៈមជ្ឈិមបក្ស។

**ស៖** តើលោកឮពីមជ្ឈិមបក្សហ្នឹង ឮអំពីអ្វីដែរ? ហើយតើលោកយល់ថា មជ្ឈិមបក្សហ្នឹងជាអ្វីដែរ?

[១១:០៩:៤៣]

PURL: http://www.legal-tools.org/doc/431d2b/

**ឆ៖** ខ្ញុំថាគណៈមជ្ឈិមបក្សហ្នឹងអ្នកដែលធំជាងគេ គេហៅថាគណៈមជ្ឈិមបក្សៗ ធំជាងគេ ប៉ុន្តែមិនដឹងថានរណាទេ ខ្ញុំមិនស្គាល់ទេ។ មិនដឹងជាអ្នកនោះឈ្មោះអីៗ មនុស្សនោះយ៉ាងម៉េចៗ អត់ដឹងទេ ដឹងតែគណៈមជ្ឈិមបក្ស ខ្ញុំស្មានតែគណៈមជ្ឈិមបក្សនេះជាច្បាប់ អត់ដឹងថារូបមនុស្សទេ។ ទើបនឹងដឹងថារូបមនុស្សនេះ ដឹងពេលដែលវៀតណាមចូលនៅឆ្នាំ៧៩ហើយ ដឹងអាពតៗៗៗ។ ពីដើមមិញ គឺគ្មាននរណាស្គាល់ ប៉ុល ពត ទេ ស្គាល់ដែលយួនចូលមកពេញដីខ្មែរតើ ស្គាល់នោះ។ តែត្រង់ ប៉ុល ពត មែន មិនមែន អាហ្នឹងខ្ញុំមិនដឹងទេ ប៉ុន្តែឮនិយាយ ថាតាមគេទៅ។

**ស៖** តើលោកចាំទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺថាតើលោកធ្លាប់ឮពាក្យថា "មហាលោតផ្លោះ មហាអស្ចារ្យទេ"? តើលោកធ្លាប់ឮមេដឹកនាំបក្សនិយាយអំពីពាក្យ "មហាលោតផ្លោះ មហាអស្ចារ្យទេ"? ហើយថាតើលោកយល់ថាពាក្យ "មហាលោតផ្លោះ មហាអស្ចារ្យ" ហ្នឹងមានន័យយ៉ាងដូចម្ដេចដែរ?

**ឆ៖** ខ្ញុំមិនដែលបានឮទេ ពាក្យ "មហាលោតផ្លោះ មហាអស្ចារ្យ"នេះ មិនដែលឮទេ ព្រោះនៅក្នុងអង្គភាពចល័តខ្ញុំ មិនដែលមានឮពាក្យ "មហាលោតផ្លោះ មហាអស្ចារ្យ"នេះ អត់ដែលឮ។ តែបើតាមសហករណ៍ ឬក៏ស្រុក គេមានប្រើពាក្យនោះ ខ្ញុំអត់ដឹង។

**ស៖** តើលោកដឹងទេថា មេដឹកនាំបក្សមានគោលនយោបាយកសាងទំនប់ ប្រឡាយ និងប្រព័ន្ធធារាសាស្ត្រនៅទូទាំងប្រទេសឲ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបានទេ? តើលោកធ្លាប់ឮទេថា គេមានគោលយោបាយបែបនេះ?

[១១:១២:១០]

**ឆ៖** ខ្ញុំមិនដឹងដែរ មិនដឹងជាក្នុងគោលនយោបាយគេ ទៅជាយ៉ាងម៉េចៗ មិនដឹងទេ ខ្ញុំដឹងថា គេប្រើឲ្យទៅវាស់ដី គឺវាស់ ប្រើឲ្យទៅតម្រង់ទំនប់ ក៏ទៅ តែត្រង់ផែនការ ខ្ញុំអត់ដឹងទេ។

**ស៖** ដើម្បីជួយដល់ការចងចាំរបស់លោក ខ្ញុំសូមអានឲ្យលោកស្ដាប់បន្តិច គឺនៅឯកសារមួយចំនួននៅក្នុងឆ្នាំ៧៧ ទាក់ទងទៅនឹងទំនប់ត្រពាំងថ្ម។ ឯកសារទី១ គឺឯកសារ E3/1783 ERN ខ្មែរមានលេខ 00659260, អង់គ្លេសមាន 00498181 និងបារាំងមានលេខ 00606766។ លោកសាក្សី នេះគឺអត្ថបទឆ្នាំ៧៧ ខែធ្នូ ជារបាយការណ៍របស់ចិន ដែលនិយាយអំពីដំណើរទស្សនកិច្ចរបស់មេដឹកនាំចិនមកទំនប់ត្រពាំងថ្ម។ ហើយរបាយការណ៍នេះ គឺបានរាយការណ៍អំពីរបាយការណ៍របស់លោក វស់ ញឹម មេភូមិភាគពាយ័ព្យ ហើយខ្ញុំសូមដកស្រង់៖ "ត្រូវបានកសាងឡើងនៅក្នុង២ឆ្នាំ ២ខែចុងក្រោយដែល

ប្រជាជនខាងភូមិភាគពាយ័ព្យឆ្លើយតបទៅនឹងការអំពាវនាវរបស់គណៈមជ្ឈិមបក្ស ដើម្បីកសាងគម្រោងទំនប់ទឹកឲ្យបានធំទូលាយ។" សូមបញ្ចប់ការដកស្រង់។ ថាតើការដែលខ្ញុំអានឲ្យលោកស្ដាប់ហ្នឹង ថាតើវាអាចជួយឲ្យលោកនឹកឃើញអំពីគោលនយោបាយរបស់មជ្ឈិមបក្សដែរឬទេ? តើលោកដឹងដែរឬទេ ថាតើមានការណែនាំពីមជ្ឈិមបក្សពាក់ព័ន្ធទៅនឹងការសាងទំនប់ដែរឬទេ?

**ឆ៖** សំណួរដែលសួរនេះ គឺខ្ញុំមិនដែលមានបានឮ ហើយក៏មិនដែលបានឃើញពួកចិនឯណាទៅក្នុងអាងត្រពាំងថ្ម គឺអត់ឃើញទេ។ ហើយក៏គណៈមជ្ឈិមបក្ស ក៏មិនដែលមានឮឈ្មោះនៅក្នុងអាងត្រពាំងថ្មទេ ព្រោះបានដឹងតែត្រឹម តាវ៉ាល់ និង តាហ៊ីង្ស ប្រាប់ខ្ញុំប៉ុណ្ណោះ តែត្រង់ផុតពីនោះខ្ញុំអត់ដឹងថាពាក្យនេះមកពីណា ការចាត់តាំង ចាត់ចែងនេះមកពីណាៗគឺខ្ញុំអត់ដឹងទេ អត់ដែលឮថា អ៊ូ! គណៈមជ្ឈិមបក្សឲ្យធ្វើប្រព័ន្ធទំនប់ប្រឡាយអីអត់មាន អត់ដែលឮទេ។

[១១:១៥:៤៧]

**ស៖** លោកបានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា ក្នុងឆ្នាំ៧៥ ដល់៧៦ លោកទទួលខុសត្រូវនៅក្នុងឃុំព្រះនេត្រព្រះ គឺលោកជាអ្នកមើលលើយុវជននៅតំបន់នោះ។ តើលោកធ្លាប់ឮទស្សនាវដ្ដី ដែលគេបោះប្រចាំខែ ដែលគេហៅថាទស្សនាវដ្ដី យុវជន យុវនារីបដិវត្តដែរឬទេ?

**ឆ៖** អត់ដែលបានមើលផង ខ្ញុំមិនដែលបានឃើញទស្សនាវដ្ដី ខ្ញុំមិនដែលបានឃើញដែរ ហើយក៏មិនដែលបានអានដែរ។ ខ្ញុំមិនឃើញបានអីនឹងអាន ទោះបីជាឃើញ ក៏ខ្ញុំមិនដែលអាន ព្រោះខ្ញុំមិនសូវចេះអក្សរ ខ្ជិលមើលដែរ។ វាមិនមែនបញ្ហាចិញ្ចឹមជីវិតខ្លួនឯង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារជូនសាក្សី គឺឯកសារខែកក្កដា-សីហា ៧៦ នៃទស្សនាវដ្ដីយុវជន យុវនារីបដិវត្តគឺ E3/771 ដើម្បីឲ្យគាត់ពិនិត្យមើល ហើយថាតើគាត់អាចចាំដែរឬទេ? ថាតើគាត់ធ្លាប់ឃើញឯកសារបែបនេះដែរឬទេ នៅពេលនោះគឺនៅក្នុងរបបនោះ? សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី នេះគឺជាឯកសារថតចម្លងពណ៌សខ្មៅទេ ប៉ុន្តែវាជាឯកសារតាំងពីឆ្នាំ៧៧មក

ហើយខ្ញុំដឹងថា លោកមិនដែលអានទស្សនាវដ្តីនេះទេ ប៉ុន្តែខ្ញុំចង់ដឹងថាតើលោកធ្លាប់ដែលឃើញឯកសារបែបនេះទេ គឺថាឯកសារជាទស្សនាវដ្តីទង់បដិវត្ត ឬក៏ទស្សនាវដ្តីយុវជន យុវនារី? តើលោកធ្លាប់ដែលឃើញទេ ពេលដែលលោកនៅធ្វើការនៅពេលនោះ?

**លោក 2-TCW-918៖**

**ឆ៖** ខ្ញុំកាលដែលធ្វើការនោះ គឺមិនដែលបានជួបទេ មិនដែលបានឃើញទង់អីចេះទេ ឯកសារនេះក៏មិនដែលបានឃើញ។

**ស៖** ប្រហែលជានៅពេលក្រោយ ខ្ញុំនឹងមានសំណួរបន្ថែមទៀត ប៉ុន្តែឥឡូវនេះ ខ្ញុំសូមអាននូវឯកសារមួយចំនួនទាក់ទងទៅនឹងត្រពាំងថ្ម។ ឥឡូវនេះខ្ញុំសូមងាកត្រឡប់ទៅសួរលោកអំពីកំបោរ ហើយនិងគោករំចេក ដែលលោកធ្វើការនៅនោះ។ ថាតើៗ លោកធ្វើការនៅទំនប់ទាំងពីរហ្នឹងនៅក្នុងថ្ងៃឆ្នាំ នៅក្នុងខែឆ្នាំណាដែរ លោកចាំទេ?

**ឆ៖** កាលចាប់ផ្តើមកាលណោះ គឺចង់ភ្លេចដែរ ប៉ុនខ្ញុំតាម ខ្ញុំចំណាំ អានេះក្នុងខែថ្ងៃ គឺខ្ញុំអត់បានគិតដែរ ខ្ញុំគិតចំណាំពេលវេលា ព្រោះទឹកទើបស្រក ដីទ្រង់សើមៗដែលខ្ញុំដើរតម្រង់ទំនប់កំបោរ យើងស្មានថាទឹកទើបស្រក ស្រូវចេញអីចឹង ស្មានថាបែបជាខែ១២ ចុងខែ១២ ឬក៏ពាក់កណ្តាលខែ១២អីប៉ុណ្ណោះទេ ឬក៏ដើមខែ១។ ទំនប់គោករំចេកដើមខែ១ បើទំនប់កំបោរ បើមិនចុងខែ១២ទេក៏ពាក់កណ្តាលខែ១២ ព្រោះទឹកគោកអស់ហើយ បររទេះក្របីទៅនៅតែផុងៗ គោទៅមិនបាន សុខចិត្តរករទេះក្របីដឹកបង្គោល ដឹកឫស្សី។

[១១:២០:៥១]

**ស៖** ដើម្បីឱ្យច្បាស់ថាខ្ញុំយល់អំពីពេលវេលាដែលលោកនិយាយនោះ ថាតើលោកនិយាយអំពីចុងខែធ្នូ ដើមខែមករា? ថាតើលោកចង់និយាយដើមខែមករា ៧៦ ចុងខែធ្នូ ៧៥ តើអីចឹងមែនទេ? តើលោកចង់និយាយថា លោកធ្វើការនៅទំនប់ទាំងពីរនេះគឺនៅឆមាសទី១នៃៗឆ្នាំ៧៦ តើអីចឹងមែនទេ?

**ឆ៖** បាទ ឆ្នាំ៧៦ហ្នឹងឯង ក៏ប៉ុន្តែបែបជាដំណើរដែលទៅវាស់វែងបែបជាចុងខែ ចុងឆ្នាំ បែបជាចុងឆ្នាំ៧៥។

**ស៖** តើមានកម្មករប៉ុន្មាននាក់ដែរ ដែលគេចាត់តាំងឱ្យទៅកសាងទំនប់ទាំងពីរនោះ?

**ឆ៖** ដែលចុះរៀប ដែលខ្ញុំគេឱ្យធ្វើអ្នកបញ្ជាការសមរភូមិ ដែលចុះតម្រង់ គ្នាខ្ញុំតែប្រាំមួយនាក់ទេ ដើរតម្រង់។ ដល់តម្រង់បានត្រង់ហើយ គាត់មកឃើញថាត្រង់ហើយ គាត់អូសកម្លាំងយកមកដាក់

លើកតែម្តង ព្រោះគ្នាខ្ញុំតែប្រាំមួយនាក់ដែលដើរតម្រង់នោះ ពេលដែលត្រូវការខ្វះខាតអីទាក់ទងតាមសហករណ៍សុំរទេះ សុំឫស្សី សុំអីគេសម្រាប់តម្រង់។

**ស៖** តើកងចល័តតំបន់៥ហ្នឹង គឺជាអ្នកតម្រង់ ហើយតើលោកប្រាប់ទេ អាចប្រាប់បានទេថាតើមានប៉ុន្មាននាក់ដែរនៅក្នុងកងចល័តតំបន់៥នៅឆ្នាំ៧៦នោះ?

**ឆ៖** បាទ កម្លាំងដែលរៀបចំក្នុងឆ្នាំ៧៦ ចាប់ផ្តើមទំនប់កំបោរ វាមាន៦.៥០០នាក់។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើទំនប់ហ្នឹងធំប៉ុនណាដែរ? តើប្រវែងវាៗប៉ុន្មានម៉ែត្រ ប៉ុន្មានគីឡូម៉ែត្រដែរទំនប់កំបោរ ហើយនិងទំនប់ទាំងពីរហ្នឹង? តើលោកចំណាយពេលប្រហែលប៉ុន្មានដែរដើម្បីបញ្ចប់ការសាងសង់ទំនប់ហ្នឹង?

[១១:២៣:៥៧]

**ឆ៖** ទំនប់កំបោរ បណ្តោយ១៣គីឡូម៉ែត្រ បាតក្រោម១០ម៉ែត្រ ខ្នងលើ៥ម៉ែត្រ កម្ពស់២ម៉ែត្រខ្លះ ១,៥ម៉ែត្រខ្លះ ទៅតាមសភាពដី ហើយនិងសភាពទឹក។ ហើយប្រឡាយ មាត់ប្រឡាយ១០ម៉ែត្រ បាតប្រឡាយ៥ម៉ែត្រ នេះទំនប់កំបោរ។ ហើយទំនប់គោករំចេក ស្ពាន់ចារ-គោកទៀម ទល់ទានកាំនោះ ១៨គីឡូម៉ែត្រ។ ប្រឡាយដូចគ្នា ទំនប់ដូចគ្នា ទទឹងបណ្តោយដូចគ្នា អាខ្នងលើ ហើយនិងបាតក្រោមដូចគ្នា។

**ស៖** ចំពោះទំនប់ទាំងពីរហ្នឹង ថាតើគេផ្តល់ឲ្យកងចល័តតំបន់ហ្នឹង រយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំដែរ ដើម្បីឲ្យបញ្ចប់ទំនប់នោះ?

**ឆ៖** ទំនប់កំបោរ គេលើកបញ្ហាថាឲ្យបានរួចមុនចូលឆ្នាំ ទំនប់កំបោរ។ តែដល់ទំបន់គោករំចេក ១៨គីឡូនេះ គេឲ្យរួចមុនចូលឆ្នាំដូចគ្នា។ ហើយក្នុងនោះមានកម្លាំងតែបួនពាន់ជាងទេ ហើយគេឲ្យអាសានីចូកដី ឈូសនោះបី បីគ្រឿង។ ហើយខ្ញុំនៅធ្វើការនៅនោះខ្ញុំមិនហ៊ានប្តេជ្ញាទេ ធ្វើទៅតាមដំណើរពេលណារួច គឺរួចរាល់ទំនប់ វាខុសគ្នា កម្លាំងក៏ខុសគ្នា។ ម្ល៉ោះហើយអត់ហ៊ានប្តេជ្ញា លើក បងប្អូនលើកតាមដំណើរ។

**ស៖** ថាអ៊ីចឹងនៅពេលដែលលោកនិយាយថា បញ្ចប់ឲ្យបានមុនចូលឆ្នាំហ្នឹង តើលោកចង់សំដៅចូលឆ្នាំខ្មែរមែនទេ? បើសិនបើចូលឆ្នាំខ្មែរ គឺចង់និយាយថា នៅក្នុងខែមេសា ឆ្នាំ៧៦ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ព្រោះពេលនោះ យើងបញ្ចប់ឲ្យបានមុនចូលឆ្នាំខ្មែរហ្នឹងឯង ព្រោះយើងខ្មែរ ប្រពៃណីចូលឆ្នាំនៅខែចេត្រ ព្រោះប្រទេសគេផ្សេង ជនជាតិចិន គេចូលឆ្នាំនៅខែ០១ ព្រោះខ្មែរយើងនិយមតែខែចែត្រ។

**ស៖** បើអ៊ីចឹងមានន័យថា ទំនប់ទាំងពីរហ្នឹង គឺថាគេចង់ឲ្យធ្វើឲ្យហើយក្នុងរយៈពេលបីបួនខែ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** គេនិយាយនោះត្រឹមត្រូវមួយចំហៀង តែមួយចំហៀងមិនត្រឹមត្រូវទេ ព្រោះទំនប់មួយចំហៀងនោះ វា១៨គីឡូម៉ែត្រ។ អាមួយចំហៀងកំបោរនេះ វា១៣គីឡូម៉ែត្រ គេអាចប្ដេជ្ញាយករួចមុនចូលឆ្នាំ។ ហើយអា១៨គីឡូម៉ែត្រនោះ គេមិនអាចប្ដេជ្ញាបានទេ ក៏គេលើកចោល ដោយនៅស្ងៀមទៅ។ ពេលណារួច រួចពេលនោះទៅ គេបង្ខំតែទំនប់កំបោរមួយទេ។

**ស៖** លោកសាក្សី ខ្ញុំចង់សួរលោកបន្តិចទៀត ទាក់ទងទៅនឹងស្ថានភាពការងារទូទៅ។ តើការកសាងទំនប់កំបោរ ហើយនិងទំនប់គោករំចេកហ្នឹង គឺស្ថានភាពវាដូចគ្នានឹងការកសាងទំនប់ត្រពាំងថ្មដែរ ឬមួយក៏វាមានភាពខុសគ្នា? ខ្ញុំចង់និយាយអំពីស្ថានភាពការងារ ក៏ដូចជារបៀបរបបក្នុងការកសាងទំនប់នោះ។ ឧទាហរណ៍ដូចថា និយាយពីម៉ោងធ្វើការ គេធ្វើការម៉ោង ម៉ោងធ្វើការដូចគ្នា ឬមួយក៏ខុសគ្នា។ ថាតើក្នុងចំណោមទំនប់ទាំងបីហ្នឹង គឺទំនប់កំបោរ ទំនប់គោករំចេក ហើយនិងទំនប់ត្រពាំងថ្មហ្នឹង តើពួកគេធ្វើការ តើម៉ោងធ្វើការហ្នឹងដូចគ្នា ឬមួយក៏គេធ្វើការម៉ោងខុសគ្នា ច្រើនជាង តិចជាងគ្នាអី?

[១១:២៩:២១]

**ឆ៖** បាទ ទំនប់ទាំងបី ការដ្ឋានទាំងបីនេះ គឺម៉ោងដូចតែគ្នា ម៉ោងសម្រាកដូចគ្នា ចូលធ្វើការម៉ោងមួយកន្លះដូចគ្នា។ ថ្ងៃណាទៅម៉ោងពីរ ចុះចាប់ធ្វើការក៏មានដែរ ហើយគេធ្វើមានម៉ោងដូចគ្នា។ ហើយក្នុងការហូប គឺហូបមួយថ្ងៃបីកំប៉ុង ពួកចល័តតំបន់ គឺរបបត្រូវហូបមួយថ្ងៃ គឺបីកំប៉ុង ព្រោះក្នុងដាំមួយពេលគឺដាំមួយកំប៉ុង បីពេលដាំបីកំប៉ុង។

**ស៖** ចុះផែនការរែកដីវិញ តើដូចគ្នាដែរទេក្នុងចំណោមទំនប់ទាំងបីនោះ?

**ឆ៖** ក្នុងរែកដីក្នុងចំណោមទំនប់ទាំងបីវាមិនដូចគ្នាទេ ព្រោះនៅអាងត្រពាំងថ្មវាធំ ហើយវាខ្ពស់ហើយវាឆ្ងាយ។ ហើយទំនប់កំបោរ ហើយនិងទំនប់គោករំចេក វាទាប វាតូច ខ្លី ជិត។ ម្ល៉ោះហើយក្នុងរែកវាមិនដូចគ្នាទេ វាមាន ឧទាហរណ៍យើងនៅខាងទំនប់គោករំចេក យើងលើកបានមួយអំរែក ហើយខាងទំនប់អាងត្រពាំងថ្មនោះ មិនបានមួយអំរែកទេ ព្រោះវាឆ្ងាយ ម្ល៉ោះហើយរែកឆ្ងាយគឺមិនបានដាក់ពេញបង្គីឲ្យហៀរដូចយើងលើកអាជិតទេ។ អាជិត យើងដើរតែពីរបីជំហាន តែ៥ម៉ែត្រគឺដល់កន្លែងចាក់។ បើអាងត្រពាំងថ្មវា១០ម៉ែត្រជាងនោះបានដល់កន្លែងចាក់។ ម្ល៉ោះហើយវាឆ្ងាយខុសគ្នា ពេលវេលាវាមិនដូចគ្នាទេ រែកក៏វាមិនដូចគ្នាដែរ។

PURL: http://www.legal-tools.org/doc/431d2b/

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំនឹងនិយាយអំពីផែនការរែកដីហ្នឹងនៅពេលក្រោយបន្តិចទៀត។ ឥឡូវនេះពាក់ព័ន្ធទៅនឹងទំនប់គោករំចេកវិញ តើលោកចាំទេថា មានមេដឹកនាំបក្ស ឬក៏មានថ្នាក់ដឹកនាំណាម្នាក់មកទំនប់គោករំចេកហ្នឹងដែរឬទេ?

[១១:៣២:០២]

**ឆ៖** ពេលនោះ ទំនប់គោករំចេកនោះមាន ប៉ុន្តែខ្ញុំមិនស្គាល់។ ក្នុងនោះ ឃើញឡានមួយឈប់ ក៏មានមនុស្សម្នាក់ចុះមកឈរមើល អត់មាននិយាយអីជាមួយនរណា អត់មានហៅកងចល័ត ឬក៏ហៅមេបញ្ជាការកងធំ វរសេនាធំអីជួបជុំគឺអត់មានទេ។ អានេះគឺឃើញចុះពីលើឡានតែម្នាក់ រួចក៏ឡើងឡានចូលទៅភ្នំស្រុកទៅ ឡានក៏បើកចូលទៅភ្នំស្រុកទៅ។ មិនដឹងជាអង្គការថ្នាក់ណា ឬក៏ជាអ្នកណា គឺអត់ដឹង គឺមានៗម្នាក់ដែលទៅនោះ។ ឡានមួយវាមិនមែនមនុស្សទេ ឡានមួយ ប៉ុនឃើញចុះតែម្នាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗសហព្រះរាជអាជ្ញារង។ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការចំពោះមុខអង្គជំនុំជម្រះនេះនៅវេលាម៉ោងមួយកន្លះរសៀល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្តល់វេទិកាជូនទៅ

ក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំបានសួរលោក ថាតើមានមេដឹកនាំណាបានមកពិនិត្យមើលការដ្ឋានគោករំចេកដែរឬក៏អត់ លោកបានរៀបរាប់ថា មានពេលមួយនោះ លោកបានឃើញមនុស្សម្នាក់ទៅទីនោះ ហើយបានដើរចុះចេញពីរថយន្ត ហើយដំបូងនោះ លោកមិនបានស្គាល់មនុស្សនោះទេ។ ក្រោយពីបុគ្គលនោះចាកចេញជាមួយរថយន្តនោះទៅនោះ លោក តើមេដឹកនាំរបស់លោក មេរបស់លោក តាវ៉ាល់ មានបានប្រាប់លោកថា អ្នកនោះជាអ្នកណាដែរទេ?

**លោក 2-TCW-918៖**

**ឆ៖** សូមគោរពលោកប្រធាន។ ពេលនោះមេដឹកនាំ តាវ៉ាល់ គាត់បានប្រាប់ថា ខៀវ សំផន ប៉ុន្តែខ្ញុំពេលនោះ ខ្ញុំមិនស្គាល់គាត់ទេ ព្រោះដល់ពេលសព្វថ្ងៃនេះ ដែលខ្ញុំបានឃើញគាត់ រូបដែលថា ខៀវ សំផន នោះ មិនមានរូបអីចុះទេ ព្រោះរូបនោះ ធំដំបង ខ្ពស់ មិនមែនរូប ខៀវ សំផន នេះទេ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីមនុស្សម្នាក់ដែល តាវ៉ាល់ ប្រាប់លោកថាគឺជា ខៀវ សំផន នៅពេលក្រោយបន្តិច។ មុនពេល តាវ៉ាល់ ប្រាប់លោកថាគឺ ខៀវ សំផន ដែលបានទៅការដ្ឋានទំនប់គោករំចេកហ្នឹង តើអតីតព្រះបិតាជាតិ នរោត្តម សីហនុ មានធ្លាប់បានទៅពិនិត្យការដ្ឋានលើកទំនប់នោះដែរទេ?

**ឆ៖** អត់ទេ។ អត់ដែលបានទៅទេ។

[១៣:៣៥:៤៤]

**ស៖** លោកចាំធ្លាប់ដែលបានឃើញព្រះមហាក្សត្រ នរោត្តម សីហនុ ដែរទេ នៅពេលដែលព្រះអង្គយាងទៅភ្នំស្រុកនោះ?

**ឆ៖** មិនបានឃើញទៅភ្នំស្រុកទេ។ ឃើញពេលនោះសម្តេចឪបានទៅព្រៃមាន់ គេហៅថា “គបីដើម” មិនមែនទៅភ្នំស្រុកទេ។

**ស៖** ឥឡូវនេះ ខ្ញុំសូមអានសម្រង់មួយចំនួនដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា

ដើម្បីឲ្យយល់ ឲ្យលោកពន្យល់ជូនតុលាការ ហើយនិងពន្យល់អំពីចម្លើយរបស់លោកនេះ ជូនតុលាការ។ ឥឡូវសូមចាប់ផ្តើមជាមួយឯកសារ E3/9094 ERN ជាភាសាខ្មែរ 00734078 ដល់ 79, អង់គ្លេស 00728675 ដល់ 76 និងបារាំង 01123637 ដល់ 38។ នេះគឺជាភ័ស្តុតាងដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា៖ “ខៀវ សំផន និង សម្តេច សីហនុ បានទៅពិនិត្យមើលការដ្ឋានត្រពាំងថ្មដែរឬទេ? ថាអត់ទេ។ គាត់មកមើលទំនប់គោករំចេកដែលខ្ញុំលើក។ សួរ៖ នៅកាលនុំងសម្តេច គាត់យាងមកជាមួយអ្នកណា? ឆ្លើយ៖ សម្តេចមកជាមួយប្រពន្ធគាត់ ហើយនិងសម្តេច ប៉ែន នុត។ សួរ៖ បីនាក់ហ្នឹងទេ? ដល់ក្រោយមកទៀត ខៀវ សំផន  គាត់មកទៀតទេ? បាទក្រោយមក ខៀវ សំផន បានមកតែគាត់ គ្នាពីរបីនាក់ដែរ។ សួរ៖ កាលសម្តេចមកឆ្នាំណា ដែលមកមើលទំនប់គោករំចេកហ្នឹង? ឆ្លើយ៖ សម្តេចយាងមកនៅឆ្នាំ៧៦។ សួរ៖ ៧៦ ខែណាដែរ? ឆ្លើយ៖ គឺជាខែដែលប្រជាជនចាប់ផ្តើមដកស្ទូង រវាងខែមេសា និងខែឧសភា។” បញ្ចប់ការដកស្រង់។ លោកសាក្សីតើចម្លើយទាំងអម្បាលម៉ានរបស់លោកនេះ ខ្ញុំអានអម្បាញ់មិញជួយរំឭកដល់ការចងចាំទេ ថាតើអតីតព្រះមហាក្សត្រមានបានយាងទៅពិនិត្យមើលទំនប់គោករំចេកជាមួយនឹងសម្តេច ប៉ែន នុត ដែរទេ?

**ឆ៖** ពេលនោះគឺសម្តេចមិនបានយាងទៅទំនប់គោករំចេកទេ គឺសម្តេចយាងទៅព្រៃមាន់ គេហៅថា គបីដើម ព្រៃមាន់។

[១៣:៣៩:៣០]

**ស៖** សូមលោកពន្យល់ជូនតុលាការបន្តិចមកថា ទីតាំងហ្នឹងស្ថិតនៅក្នុងឃុំស្រុកណាដែរ គឺទីតាំងឃុំស្រុកដែលព្រះមហាក្សត្របានយាងចុះទៅពិនិត្យការដ្ឋានលើកទំនប់ហ្នឹង?

**ឆ៖** នៅគោករំចេកនោះ គឺទីតាំងនៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យយើង។

**ស៖** ឲ្យជាក់លាក់មែនទែនទៅ ថាតើព្រះមហាក្សត្រ ព្រះអង្គយាងទៅចុះពិនិត្យមើលអ្វីដែរនៅក្នុងដំណើរទស្សនកិច្ចរបស់ព្រះអង្គហ្នឹង? ពិតឲ្យមែនទែនទៅ តើព្រះអង្គទៅមើលអី?

**ឆ៖** ពេលនោះ ខ្ញុំក៏មិនដឹងថាព្រះអង្គទៅមើលអីដែរ ព្រោះព្រះអង្គចុះពីឡានមក គឺនៅលើថ្នល់ក្រហមផ្លូវចូលទៅភ្នំស្រុក ខាងជើងព្រៃមាន់ប្រហែលជា២គីឡូ គេហៅថាគបីដើម ប៉ុន្តែព្រះអង្គមិនបានចុះដល់ទំនប់ទេ ព្រះអង្គនៅតែលើថ្នល់ក្រហមនោះ ក៏ព្រះអង្គត្រឡប់មករកព្រៃមាន់វិញ តែប៉ុណ្ណោះ។

**ស៖** តើផ្លូវនេះវានៅជិតការដ្ឋានលើកទំនប់ដែលលោកធ្វើការហ្នឹងឬអត់ទេ ទើបបានជាលោកឃើញព្រះមហាក្សត្រទៅទតការលើកទំនប់ហ្នឹង?

**ឆ៖** នៅឆ្ងាយៗប្រហែលជាជាង១០គីឡូ ប៉ុន្តែពេលដែលព្រះអង្គទៅនោះ គេបានហៅខ្ញុំទៅទទួលព្រះអង្គដែរ បានជាខ្ញុំបានឃើញ។

[១៣:៤២:០១]

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានរៀបរាប់អំពីការរៀបចំទីកន្លែងនោះជាមុន មុនពេលព្រះអង្គយាងទៅដល់។ ហើយតើនៅពេលមុនហ្នឹង គេប្រាប់ទៅលោកឲ្យរៀបចំ ឲ្យត្រៀមលក្ខណៈតំបន់ហ្នឹងទុកជាមុនយ៉ាងម៉េចដែរ មុនដំណើរទស្សនកិច្ចរបស់ព្រះអង្គទៅទតនៅទីនោះ?

**ឆ៖** គឺការរៀបចំនោះ គឺខ្ញុំមិនបានដឹងទេ។ ដល់ពេលថ្ងៃដែលសម្តេចយាងមក ទើបបានគេប្រាប់ខ្ញុំឲ្យទៅទទួលស្តេចប៉ុណ្ណោះឯង។ ការរៀបចំមុន គឺខ្ញុំអត់ដឹងៗថាស្តេចមកថ្ងៃណាៗ អត់ដឹង។ បើពីដើម យើងបានដឹងសម្តេចយាងទៅត្រង់ណាៗ គេតែងប្រាប់ប្រជាជនទាំងអស់ដើម្បីឲ្យទៅទទួលព្រះអង្គ ដល់ពេលនេះអត់មានបានដឹងមុនទេ ស្រាប់តែគេហៅតែម្តង ហៅតែខ្ញុំម្នាក់ទេក្នុងមួយអង្គភាព។

**ស៖** ខ្ញុំសូមអានចម្លើយដែលលោកឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា អំពីការរៀបចំជាមុនសម្រាប់ដំណើរទស្សនកិច្ចរបស់ព្រះអង្គ គឺឯកសារ E3/9094 ដដែល។ ERN ជាភាសាខ្មែរ 00734079 ដល់ 080, អង់គ្លេស 00728676 ដល់ 777, បារាំង 01123638 ដល់ 3639។ នេះគឺជាអ្វីដែលលោកបានឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ សូមដកស្រង់៖ "នៅពេលសម្តេចឪយាងទៅមើល ទតការដ្ឋានលើកទំនប់ គេឲ្យអាអ្នកស្គមៗចេញទៅបាត់ មិនឲ្យពួកអ្នកស្គមៗកំព្រឹងអឺចឹងនៅកន្លែងនោះ ដើម្បីឲ្យសម្តេចបានទតឃើញថាមានអ្នកស្គមៗអឺចឹងទេ។ ព្រះអង្គ គេអនុញ្ញាតឲ្យព្រះអង្គទៅមើលតែស្ត្រីដែលនៅការដ្ឋាននោះដែលមានពាក់ស្បែកជើងខោអាវខ្មៅ។ អ្វីដែលព្រះអង្គទតឃើញ គឺថាល្អទាំងអស់ ប៉ុន្តែគេមិនអនុញ្ញាតឲ្យព្រះអង្គបានទតឃើញប្រជាជនដែលមានរាងកាយស្គមស្គាំងនោះទេ។"

ហើយនៅទំព័រខាងក្រោមមកទៀត៖ "សួរ៖ លោកបានដឹងថាអ្នកដែលហើមត្រូវបាន អ្នកហើមស្គមគេបញ្ជូនចេញ ឬក៏អី? បាទ ពីព្រោះគេបញ្ជាឲ្យខ្ញុំរៀបចំកងកម្លាំង កម្លាំងកងចល័តហ្នឹងដើម្បីទទួលសម្តេច។" បញ្ចប់ការដកស្រង់។ លោកសាក្សី តើនេះវាជួយរំឭកដល់ការចងចាំរបស់លោក របស់គេ ដែលថាអ្នកដែលឈឺ អ្នកដែលស្គមស្គាំង គឺថាត្រូវគេយកបញ្ជូនចេញទៅក្រៅបាត់ ហើយលោកទទួលការណែនាំនេះពីមេរបស់លោក ដើម្បីរៀបចំកម្លាំងកងចល័តឲ្យទៅទទួលព្រះអង្គ លោកនៅចាំ

រឿងនេះទេ?

[១៣:៤៥:៤៦]

**ឆ៖** រឿងនេះ គឺគេមិនបានឲ្យខ្ញុំដឹកនាំកងចល័តទៅទទួលព្រះអង្គទេ គឺគេគ្រាន់តែហៅខ្ញុំទៅតែម្នាក់ទេ ប៉ុន្តែពេលដែលខ្ញុំទៅ ខ្ញុំឃើញអ្នកដែលនៅទទួលព្រះអង្គសុទ្ធតែអាវខ្មៅ ខោខ្មៅ ស្បែកជើងប៉ូវ៉ា តែអ្នកដែលនៅកន្លែងនោះពីដើម ស្គមៗ គឺគេយកបញ្ជូនចេញទៅណាអស់ គឺខ្ញុំអត់ដឹងទេ។ ឲ្យទៅនៅឆ្ងាយពីថ្នល់ជាតិ គឺខ្ញុំមិនបានដឹងថា គេរៀបចំយ៉ាងម៉េចៗទេ គ្រាន់តែមិនឃើញ គឺខ្ញុំឆ្ងល់តែប៉ុណ្ណោះឯង។

**ស៖** ឥឡូវខ្ញុំត្រឡប់ចូលទៅព្រឹត្តិការណ៍មួយ ដែលលោកបានឃើញបុគ្គលម្នាក់ចេញមកពីឡាន ហើយក្រោយមក តាវ៉ាល់ ប្រាប់ទៅលោកថាគឺជា ខៀវ សំផន ហើយ។ តើព្រឹត្តិការណ៍ហ្នឹងកើតមានឡើងនៅពេលណា? ពេលដែលព្រះអង្គបានយាងទៅពិនិត្យមើលកន្លែងការដ្ឋានលើកទំនប់ ក្នុងកន្លែងរបស់លោកនោះ ពេលនោះគឺចំពេលខែឆ្នាំណា?

**ឆ៖** ពេលនោះ គឺខែ៤ វាត្រូវនឹងខែចែត្រ។ ខែចែត្រនោះឃើញថា ឡានមួយទៅខាងភ្នំស្រុក ឃើញមនុស្សម្នាក់ដែលចុះមក ឃើញពិតប្រាកដមែន តែខ្ញុំមិនស្គាល់ទេ។ ដល់ចេញផុតហើយ តាវ៉ាល់ គាត់ថា ខៀវ សំផន។ ហើយខ្ញុំមិនដែលឃើញគាត់ទេ ខ្ញុំក៏ឮតែគាត់ថាប៉ុណ្ណោះ ក៏ខ្ញុំនៅស្ងៀមទៅ។ ដល់ថ្ងៃណោះថ្ងៃមុនដែលខ្ញុំបានចូលកន្លែងសវនាការនេះ ខ្ញុំឃើញរូប ខៀវ សំផន មិនមែនដូចរូបដែល តាវ៉ាល់ ប្រាប់ខ្ញុំទេ។ បានន័យថា រូបនោះគឺមិនមែនទេ មិនមែន ខៀវ សំផន ទេ ព្រោះមាឌដែលឃើញនោះ ធំដំបង ខ្ពស់។

[១៣:៤៨:៣០]

**ស៖** នៅពេលដែលលោកនិយាយថា មនុស្សដែលលោកឃើញហ្នឹងមានមាឌធំខ្ពស់ហ្នឹង ពេលដែលលោកថា មានមាឌធំខ្ពស់ហ្នឹង លោកចង់និយាយថាម៉េច កម្ពស់ប៉ុន្មាន?

**ឆ៖** ស្មានមិនត្រូវទេ។ កម្ពស់នោះកម្ពស់ប្រហែលជា៧០លើស នេះតាមស្មានទេ ក៏៨០ទេដឹង ព្រោះខ្ញុំមិនដែលស្មានមនុស្សផង។ ប៉ុន្តែឲ្យថាទាប មិនមែនទេ ព្រោះលោកតាខៀវ សំផន ខ្ញុំបានមកឃើញគាត់កាលឆ្នាំមុន នៅកន្លែងនេះ គាត់ទាប គាត់មិនខ្ពស់ ដូចដែលខ្ញុំឃើញនោះទេ។ បានខ្ញុំថាអត់មែនគាត់ទេ។

**ស៖** ចុះបើសិនជាលោកប៉ាន់ប្រមាណមើលលោក តើលោក ខៀវ សំផន នេះមានកម្ពស់ប៉ុន្មាន

ម៉ែត្រដែរ?

**ឆ៖** តាមដែលខ្ញុំឃើញគាត់ពីចម្ងាយនេះ ដែលឃើញគាត់ឆ្នាំមុនដែលខ្ញុំមក ខ្ញុំឃើញពីចម្ងាយ កម្ពស់គាត់ប្រហែលជា១ម៉ែត្រ ៦៧ ឬក៏៦៨ មិនដល់៧០។

**ស៖** នៅពេលណាដែលលោកបានឃើញ ខៀវ សំផន ជិតមែនទែនទើបដែល១នាំឲ្យលោកអាច ស្មានកម្ពស់របស់គាត់បានហ្នឹង?

**ឆ៖** ពេលដែលគេហៅខ្ញុំមកក្នុងកន្លែងសវនាការនេះឯង មកឆ្នាំ២០១៣អីទេ កាលនោះ ខ្ញុំភ្លេច ទៅដែរ។

**ស៖** មនុស្សដែលទៅពិនិត្យមើលការដ្ឋានរបស់លោក ហើយដែលមេរបស់លោកប្រាប់ថាគឺជា ខៀវ សំផន ហើយដែលឥឡូវលោកថាមិនមែនជា ខៀវ សំផន ទេ ដោយសារថា ខៀវ សំផន មិនអាច មានកម្ពស់ទៅដល់១,៧០ម៉ែត្រទេ។ នៅពេលបុគ្គលនោះទៅពិនិត្យមើលការដ្ឋាននោះ តើគេមានប្រាប់ លោកជាមុនថា មានអ្នកណាម្នាក់ទៅពិនិត្យមើលការដ្ឋាននោះទេ ដើម្បីឲ្យលោករៀបចំកន្លែងការដ្ឋាន ជាមុន១នឹងមនុស្សនោះទៅដល់?

[១៣:៥១:៣១]

**ឆ៖** អត់មានទេ សូម្បីតែ តាវ៉ាល់ ក៏គាត់មិនដឹងថាអ្នកណាទៅផង គាត់អត់ដឹងដែរ មិនមាន អ្នកណាប្រាប់ទេ អត់មានដំណឹងមុនទាំងអស់។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោក លោកក៏បានបញ្ជាក់ដែរថានៅពេលដែលលោកឃើញ បុគ្គលនោះទៅដល់ លោកបានគិតថាគឺជាកម្មាភិបាលជាន់ខ្ពស់ហើយ។ តើលោកអាចពន្យល់ជូន តុលាការបានទេ ថាធ្វើម៉េចបានជាលោកគិតថាបុគ្គលនោះ គឺជាអ្នកដែលមានតួនាទីខ្ពង់ខ្ពស់នោះ គឺជា កម្មាភិបាលជាន់ខ្ពស់នោះ?

**ឆ៖** ហើយក្នុងការរ៉ៃស្មានរបស់ខ្ញុំដែលថាកម្មាភិបាលជាន់ខ្ពស់ ព្រោះគាត់ទៅនោះ គាត់មាន ឡានជិះ ព្រោះសម័យនោះអត់ដែលមានប្រជាជនណាមានឡានជិះទេ។

**ស៖** រថយន្តនោះជារថយន្តប្រភេទអីដែរ?

**ឆ៖** ខ្ញុំចាំមិនបាន មិនដឹងជាម៉ាកអី ប្រភេទអី ខ្ញុំអត់ដែលស្គាល់រថយន្តផង។

**ស៖** លោកសាក្សីមនុស្សដែលមេរបស់លោកប្រាប់ថាជា ខៀវ សំផន នោះនៅពេលមនុស្ស នោះចេញពីរថយន្ត តើគាត់ធ្វើអ្វី?

PURL: http://www.legal-tools.org/doc/431d2b/

**ឆ៖** អត់ឃើញមានគាត់ធ្វើអីផង គ្រាន់តែគាត់ចុះពីលើរថយន្តគាត់ឈរអែបរថយន្តនោះឯង គាត់គ្រាន់តែឈរមើលប៉ុណ្ណោះឯង អត់មាននរណាទៅជិតគាត់ទេ គ្រាន់តែឈរតែម្នាក់ឯងរួច ក៏ឡើងឡានទៅភ្នំស្រុកទៅ។

**សៈ** តើមនុស្សរូបនេះគឺថាឈរនៅលើខ្នងទំនប់ដើម្បីមើលកម្លាំងហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** មិនមែនឈរលើខ្នងទំនប់ទេ។ ឈរលើផ្លូវលំ ផ្លូវដែលសំដៅចូលស្រុកភ្នំស្រុកផ្លូវគ្រួសក្រហម គាត់មិនមែនឈរលើខ្នងទំនប់ទេ។

[១៣:៥៤:២៧]

**សៈ** ខ្ញុំសូមអាននូវចម្លើយដែលលោកឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារដដែល គឺ E3/9094 ត្រង់ខ្មែរ ERN 00734082, អង់គ្លេស 00728678, បារាំង 01123640។ សូមដកស្រង់៖ "នៅពេលយើងកំពុងលើកទំនប់គោករំចេក គាត់ឈរនៅលើខ្នងទំនប់ ហើយពិនិត្យមកមើលយើង។ សួរ៖ តើគាត់ឈរនៅទីនោះម្នាក់ឯងឬ? ឈរនៅទីនោះយូរទេ? ឆ្លើយ៖ យូរដែរ ខ្ញុំបានមើលទៅគាត់ ហើយខ្ញុំឃើញគាត់ឈរនៅទីនោះយូរណាស់។ ខ្ញុំគិតថា ជាមួយនឹង តាហ៊ីង្ស ហើយនិង តាវ៉ាល់ ថាកម្មាភិបាលជាន់ខ្ពស់មកដល់។ នៅពេលដែលខ្ញុំទៅជិតគាត់ ខ្ញុំអត់ស្គាល់។" បញ្ចប់ការដកស្រង់។ លោកសាក្សី លោកបានឆ្លើយថា លោកបានចូលទៅជិត ហើយមើលទៅមនុស្សនោះ គឺថាជិតដែរ តើជិតហ្នឹង ជិតប៉ុនណាដែរ?

**ឆ៖** ព្រោះការដែលឈរជិតនេះ ព្រោះកម្លាំងលើកទំនប់នោះ លើកឆ្ងាយពីផ្លូវលំនោះ ប្រហែលជា២គីឡូជាងហើយ។ ហើយខ្ញុំក៏ដើរទៅជិតនោះ ក៏មិនបានដល់ទៅលើថ្នល់ក្រហមនោះទេ។ គ្រាន់តែនៅឯដំបូកមួយ គេហៅថាគោកមួយ នៅគោករំចេក ចម្ងាយពីផ្លូវលំចូលភ្នំស្រុកនោះ ប្រហែលជា២៥០ម៉ែត្រ។ មិនបានទៅជិត ដូចថា យើង១ម៉ែត្រ ២ម៉ែត្រ អត់មែនទេ។

**សៈ** ខ្ញុំព្យាយាមសួរលោកម្តងទៀត ដើម្បីឲ្យយល់ឲ្យបានច្បាស់។ លោកឆ្លើយថា លោកនៅចម្ងាយជិតហ្នឹង គឺចម្ងាយ២៥០ម៉ែត្រ អ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

ឆ្លើយ! សូមអញ្ជើញឆ្លើយ!

**លោក 2-TCW-918៖**

**ឆ៖** បាទ ចម្ងាយប្រហែល២៥០ម៉ែត្រនេះឯង មិនមែនជិតដូចយើង ១០ម៉ែត្រ ២០ម៉ែត្រអីទេ។

PURL: http://www.legal-tools.org/doc/431d2b/

[១៣:៥៧:២៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ហើយសក្ខីកម្មរបស់លោក គឺឆ្លើយដែលឆ្លើយជូនតុលាការដែលថា ចម្ងាយដែលលោកឃើញបុគ្គលនោះ គឺលោកថាមនុស្សនោះ គឺមានកម្ពស់ប្រហែលជា១,៧០ម៉ែត្រ មិនមែន១,៦០ម៉ែត្រជាង ឬក៏ថា១,៨០ម៉ែត្រនោះទេ។ តើលោកកំពុងតែឆ្លើយថាអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំឆ្លើយថា មនុស្សនោះ វាមួយ១,៧០ម៉ែត្រជាង មិនមែន៦០ទេ ប្រហែលជា៧០ជាង តែមិនដល់៨០ទេ។

**ស៖** សម្រង់ចុងក្រោយមួយ ដែលលោកឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាទៅលើប្រធានបទដដែលនេះ គឺទំព័រដដែល ដែលខ្ញុំបានដកសម្រង់មុននេះ គឺមានជាភាសាខ្មែរ 00734081, អង់គ្លេស 00728677 ដល់78, បារាំង 01123639។ "សួរ៖ តើលោក – នេះគឺជាសំណួរទាក់ទងទៅនឹងមនុស្សដែលមេរបស់លោក តាវ៉ាល់ ប្រាប់ថាជា ខៀវ សំផន នោះ – សួរ៖ ចុះលោកមានរៀបចំទទួលអីគាត់ទេ? អត់មានអ្នកណាដឹងថាគាត់មកទេ។ តើមានបានរៀបចំអ្វីជូនគាត់ទេឬ? អត់ទេ។ សួរ៖ តើគាត់បានមើលឃើញប្រជាជនច្បាស់ អ្នកស្គម អ្នកស្គាំងអីឃើញដែរទេ? បាទ។" បញ្ចប់ការដកស្រង់។ ត្រឹមត្រូវដែរទេ លោកសាក្សីដែលថាមេដឹកនាំទៅពិនិត្យការដ្ឋាន ហើយដែលមេរបស់លោកប្រាប់ថាគឺជា ខៀវ សំផន នោះ ដែលខុសពីដំណើរទស្សនកិច្ចរបស់ព្រះអង្គនោះ គឺថានៅពេលនោះ គឺអ្នកដែលឈឺ និងអ្នកស្គមស្គាំងមិនត្រូវបានគេយកចេញ មិនឲ្យអ្នកនោះឃើញទេ ត្រឹមត្រូវដែរទេ?

[១៣:៥៩:៥៤]

**ឆ៖** មិនត្រឹមត្រូវទេ ព្រោះវាច្រឡំគ្នា វាអត់មែនត្រូវសាច់រឿងគ្នាទេ ព្រោះដែលគេយកមនុស្សស្គមចេញនោះ ពេលដែលសម្តេចយាងទៅព្រៃមាន់ទេ។ តែដែលត្រង់ថា ដែលឃើញមនុស្សម្នាក់ទៅនេះ គឺមិនមែនទៅឃើញមនុស្សប្រជាជនលើកទំនប់ជីកប្រឡាយ គឺអត់មានបានឃើញទេ។ ព្រោះគាត់ដើរតែតាមថ្នល់តែគាត់ គាត់ចុះពីលើឡានតែគាត់ តាមថ្នល់តែគាត់ទេ។ គាត់មិនបានទៅត្រួតពិនិត្យកន្លែងការដ្ឋានទំនប់គោករំចេកនោះទេ។

**ស៖** ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត លោកសាក្សី គឺខ្ញុំនឹងនិយាយអំពីការដ្ឋានទំនប់ត្រពាំងថ្ម។ ដូច្នេះជាដំបូងខ្ញុំចង់សួរលោកថា តើលោកធ្លាប់ចូលរួមនៅក្នុងការប្រជុំណាមួយដែលនៅក្នុងការប្រជុំហ្នឹង គឺគេលើកអំពីផែនការកសាងទំនប់ត្រពាំងថ្ម តើលោកធ្លាប់ចូលរួមការប្រជុំបែប

នេះដែរឬទេ?

**ឆ៖** ក្នុងការប្រជុំចូលរួមអាងត្រពាំងថ្មនេះ គឺខ្ញុំមិនដែលបានប្រជុំទេ។ មិនដែលបានចូលរួមប្រជុំជាមួយអង្គការថ្នាក់លើ ថ្នាក់ក្រោយអីណា អត់ឡើយ។ គ្រាន់តែគេឲ្យខ្ញុំចាប់ផ្តើមរៀបចំធ្វើផ្លូវ ដូចខ្ញុំបានប្រាប់ពីព្រឹកម្តង។

[១៤:០១:៥១]

**ស៖** ខ្ញុំសូមអានជូនលោកនូវចម្លើយ ដែលលោកផ្តល់ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត គឺ E3/9504 គឺជាសំណួរចម្លើយទី១ នៅក្នុងកិច្ចសម្ភាសន៍។ "សំណួរ៖ តើលោកធ្លាប់ចូលរួមកិច្ចប្រជុំរៀបចំផែនការសម្រាប់ការកសាងទំនប់ដែរឬទេ? ឆ្លើយ៖ បាទ ខ្ញុំធ្លាប់ចូល។ ក្នុងកិច្ចប្រជុំហ្នឹង គឺមានការចូលរួមពីគណៈតំបន់ គណៈភូមិភាគ ប្រធានកងចល័តតំបន់ ហើយនិងប្រធានកងតំបន់ ព្រមទាំងអ្នកមកពីការដ្ឋានផ្សេងៗទៀត។" ដូច្នេះខ្ញុំចង់សួរលោកថា តើការប្រជុំហ្នឹងកើត -- ការប្រជុំហ្នឹងវាធ្វើនៅកន្លែងណា នៅពេលដែលលោកផ្តល់ចម្លើយឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង ហើយនៅក្នុងចម្លើយហ្នឹងគឺលោកថា មានអ្នកចូលរួមពីខាងគណៈតំបន់ និងគណៈភូមិភាគចូលរួមផងដែរនោះ?

**ឆ៖** អ៎! អាប្រជុំនោះ កាលនោះប្រជុំមែន។ ប្រជុំនៅនឹងស្វាយស៊ីសុផុន កន្លែងគឺថាសាលានយោបាយ។ បើសព្វថ្ងៃនេះ គឺគេធ្វើជាមន្ទីរបក្សៗ។ គឺបានប្រជុំរៀបចំផែនការទៅតាមអ្នកដែលមានកម្លាំង ដូចប្រធានវរសេនាធំ ហើយប្រធានតំបន់ៗ ប្រធានចល័តតំបន់ ហើយនិងគណៈតំបន់ គណៈភូមិភាគខ្ញុំអត់ស្គាល់ទេ គ្រាន់តែគេថា ឃើញតែរូបមិនដឹងជានរណាទេ។ គេថា មកពីភូមិភាគៗ ក៏ថានឹងគេទៅ ភូមិភាគនឹងគេទៅ។ កាលនុ៎ងបានប្រជុំរៀបចំផែនការលើកអាង កាលដែលមុនដំបូង គឺមិនបានប្រជុំទេ ដែលប្រើខ្ញុំទៅវាស់នោះ គ្រាន់តែ តាវ៉ាល់ គាត់ប្រើទៅទេ។ ទៅវាស់ធ្វើជាផ្លូវពីសំរោង-កាណាំងទៅដូនណូយ។ ដល់ក្រោយមកគេរៀបចំជាអាង ក៏ហៅប្រជុំដែរ។ ប្រជុំនឹងស្វាយនេះឯង ប៉ុន្តែកន្លែងនោះសព្វថ្ងៃ គេធ្វើជាមន្ទីរបក្ស។

**ស៖** ដូច្នេះកិច្ចប្រជុំដែលលោកចូលរួមនៅស្វាយស៊ីសុផុននុ៎ង គឺនៅក្រោយពេលដែលគេរៀបចំផែនការកសាងទំនប់រួចរាល់ហើយ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលដែលរៀបចំរួចហើយ បានប្រជុំ ព្រោះខ្ញុំមកក្រោយគេដែរ។ ព្រោះខ្ញុំអាល័យតែទៅធ្វើការងារទៅ គេប្រជុំមុនៗ ខ្ញុំអត់បានប្រជុំ។ ប្រជុំបានតែអាលើកក្រោយនេះឯង។

[១៤:០៥:១៣]

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត លោកបាននិយាយថា កិច្ចប្រជុំដែលលោកបានចូលរួមហ្នឹង គឺចូលរួមដោយគណៈតំបន់ និងគណៈភូមិភាគផងដែរ។ ដូច្នេះខ្ញុំចង់ដឹងថា តើអ្នកដែលមកពីគណៈភូមិភាគហ្នឹងជាអ្នកណាគេដែរ ដែលចូលរួមក្នុងកិច្ចប្រជុំនោះ?

**ឆ៖** ខ្ញុំអត់ស្គាល់ទេ។ អត់ប៉ានមើលមុខគេផង ដល់គេថាភូមិភាគៗ ក៏ភូមិភាគគេទៅ គ្រាន់តែឮភូមិភាគខ្លាចហើយ មិនប៉ានមើលមុខគេច្បាស់។

**ស៖** តើលោកស្គាល់អ្នកណាខ្លះដែរ នៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** នៅក្នុងកិច្ចប្រជុំនោះ ខ្ញុំស្គាល់តែ តាវ៉ាល់ ហើយនិង តាហ៊ីង្ស ប៉ុណ្ណឹង ដែលគាត់ដឹកនាំខ្ញុំស្គាល់តែពីរនាក់ អ្នកធំៗ។ ធំក្រៅពីនោះទៀត ខ្ញុំអត់ស្គាល់។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍កន្លងមករបស់លោក គឺកំណត់ហេតុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោកបាននិយាយអំពីការដែលគេតែងតាំងលោកឲ្យទៅកសាងផ្លូវ គឺផ្លូវដែលធ្វើដំណើរទៅដល់ព្រំដែនថៃ ទៅដល់ថៃ។ ហើយក្រោយមកគេប្តូរផែនការ ហើយគេក៏បញ្ជាឲ្យលោកទៅសាងសង់ទំនប់ត្រពាំងថ្មវិញ? តើកិច្ចប្រជុំដែលលោកចូលរួមនៅស្វាយស៊ីសុផុនហ្នឹង គឺការប្រជុំហ្នឹងប្រជុំមុនពេលដែលគេឲ្យលោកទៅធ្វើផ្លូវទៅថៃនុ៎ង ឬមួយក៏ក្រោយពេលដែលគេឲ្យលោកទៅធ្វើផ្លូវនោះ?

[១៤:០៧:៣២]

**ឆ៖** ដែលប្រជុំៗនោះពេលក្រោយ ក្រោយដែលគេឲ្យខ្ញុំទៅធ្វើផ្លូវ។

**ស៖** នៅពេលដែលគេបញ្ជាឲ្យលោកទៅធ្វើផ្លូវនោះ ថាតើអ្នកណាជាអ្នកបញ្ជាលោក? ថាតើមកពីថ្នាក់តំបន់ ឬក៏ថ្នាក់មជ្ឈិម? ដូច្នេះខ្ញុំចង់ដឹងថា តើអ្នកណាជាអ្នកបញ្ជាឲ្យលោកទៅសាងសង់ផ្លូវនោះ?

**ឆ៖** ឲ្យទៅរៀបចំផ្លូវនោះគឺ តាវ៉ាល់ គាត់អ្នកបញ្ជាខ្ញុំ ព្រោះគាត់ប្រធានខ្ញុំ អត់មាននរណា ពីណា គាត់ទទួលបញ្ជាពីណា ថ្នាក់លើថ្នាក់អីណា គឺខ្ញុំអត់ដឹង។ ខ្ញុំដឹងតែប្រធានគាត់បញ្ជាឲ្យធ្វើ ខ្ញុំធ្វើទៅតាមប្រធាន។

**ស៖** ខ្ញុំសូមអានឲ្យលោកស្តាប់នូវចម្លើយរបស់លោកគឺ E3/9094 ភាសាខ្មែរមានលេខ ERN 00734059 ដល់ 00734061, អង់គ្លេសមាន 00778662 ដល់63 និងបារាំងមានលេខ 01123625។ សូមដកស្រង់៖ “នៅពេលដែលគេហៅឲ្យលោកចូលរួម ខ្ញុំដឹងថា ដោយសារតែអង្គការលើចង់ឲ្យយើង

PURL: http://www.legal-tools.org/doc/431d2b/

រៀបចំផែនការ។ គេឲ្យយើងធ្វើផ្លូវទៅដល់ថៃ ហើយគេឲ្យយើងរៀបចំប្រព័ន្ធអគ្គិសនីដើម្បីឲ្យអាចបង្ហូរទឹកពីទីនេះទៅដល់ប្រទេសថៃ។" ហើយបន្តមកទំព័រក្រោយមកទៀត "សំណួរ៖ តើនរណាជាអង្គការលើ? ចម្លើយ៖ អង្គការលើត្រូវគេហៅថា បងគណៈមជ្ឈិមបក្ស។ មជ្ឈមបក្សគឺ -- តើមជ្ឈិមបក្សសំដៅលើអ្នកមកពីភ្នំពេញឬ? ឆ្លើយ៖ បាទ គឺអ្នកមកពីមជ្ឈិមបក្ស។ សំណួរ៖ គាត់និយាយថា បងមជ្ឈិមបក្សស្នើឲ្យយើងសង់ផ្លូវមែនទេ? ចម្លើយ៖ បាទ ពិតហើយ។" សូមបញ្ចប់ការដកស្រង់។ តើអ្វីដែលខ្ញុំអានហ្នឹងធ្វើឲ្យលោកនឹកឃើញចម្លើយ ដែលលោកបានប្រាប់ដែរឬទេ? ហើយគឺធ្វើឲ្យលោកនឹកឃើញថា គឺមជ្ឈិមបក្ស ជាអ្នកបញ្ជាឲ្យលោក ជាអ្នកមកសាងសង់ផ្លូវហ្នឹង តើលោកនឹកឃើញដែរឬទេ?

**ឆ៖** អត់ទេ ព្រោះអត់មានមជ្ឈិមបក្សមកបញ្ជាទេ គឺ តាវ៉ាល់ ហ្នឹងបញ្ជា។ ខ្ញុំដឹងតែប៉ុណ្ណោះ អត់មានទាក់ទងអីដល់គណៈមជ្ឈិមបក្សទេ។

**ស៖** ចុះនៅពេលដែលគេប្តូរផែនការ ហើយគេបញ្ជាឲ្យលោកទៅសាងសង់ត្រពាំងថ្មវិញ ដោយមិនសង់ផ្លូវ តើនៅពេលនុ៎ងគេមានប្រាប់ទេថា អ្នកណាជាអ្នកបញ្ជាឲ្យផ្លាស់ប្តូរផែនការហ្នឹង? ហើយតើអ្នកណាជាអ្នកបញ្ជាឲ្យសាងសង់ទំនប់ហ្នឹងវិញ?

[១៤:១១:៤១]

**ឆ៖** ត្រង់នេះអ្នកដែលបញ្ជាឲ្យសាងសង់ធ្វើជាអាងត្រពាំងថ្មវិញនេះ ខ្ញុំក៏មិនដឹងអ្នកណាពិតប្រាកដជាអ្នកបញ្ជាដែរ។ ក៏ប៉ុន្តែក្នុងនោះមាន តាវ៉ាល់ ដែលប្រធានខ្ញុំ គាត់បញ្ជាខ្ញុំឲ្យខ្ញុំមើល រៀបចំឲ្យបានត្រង់ ទទឹង បណ្តោយឲ្យបានត្រឹមត្រូវ ឲ្យបានស្អាតដូចសព្វដើម តែគាត់ទទួលបញ្ជាមកពីថ្នាក់ណាខាងលើៗទៀតនោះ ក៏ខ្ញុំមិនដឹង។ ប៉ុន្តែការស្មានរបស់ខ្ញុំ បើគ្មានបទបញ្ជាពីថ្នាក់លើ តាវ៉ាល់ ក៏គាត់មិនមានបទបញ្ជាដាក់លើកមកឲ្យខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងថាមានបញ្ជាពីលើ ឬក៏អត់ប៉ុណ្ណោះទេ។ ខ្ញុំដឹងតែទទួលទិសពី តាវ៉ាល់។

**ស៖** លោកសាក្សីគឺថា គឺលោកបានផ្តល់ចម្លើយលម្អិតជាងនៅក្នុងចម្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនៅទីនោះ លោកបានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅត្រង់ឯកសារ E3/9094 ខ្មែរមានលេខ00734065, អង់គ្លេសមានលេខ00728666, បារាំងមានលេខ 01123629។ "សំណួរ៖ ប៉ុន្តែផែនការបានផ្លាស់ប្តូរទៅសង់ទំនប់ពីរ ថាតើគេប្តូរផែនការពីមជ្ឈិមបក្ស ឬក៏ពី តាហ៊ីង្ស? ចម្លើយ៖ គឺមកពីថ្នាក់លើ ថ្នាក់លើជាអ្នកប្តូរផែនការ។ សំណួរ៖ ថាតើថ្នាក់លើហ្នឹងអ្នកណាដែរ? ចម្លើយ៖ គឺមជ្ឈិមបក្ស គណៈមជ្ឈិមជាអ្នកប្តូរផែនការ។ សំណួរ៖ តើលោកច្បាស់អត់? ប្រហែល

ជាតាហឿង ជាអ្នកផ្ទាស់ -- តាហ៊ីង្ស ជាអ្នកផ្ទាស់ប្តូរផែនការមែនទេ? មិនមែនទេ គឺមិនមែន តាហ៊ីង្ស ទេ គឺគណៈមជ្ឈិមបក្សជាអ្នកបញ្ជាមក តាហ៊ីង្ស។ សំណួរ៖ តើលោកបានឮផ្ទាល់ដែរឬទេ? ចម្លើយ៖ បាទ។” តើអ្វីដែលខ្ញុំអានឲ្យលោកស្តាប់ហ្នឹង តើវាធ្វើឲ្យលោកនឹកឃើញដែរឬទេ? តើលោកចាំដែរឬទេ ថាលោកធ្លាប់ឮផ្ទាល់ត្រចៀកថា តាហ៊ីង្ស ទទួលបានបញ្ជាពីគណៈមជ្ឈិមបក្សនោះ?

[១៤:១៤:១៨]

**ឆ៖** ខ្ញុំនឹកមិនឃើញទេ ព្រោះខ្ញុំបានទទួលបញ្ជាតែពី តាវ៉ាល់ ហើយពីគណៈមជ្ឈិមបក្សអី ខ្ញុំរកនឹកអត់ឃើញ ព្រោះវាដូចអត់មាន។ ប៉ុន្តែក្នុងការស្មាន អានេះក្នុងការស្មានរបស់ខ្ញុំទេ ថាពួក តាវ៉ាល់, តាហ៊ីង្ស បើគ្មានបញ្ជាពីថ្នាក់លើ គាត់មិនអាចមិនធ្វើកើត គាត់ក៏មិនហ៊ានសម្រេចទេ តែបែបជាមាន ប៉ុន្តែខ្ញុំ គឺខ្ញុំមិនដឹងថាបញ្ជាពីថ្នាក់ណាទេ។ អានេះការស្មានរបស់ខ្ញុំ។

**ស៖** តើលោកជួប តាហ៊ីង្ស ញឹកញាប់បែបណាដែរ? គឺតើលោកធ្លាប់ជួបគាត់ញឹកញាប់បែបណាដែរ? តើលោកធ្លាប់ប្រជុំជាមួយគាត់ញឹកញាប់ដែរឬទេ?

**ឆ៖** មិនដែលបានប្រជុំញឹកញាប់ទេជាមួយ តាហ៊ីង្ស នោះ។ ជួនកាលពីរខែបីខែ បានជួបគាត់ម្តង។ តែញឹកញាប់រាល់ថ្ងៃ មានតែ តាវ៉ាល់។

**ស៖** ដូច្នេះលោកជួប តាវ៉ាល់ ញឹកញាប់ ប៉ុន្តែចំពោះ តាហ៊ីង្ស គឺលោកជួបត្រឹមតែម្តងក្នុងមួយខែពីរខែ។ តើលោកជួប តាហ៊ីង្ស នៅកន្លែងណាដែរ? តើមន្ទីររបស់ តាហ៊ីង្ស ហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** មន្ទីរ តាហ៊ីង្ស នៅស្វាយ នៅកន្លែងមន្ទីរបក្សសព្វថ្ងៃនេះឯង ហៅថាសាលានយោបាយកន្លែងគាត់នៅនោះ។

**ស៖** តើមន្ទីររបស់គាត់ហ្នឹងមានលេខកូដដែរឬទេ? គេមានហៅលេខមន្ទីរដែរឬទេ?

**ឆ៖** មិនមានទេ។ សម័យនោះអត់មានលេខកូដ អត់មានអី មិនដែលឃើញមានបិទស្លាកអីផង។

[១៤:១៦:៥៥]

**ស៖** លោកសាក្សី តើការកសាងទំនប់ត្រពាំងថ្មចាប់ផ្តើមនៅពេលណា? ខ្ញុំមិនមែនចង់សួរពីពេលដែលលោកទៅវាស់វែងទេ ប៉ុន្តែខ្ញុំចង់សួរពេលដែលកម្មករចាប់ផ្តើមកសាង ចាប់ផ្តើមសាងសង់ទំនប់ត្រពាំងថ្មតែម្តង។ តើលោកដឹងទេថានៅពេលណា?

**ឆ៖** ខ្ញុំភ្លេចហើយ។ មិនដឹងថាខែប៉ុន្មានច្បាស់លាស់ ព្រោះកាលដែលចុះកម្លាំងប្រយុទ្ធនៅ

PURL: http://www.legal-tools.org/doc/431d2b/

ការដ្ឋានអាងត្រពាំងថ្មនេះគឺអត់ចាំថ្ងៃ អត់ចាំខែទេ។ គ្រាន់តែការចំណាំបាន ព្រោះខែដែលយើងច្រូតស្រូវរួច។ ព្រោះកាលដែលទៅធ្វើ ឃើញនៅមានគល់ជញ្ជ្រាំងស្រូវ។ មិនដឹងជាខែ១ ឬក៏ខែ២។

**ស៖** ទាក់ទងទៅនឹងថ្ងៃខែ តើលោកចង់និយាយអំពីខែមករា កុម្ភៈ ឆ្នាំ៧៧ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ក្នុងឆ្នាំ៧៧ ហ្នឹងឯង។

**ស៖** ទស្សនាវដ្ដីយុវជនយុវនារីបដិវត្ត ដែលខ្ញុំបានផ្ដល់ឲ្យលោកមុននេះបន្តិច គឺនៅក្នុងខែកក្កដា សីហា ៧៧ដែរ។ គឺនៅក្នុងទស្សនាវដ្ដីហ្នឹង គឺបានរៀបរាប់លម្អិតអំពីការកសាងទំនប់ត្រពាំងថ្ម។ ហើយមានឯកសារលេខ E3/771 ខ្មែរមានលេខ 00376312, បារាំងមានលេខ 00594053។ ខ្ញុំសូមអានភាសាខ្មែរឡើងវិញ 00376343។ ហើយនៅត្រង់ទំព័រនោះ គឺគេបានបញ្ជាក់ដូចតទៅនេះ៖ "បងប្អូនចាប់ផ្ដើមការដ្ឋាននេះនៅថ្ងៃ១៦ កុម្ភៈ ៧៧។" តើវាធ្វើឲ្យលោកនឹកឃើញដែរឬទេ អំពីកាលបរិច្ឆេទ? ថាតើកាលបរិច្ឆេទហ្នឹង គឺវាដូច ឬក៏ប្រហែលគ្នានឹងកាលបរិច្ឆេទដែលកម្មករចាប់ផ្ដើមកសាងទំនប់ត្រពាំងថ្មដែរឬទេ?

[១៤:២០:១២]

**ឆ៖** ខ្ញុំមិនដឹងថាខែកុម្ភៈហ្នឹងត្រូវនឹងខែប៉ុន្មាន។

**ស៖** លោកបានផ្ដល់សក្ខីកម្មថា មុនពេលដែលកម្មករមកដល់ គឺថាលោកធ្វើការវាស់វែងស្ទង់នៅការដ្ឋាននុ៎ង។ ដូច្នេះខ្ញុំចង់ដឹងថាតើលោកនៅការដ្ឋានត្រពាំងថ្មធ្វើការវាស់វែងស្ទង់ហ្នឹងប៉ុន្មានខែដែរ មុនដែលកម្មករមកដល់ការដ្ឋានសាងសង់ហ្នឹង?

**ឆ៖** មុនដែលកម្លាំងបានចុះនៅក្នុងការដ្ឋានហ្នឹង ខ្ញុំរៀបចំជាងកន្លះខែ។

**ស៖** តើលោកបន្តធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹងប្រហែលជាប៉ុន្មានខែមកទៀត ក្រោយពេលដែលកម្មករគេមកដល់ការដ្ឋានហ្នឹង?

**ឆ៖** ក្រោយពេលកម្មករមកដល់ការដ្ឋានហ្នឹង ខ្ញុំបាននៅធ្វើការជាមួយកម្មករនេះចំនួនប្រហែលជា២ខែ មិនពេញទេ ប្រហែលជាជិត២ខែ ហើយក៏គេដកខ្ញុំឲ្យទៅរកត្រី ដើម្បីដោះស្រាយកម្មករហ្នឹង។

**ស៖** តើមានកម្មករសរុបប៉ុន្មាននាក់ដែរ ដែលត្រូវបានគេបញ្ជូនឲ្យទៅកសាងទំនប់ត្រពាំងថ្មហ្នឹង លោកចាំទេ?

**ឆ៖** ការលើកទំនប់ត្រពាំងថ្មកម្មករ៦.៥០០នាក់។ ហើយក្នុងនោះ ក្រោយមកមានខាងស្រុកជួយកសាងទំនប់នោះដែរ ខាងគេហៅថាចល័តស្រុកៗ ទាំងអស់វាមានបួនស្រុកដែលចុះមកជួយ។

PURL: http://www.legal-tools.org/doc/431d2b/

ស្រុកភ្នំស្រុក ស្រុកព្រះនេត្រព្រះ ស្រុកសិរីសោភ័ណ ស្រុកថ្មពួក បានចុះមកជួយ តែកម្លាំងគេប៉ុន្មាន ខ្ញុំអត់បានដឹង ព្រោះខ្ញុំដឹងតែកម្លាំងចល័តតំបន់ប៉ុណ្ណោះ។

[១៤:២៣:២៤]

**ស៖** ដូច្នេះកម្មករ៦.៥០០នាក់ហ្នឹង គឺលោកសំដៅទៅលើកម្មករមកពីកងចល័តរបស់តំបន់មែនទេ?

**ឆ៖** បាទ ៦.០០០នាក់នេះ គឺជាកម្មករ ជាចល័តរបស់តំបន់ ជាចល័តតំបន់។

**ស៖** បានន័យថា កម្មករៗមកពីកងចល័តតំបន់មកដល់មុន ហើយបន្ទាប់មកទៀតបានមានកម្លាំងបន្ថែមមកជួយទៀត តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងឯង កម្មករចល័តមកដល់មុន លើកបានជិតមួយខែហើយបានកម្លាំងស្រុកនោះមកជួយ។

**ស៖** នៅក្នុងពេល២ខែ ដែលលោកនៅទីនោះ គឺនៅពេលដែលកម្មករកំពុងសង់ទំនប់ហ្នឹង តើគេមានបែងចែកតំបន់ ឬក៏បែងចែកផ្នែកណាមួយនៃទំនប់ដែលឲ្យលោកទទួលខុសត្រូវ ឬមួយក៏គេឲ្យលោកមើលជារួមទៅលើការដ្ឋានត្រពាំងថ្មតែម្តង?

**ឆ៖** ក្នុងការដ្ឋានត្រពាំងថ្មហ្នឹង គឺខ្ញុំតួនាទីត្រូវមើលជារួម។ រួម តែនៅក្នុងចល័តស្រុកនីមួយៗគេមានចែកបច្ចេកទេស គេមានបញ្ជាការគេដូចខ្ញុំដែរ គេមើលក្នុងស្រុកគេ។ គ្រប់ស្រុកហ្នឹងឯង គេមានបញ្ជាការសមរភូមិគេគ្រប់តែគ្នា ប៉ុន្តែខ្ញុំមើលទាំងអស់តែម្តង ក្នុងសមរភូមិហ្នឹង ខ្ញុំមើលទាំងអស់ គេៗមើលទៅតាមកម្លាំងស្រុក គេវាយកម្លាំងដល់ត្រឹមណា គេគ្រប់គ្រងត្រឹមនោះទៅ បើខ្ញុំគ្រប់គ្រងទូទៅទាំងអស់។

[១៤:២៦:១២]

**ស៖** តើ តាវ៉ាល់ ដែលជាប្រធានចល័តតំបន់ហ្នឹង តើ តាវ៉ាល់ គាត់មានសិទ្ធិអំណាចទៅលើកម្មករទាំងអស់នៅការដ្ឋានដែរឬទេ? គឺថាគាត់អាចមានសិទ្ធិគ្រប់គ្រងទៅលើទាំងកម្មករ ទាំងអ្នកមកពីកងចល័តតំបន់ និងអ្នកមកពីស្រុកដែរឬទេ?

**ឆ៖** បាទ ក្នុងនោះ តាវ៉ាល់ គាត់មានសិទ្ធិគ្រប់គ្រងបញ្ជាទាំងអស់ ទាំងចល័តស្រុក ទាំងចល័តតំបន់ ព្រោះខាងចល័តក៏ទទួលការណែនាំពីគាត់ ដូចថាប្រធានគេមួយទៅ ស្រុកមង្គលបុរី -- អ៎! ស្រុកសិរីសោភ័ណប្រធានមួយ ថ្មពួកប្រធានមួយទៅ គេទៅទទួលការណែនាំពី តាវ៉ាល់ ទាំងអស់។

PURL: http://www.legal-tools.org/doc/431d2b/

**សៈ** តើ តាវ៉ាល់ គាត់ជាអ្នកសម្រេចថាតើបែងចែកការងារអ្វីទៅឲ្យដល់ខាងស្រុក ទៅដល់ខាងតំបន់អីដែរឬទេ? ឬមួយក៏អ្នកផ្សេងទេជាអ្នកកំណត់បែងចែកការងារទៅឲ្យកម្មករនោះ?

**ឆៈ** តាវ៉ាល់ នេះឯងគាត់អ្នកបែងចែកការងារឲ្យតាមស្រុក មួយគន្លាក់ៗៗ។

**សៈ** ដូច្នេះខ្ញុំចង់សួរថា តើខាងតំបន់ ហើយនិងខាងស្រុកហ្នឹង ថាតើមានប្រហែលជាប៉ុន្មានភាគរយនៃអ្នកចល័តហ្នឹង កងចល័តហ្នឹងជាប្រជាជន១៧មេសា?

**ឆៈ** កងចល័តហ្នឹងសុទ្ធតែប្រជាជន១៧មេសាតើ! ព្រោះ១៧មេសាហ្នឹង ទោះបីជាមូលដ្ឋាននៅក្នុងភូមិនោះ គេហៅថាមូលដ្ឋានចាស់ក៏ជា៧មេសាដែរ -- ១៧មេសាដែរ។ ហើយដល់ប្រជាជនជម្លៀសទៅពីភ្នំពេញនេះ ក៏គេហៅថាប្រជាជនថ្មី ១៧មេសាដូចគ្នាដែរ។ គ្រាន់តែមួយមូលដ្ឋាន មួយដែលគេជម្លៀសពីភ្នំពេញនេះ គេហៅថា ប្រជាជនថ្មី។ ដល់នៅមូលដ្ឋានក្នុងភូមិនោះ គេហៅថា ប្រជាជនចាស់ ប៉ុន្តែការពិតទៅ វា១៧មេសាដូចគ្នាទាំងអស់។

[១៤:២៩:៣៧]

**សៈ** អ៊ីចឹងខ្ញុំក៏ព្យាយាមបំបែកឲ្យខុសគ្នាបន្តិច គឺមានប្រជាជនចាស់ ហើយនិងប្រជាជនថ្មី គឺប្រជាជនថ្មី អ្នកមកពីភ្នំពេញហ្នឹង និងជម្លៀសមកពីកន្លែងផ្សេងទៀត។ ដូច្នេះប្រហែលជាមានប៉ុន្មាននាក់ដែរ ប៉ុន្មានភាគរយដែលជាប្រជាជនមូលដ្ឋាន ឬក៏ប្រជាជនចាស់? ចំណែកប៉ុន្មានភាគរយដែរជាប្រជាជនថ្មី គឺអ្នកជម្លៀសមកពីភ្នំពេញ និងមកពីតំបន់ផ្សេងៗទៀតនោះ?

**ឆៈ** បើយើងសរុបនៅក្នុងកងចល័ត គឺប្រជាជនចាស់ ហើយនិងប្រជាជនថ្មីនោះប្រហែលគ្នាដែលទៅធ្វើការនៅក្នុងអង្គភាពចល័តតំបន់៥។ តែនៅក្នុងសហករណ៍ ឃុំគឺប្រជាជនចេញពីភ្នំពេញទៅគឺច្រើនជាងប្រជាជនដែលនៅក្នុងភូមិ មូលដ្ឋានចាស់ ច្រើនជាងទ្វេជាភាគមួយ និងភាគបី។

**សៈ** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចង់សួរលោកអំពីផែនការការងារ ឬក៏ការបែងចែកការងារនៅត្រពាំងថ្ម។ ថាតើផែនការការងារដែលគេបែងចែកទៅឲ្យកម្មករនីមួយៗនៅត្រពាំងថ្មហ្នឹង ថាតើគេឲ្យប្រជាជនហ្នឹងជីកដីប៉ុន្មានម៉ែត្រគូបដែរក្នុងមួយថ្ងៃ?

**ឆៈ** អាត្រង់ជីកដីតាមម៉ែត្រគូបនោះគឺខ្ញុំក៏ក្តាប់មិនបានពិតប្រាកដដែរ ព្រោះខ្ញុំអត់បានដឹកនាំកម្លាំង ម៉្លោះហើយក៏កម្លាំងខ្លះគេលើកព្រឹកផង ថ្ងៃផង។ កម្លាំងខ្លះ គេលើកតែមួយព្រឹក ថ្ងៃគេសម្រាករហូតទាល់ល្ងាច ស្អែកឡើងបានគេចាប់លើកទៀត។ ម៉្លោះហើយមិនដឹងថាគេដាក់ផែនការយ៉ាងណាពិតប្រាកដ គឺអានោះខ្ញុំអត់បានដឹងទេ ប៉ុនមិនអាចសន្និដ្ឋានប្រាប់បានទេ។

[១៤:៣២:៤៤]

**សះ** ខ្ញុំសូមអាចនូវចម្លើយដែលលោកផ្តល់ដល់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺ E3/9094 ខ្មែរមានលេខ 00734070 ដល់ 71, ភាសាអង់គ្លេសមានលេខ 00728670 និងបារាំងមានលេខ 011236 32 ដល់ 33។ គឺថាចម្លើយរបស់លោកដែលប្រាប់មជ្ឈមណ្ឌលឯកសារគឺដូចតទៅនេះ៖ “ការបញ្ជាគឺថាមនុស្សម្នាក់ត្រូវតែវាយសម្រុកបញ្ចប់៣ម៉ែត្រគូប។ ប្រសិនបើធ្វើហើយនៅពេលថ្ងៃ គឺអាចសម្រាកនៅពេលថ្ងៃ ប្រសិនបើធ្វើមិនចប់ទេ ត្រូវតែធ្វើការរហូតដល់ចប់។” ហើយបន្តពីរបីសំណួរចម្លើយមកក្រោមបន្តិច៖ “ប្រសិនបើកងកម្លាំងទាំងអស់នោះបញ្ចប់ការងារនៅម៉ោងដប់ គឺថាយើងអាចសម្រាកបាននៅពេលរសៀល។ ដូច្នេះយើងអាចសម្រាក ហើយមិននឿយហត់ពេកទេ។” ថាតើអ្វីដែលខ្ញុំជម្រាបប្រាប់លោកហ្នឹង ធ្វើឱ្យលោកនឹកឃើញអំពីការបែងចែកផែនការការងារ គឺ៣ម៉ែត្រគូបក្នុងមួយថ្ងៃ តើអ៊ីចឹងមែនទេ?

**ឆះ** បាទ ការបែងចែកការងារនោះ វាខ្លះគេដាក់ផែនការ៣ម៉ែត្រក្នុងកងវរៈគេមួយៗ តែកម្លាំងគេលើកបាន៣ម៉ែត្រនោះម៉ោងដប់មួយរួច គឺគេដេកទាល់ល្ងាចទៅ។ ទាល់តែព្រឹកឡើងបានគេចាប់ផ្តើមទៀត។ កម្លាំងខ្លះលើកបានតែ២ម៉ែត្រទៅ ល្ងាចឡើងថ្ងៃម៉ោងពីរកន្លះ ឬក៏ម៉ោងបីទ្រង់ត្រជាក់ គេទៅបង្ហើយ១ម៉ែត្រទៀត។ អានោះ គឺវារបៀបគេរៀបចំអ៊ីចុះដែរ ព្រោះអានេះមិនមែនខ្ញុំអ្នកបញ្ជាគេទេ តាមកម្លាំង ប្រធានៗគេ អង្គភាពគេ កម្លាំងគេ ដែលគេក្តាប់ផ្ទាល់ ពិភាក្សាគ្នាគេ គេត្រូវអ៊ីចឹង។

**សះ** លោកប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា កម្មករត្រូវធ្វើរហូតទាល់តែចប់ផែនការ។ ដូច្នេះ នៅពេលដែលគេធ្វើមិនចប់ តើគេត្រូវធ្វើដល់ពេលយប់ដែរឬទេ? ហើយប្រសិនបើគេត្រូវធ្វើការដល់យប់ ថាតើគេមានភ្លើងអគ្គិសនីបំភ្លឺអ្វីដែរឬទេ ចំពោះអ្នកដែលត្រូវធ្វើការដល់យប់នោះ?

**ឆះ** វា តែខ្ញុំនៅ មិនដែលឃើញមានអ្នកណាធ្វើការយប់ផង។ គេធ្វើរួចទាំងថ្ងៃៗហ្នឹងឯង។ មិនដែលបានពិបាកធ្វើយប់ទេ អត់មាន។ តែខ្លាចលោអង្គភាពអីណាផ្សេង គេធ្វើយប់ អាហ្នឹងខ្ញុំអត់ដឹងដែរ។ ព្រោះទិសដៅ--

**សះ** *(គ្មានការបកប្រែ)*

[១៤:៣៦:៣៩]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ!

សូមអញ្ជើញលោកមេធាវី កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានការជំទាស់ទេ គ្រាន់តែការសង្កេត។ បើតាមការយល់របស់ខ្ញុំ គឺតាមភាសាខ្មែរ មិនមានភាពខុសគ្នារវាងពាក្យ “ពេលល្ងាច” និង “ពេលយប់” នោះទេ។ ដូច្នេះខ្ញុំ គឺគេប្រាប់ថា គេគ្រាន់តែនិយាយអំពីពេលងងឹត ឬក៏មិនងងឹត ប៉ុន្តែចំពោះភាសាដទៃ ដូចជាភាសាអង់គ្លេសគឺថា ពេលល្ងាច និងពេលយប់ហ្នឹង គឺមានភាពខុសគ្នា។ ដូច្នេះ ខ្ញុំចង់ឲ្យមានការបញ្ជាក់ច្បាស់អំពីពេលវេលានេះ។

**លោក ឌេល លីសាក់៖**

ខ្ញុំគិតថា នេះជាការសង្កេតតែប៉ុណ្ណោះ។ ខ្ញុំមិនដឹងថាតើវាមានខុសគ្នាយ៉ាងម៉េចទេ រវាងពេលល្ងាច និងពេលយប់នោះ គឺគ្រាន់តែពេលថ្ងៃលិចទៅ អាហ្នឹងយើងដឹងថាងងឹតហើយ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកបានប្រាប់យើងនៅព្រឹកមិញនេះថា ផែនការការងារខុសៗគ្នា នៅកំបោរ ហើយនិងគោករំចេក គឺមានផែនការការងារខុសគ្នាពីត្រពាំងថ្ម។ ដូច្នេះចង់ដឹងថា តើការបែងចែកការងារហ្នឹងខុសគ្នាយ៉ាងម៉េចនៅទំនប់កំបោរ ហើយនិងទំនប់គោករំចេកនោះ?

**លោក 2-TCW-918៖**

**ឆ៖** នៅព្រឹកមិញ ខ្ញុំបានបញ្ជាក់ប្រាប់ម្ដងហើយ។ បានបញ្ជាក់ប្រាប់ថា ការងារវាខុសគ្នា។ មួយរែកឡើងខ្ពស់ មួយរែកឡើងទាប។ ការរែកដី គឺរែកដូចតែគ្នា ផែនការដូចតែគ្នា គ្រាន់តែខុសគ្នា មួយខ្ពស់ មួយទាប ហើយប្រឡាយក៏វាជ្រៅជាង។ ម្ល៉ោះហើយប្រឹងរែកខុសគ្នាអ៊ីចឹង។

[១៤:៣៩:១៣]

**ស៖** ខ្ញុំយល់អំពីសក្ខីកម្មរបស់លោក អំពីទិដ្ឋភាពខុសគ្នានៃការដ្ឋាន ប៉ុន្តែលោកប្រាប់ថា នៅត្រពាំងថ្ម គឺ៣ម៉ែត្រគូបមួយថ្ងៃ។ ដូច្នេះខ្ញុំចង់សួរលោកថា តើការបែងចែកការងារហ្នឹង ប៉ុន្មានម៉ែត្រគូបក្នុងមួយថ្ងៃដែរ នៅទំនប់កំបោរ ហើយនិងទំនប់គោករំចេកនោះ?

**ឆ៖** នៅទំនប់កំបោរ និងទំនប់គោករំចេក ហើយនិងអាងត្រពាំងថ្ម គឺទំនប់កំបោរមានផែនការ ៣ម៉ែត្រគូប ក្នុងមួយថ្ងៃនេះ គឺមិនមែនអង្គការដាក់ទិសទេ ទៅតាមក្រុមគេពិភាក្សាកូនចៅគេប្ដេជ្ញាថា រួចពីថ្ងៃគេឈប់។ ហើយអាងត្រពាំងថ្មគេយកលំនាំនោះដូចគ្នាដែរ ៣ម៉ែត្រគូបក្នុងមួយថ្ងៃ។ បើយើង

វែកពីម៉ោងប្រាំមួយព្រឹកទៅទាល់ម៉ោងដប់មួយរួច គឺចាប់ពីម៉ោងដប់មួយទៅទាល់ម៉ោងប្រាំមួយល្ងាច គឺយើងដេករហូតទាល់ម៉ោងប្រាំមួយភ្លឺ។ ព្រោះទិសដៅនេះមិនមែនអង្គការបង្ខំយើង ដាក់ទិសឲ្យយើងទេ គឺយើងពិភាក្សាយកពេលវេលាសម្រាកគ្នាយើងទេ។

**ស៖** លោកសាក្សី តើលោកចង់ប្រាប់តុលាការកងនីមួយៗមានសិទ្ធិសម្រេចផែនការការងារប៉ុន្មានម៉ែត្រគូបក្នុងមួយថ្ងៃ អ៊ីចឹងមែនទេ? ថាតើកងនីមួយៗអាចសម្រេចដោយខ្លួនឯងថា គេត្រូវធ្វើការប៉ុន្មានម៉ែត្រគូបក្នុងមួយថ្ងៃអ៊ីចឹងមែនទេ?

**ឆ៖** បាទ ព្រោះគេចង់យកពេលវេលាសម្រាកគ្នាគេក្នុងកងគេ ក្នុងក្រុមគេ ម្ល៉ោះហើយគេសម្រេចខ្លួនគេ។

**ស៖** ខ្ញុំយល់ថា កងនីមួយៗអាចសម្រេចថា តើត្រូវធ្វើយ៉ាងណាដើម្បីសម្រេចផែនការ ប៉ុន្តែខ្ញុំចង់ដឹងថា តើកងនីមួយៗហ្នឹងអាចសម្រេចបានទេថា ផែនការប្រចាំថ្ងៃហ្នឹង ថាតើពួកគេអាចកំណត់ផែនការប្រចាំថ្ងៃថា ត្រូវជីកប៉ុន្មានគូបៗដែរឬទេ?

[១៤:៤២:១៦]

**ឆ៖** ព្រោះគេធ្វើមកនេះគឺគេកំណត់បានរបស់គេ។ គេកំណត់មួយថ្ងៃ៣ម៉ែត្រគូបៗ គឺបានរបស់គេរាល់ថ្ងៃ គេបានសម្រាករាល់ថ្ងៃ។

**ស៖** ខ្ញុំសូមអានឲ្យលោកស្តាប់នូវចម្លើយរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ គឺឯកសារ E3/9094 ខ្មែរមានលេខ 00734071, អង់គ្លេសមានលេខ 00728670, បារាំងមានលេខ 01128632។ "សំណួរ៖ តើលោកជាអ្នកសម្រេចថា មនុស្សម្នាក់ត្រូវជីក៣ម៉ែត្រគូបមែនទេ ឬមួយក៏តាហ៊ីង្ស ឬមួយក៏មជ្ឈិមបក្សជាអ្នកសម្រេច? ឆ្លើយ៖ គឺមកពីលើ មកពីគណៈតំបន់។ មកពីតំបន់? ឆ្លើយ៖ បាទ ព្រោះថាតំបន់បានប្រាប់ថា ផែនការនោះគឺជាផែនការក្តៅគគុក។ ធ្វើម៉េចកម្លាំងម្នាក់ៗឲ្យបាន៣បីម៉ែត្រគូប។" ហើយចុះមកក្រោមពីរបីសំណួរទៀតមក៖ "សំណួរ៖ តើលោកចាំទេថា តាហ៊ីង្សនិយាយថាម៉េច? ឆ្លើយ៖ គាត់និយាយថា ឥឡូវហ្នឹងយើងត្រូវសម្រេចផែនការឲ្យរួចឆាប់ ព្រោះកុំឲ្យកម្លាំង-ក (ខ្ញុំគិតថាប្រហែលជាចង់មានន័យថា កម្លាំង-អាអីហើយ) គឺយើងត្រូវវែក្នុងម្នាក់៣ម៉ែត្រគូប។" តើវាធ្វើឲ្យលោកនឹកឃើញដែរឬទេ នូវអ្វីដែលខ្ញុំអាននេះ? គឺថាខាងតំបន់ ខាងគណៈតំបន់គឺជាអ្នកកំណត់៣ម៉ែត្រគូបក្នុងម្នាក់។

[១៤:៤៤:៤៩]

**ឆ៖** ខាងតំបន់គាត់មិនបានកំណត់៣ម៉ែត្រគូបទេ មានតែប្រធានវរសេនាធំគេទេ អ្នកកំណត់ ព្រោះគេចង់ឲ្យបានរួចមុនផែនការ។ ខាងតំបន់គ្រាន់តែថា គ្រាន់តែនិយាយថា ផែនការក្ដៅ ដើម្បីឲ្យបាន សម្រេចមុនចូលឆ្នាំ។ គាត់បាននិយាយតែប៉ុណ្ណោះ តែដល់យើងខាងក្រោម គឺយើងសម្រេចឲ្យបានរួច មុនផែនការ ព្រោះយើងរៀបចំគ្នាយើងតាមវរៈ តាមកង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារង។ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាក និង ឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៦ នាទី ដល់ម៉ោង ១៥:១០ នាទី)*

[១៥:១០:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** យើងនិយាយគ្នាអំពីផែនការការងារ ឥឡូវនោះ ខ្ញុំចង់ចូលត្រឡប់មកនិយាយអ្វីដែលលោកបានលើកឡើងកាលពីព្រឹកមិញនេះ។ លោកបាននិយាយថា ប្រសិនណាផែនការការងារបញ្ចប់ការលើកទំនប់ហ្នឹង គឺឲ្យខ្លីទេ ធ្វើឲ្យចប់សព្វគ្រប់ពី៣ទៅ៤ខែ។ លក្ខខណ្ឌការងារនៃជីវិតរស់នៅរបស់ពលករ

គឺថាពិបាកមែនទែន ដោយសារពួកគាត់ធ្វើការពិបាកណាស់ ដើម្បីបញ្ចប់ការដ្ឋានលើកទំនប់នោះ។ ហើយលោកក៏បានឆ្លើយជូនតុលាការថា មេបញ្ជាការចង់ឲ្យបញ្ចប់គម្រោងលើកទំនប់ហ្នឹង នៅក្នុងរង្វង់ពេលវេលា ដែលបានកំណត់អំពីផែនការនេះ ដើម្បីទទួលបាននូវការជាការលើកទឹកចិត្ត ឬក៏ការលើកជាការដំឡើងតួនាទី។ តើមេបញ្ជាការដែលទទួលខុសត្រូវនៅការដ្ឋាននុំង គឺថាអាចបញ្ចប់ផែនការហ្នឹងដូចដែលបានរៀបចំនោះដែរទេ? តើគេអាចបញ្ចប់ការលើកទំនប់នោះទាន់ពេលវេលាដូចផែនការនោះដែរទេ?

[១៥:១២:៣៣]

លោក 2-TCW-918៖

**ឆ៖** បាទ ផែនការទៅលើទំនប់កំបោរ បញ្ចប់នៅមុនចូលឆ្នាំ គឺផែនការនេះ គេលើកបញ្ចប់បាន ចប់ទំនប់កំបោរទៅ បានគេរៀបចំចូលឆ្នាំ ចាប់ផ្ដើមសម្ដោធលេងសិល្បៈ។

**ស៖** ខ្ញុំបានអានចម្លើយនេះ ឲ្យលោកស្ដាប់ព្រឹកមិញ គឺថាចម្លើយលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E9094 គឺជាអង់គ្លេស 00728655, បារាំង 01123619។ នេះគឺជាចម្លើយដែលលោកបានឆ្លើយ សូមដកស្រង់៖ “យើងសម្រេចថា នឹងបញ្ចប់ការលើកទំនប់នៅក្នុងរយៈពេលតែប៉ុន្មានខែ យើងត្រូវគ្រប់គ្រងកម្លាំងឲ្យបានត្រឹមត្រូវ ដើម្បីបញ្ចប់ការលើកទំនប់នេះ ដូចដែលមានរៀបចំផែនការ ប៉ុន្តែគឺថាមិនអាចបញ្ចប់វាបាន។” តើលោកចង់និយាយថាម៉េច ដែលលោកឆ្លើយថា មិនវាគឺថាវាមិនអាចបញ្ចប់ការលើកទំនប់នោះបាន ដូចផែនការនោះទេ? គឺថាលោកឆ្លើយថា មិនអាចមិនបញ្ចប់បានទេ ត្រូវតែបញ្ចប់ឲ្យបាន?

**ឆ៖** បាទ ក្នុងផែនការដែលបញ្ចប់ដែលខ្ញុំនិយាយនេះ គឺផែនការទំនប់កំបោរ គឺបញ្ចប់ឲ្យបានមុនចូលឆ្នាំជាស្ថាពរ។ តែផែនការទំនប់គោករំចែកដែលបណ្ដោយ១៨គីឡូនោះ ឲ្យបញ្ចប់បានដូចគ្នា គឺវាមិនបានទេ ទំនប់គោករំចែក ទល់ចារគោកទៀម ទានកាំនោះ គឺវាមិនបានរួចមុនចូលឆ្នាំទេ។ អានុំងគឺពន្យារពេលវែងតទៅទៀត ព្រោះថ្នាក់លើក៏មិនឲ្យប្ដេជ្ញាទំនប់នោះទេ តែណាប្ដេជ្ញាតែទំនប់កំបោរតើ។ និយាយព្រឹកមិញ និយាយពីរឿងទំនប់កំបោរដែលរួចជាស្ថាពរ ទំនប់គោករំចែកដែលមិនបានរួច។

**ស៖** សូមបញ្ជាក់ឲ្យបានច្បាស់ ការដ្ឋានទំនប់គោករំចែក គឺបានចាប់ផ្ដើមក្រោយពេលបញ្ចប់ទំនប់កំបោរ ការដ្ឋានទំនប់កំបោរអ៊ីចឹងមែនទេ? តើចប់ការលើកទំនប់កំបោរហ្នឹង ចប់នៅពេលណា? ហើយរយៈពេលប៉ុន្មានទើបចាប់ផ្ដើមលើកទំនប់គោករំចែក?

PURL: http://www.legal-tools.org/doc/431d2b/

[១៥:១៥:៥៣]

**ឆ៖** ទំនប់កំបោរបញ្ចប់នៅពេលមុនចូលឆ្នាំ។ ហើយចប់រួចហើយ បានចាប់ផ្តើមបញ្ចប់ទំនប់គោករំចេក ដល់ទៅខែ៨ ខែ៩បានចប់។

**ស៖** នៅពេលដែលយើងឈប់សម្រាកនោះ លោកបាននិយាយអំពីផែនការការងារ ហើយខ្ញុំក៏បានអានសម្រង់មួយឱ្យលោកស្តាប់ ដែលថាផែនការការងារ៣ម៉ែត្រគូបក្នុងម្នាក់គឺថាជាវិធានការក្តៅ។ ហើយលោកបានឆ្លើយថា លោកផ្តល់សក្ខីកម្មថា វិធានការក្តៅនេះគឺចាំបាច់ណាស់ ដើម្បីធានាថាការដ្ឋានទំនប់ត្រពាំងថ្មត្រូវតែបញ្ចប់ក្នុងពេលវេលាជាក់លាក់។ អ្នកណាជាអ្នកកំណត់ពេលវេលាផែនការហ្នឹង? អ្នកណាជាអ្នកដែលបានប្រាប់ទៅលោកថា ការដ្ឋានទំនប់ត្រពាំងថ្មត្រូវតែបញ្ចប់តាមផែនការនេះ?

**ឆ៖** អត់មានទេ។ អត់មាននិយាយពីបញ្ហាអាងត្រពាំងថ្មបញ្ចប់នៅក្នុងផែនការនេះ អត់មានទេ។ ដែលខ្ញុំនិយាយនេះ និយាយពីទំនប់កំបោរបញ្ចប់បានមុនផែនការ មុនចូលឆ្នាំ។ តែទំនប់អាងត្រពាំងថ្ម គឺអត់មានកំណត់ថ្ងៃឱ្យបញ្ចប់ទេ។

**ស៖** តើនេះជាសក្ខីកម្មរបស់លោកឬ ដែលថាលោក ឬក៏ តាវ៉ាល់ ត្រូវការចំណាយពេលវេលាទៅតាមដែលអាចធ្វើទៅបានក្នុងការលើកទំនប់ត្រពាំងថ្ម? តើមិនមានផែនការកំណត់ពេលវេលាជាក់លាក់ដើម្បីបញ្ចប់ការលើកទំនប់ត្រពាំងថ្មទេឬ?

**ឆ៖** បាទ ពេលនោះគឺថ្នាក់លើត្រឹមថ្នាក់តំបន់ ហើយនិង តាវ៉ាល់ ហើយ តាហឹង្ស ហើយនិង តាវ៉ាល់ នោះគឺគាត់អត់មានដាក់ផែនការបញ្ចប់នៅខែណា ឆ្នាំណា គឺអត់មានទេ ព្រោះការដ្ឋាននេះ អាងត្រពាំងថ្មនេះធំ មិនមែនតូច ធំ ម៉្លោះហើយពេលវេលាណារួច ក៏រួចទៅ។ អត់មានផែនការបញ្ចប់ថាឆ្នាំនេះ ឆ្នាំនោះ អត់មាន។

[១៥:១៨:០៨]

**ស៖** តើគម្រោងការការដ្ឋានទំនប់ត្រពាំងថ្ម មិនត្រូវបានចាត់ទុកថាជាសមរភូមិក្តៅទេឬ?

**ឆ៖** បាទ អាងត្រពាំងថ្មមិនមែនចាត់ទុកជាសមរភូមិក្តៅទេ។ សមរភូមិក្តៅចាត់ទុកតែទំនប់កំបោរមួយប៉ុណ្ណោះទេ ដែលជាសមរភូមិក្តៅដែលឱ្យសម្រេចឱ្យបានមុនផែនការ។

**ស៖** ឥឡូវនេះខ្ញុំសូមអានសម្រង់មួយឱ្យលោកស្តាប់។ សម្រង់ពីខែកក្កដា ១៩៧៧ នៃឯកសារយុវជនបដិវត្ត។ ប្រសិនជាលោកចង់មើលទំព័រនេះ គឺថាគឺឯកសារ E3/771, ERN ជាភាសាខ្មែរ

00376344, អង់គ្លេស 00509686, បារាំង 00594054។ នៅក្នុងឯកសារនេះ ក្រោយការពិភាក្សាជាលម្អិតរួចមកអំពីការលើកទំនប់ត្រពាំងថ្ម រវាងខែមេសា-ឧសភា ១៩៧៧ ឯកសារបក្សបានលើកឡើងថា សូមដកស្រង់៖ “នៅក្នុងអំឡុងពេលលើកអាងស្តុកទឹកត្រពាំងថ្មនេះ សមាជិកសហករណ៍របស់យើងទាំងប្រុសទាំងស្រីនៃតំបន់នៅបាត់ដំបងគឺថា ពង្រឹងសីលធម៌ និងកម្លាំង ហើយនិងបានលះបង់អ្វីៗគ្រប់យ៉ាងដើម្បីសម្រេចផែនការបក្សឲ្យបានទាំងស្រុង និងឲ្យបានជោគជ័យទាំងស្រុង។ ពលកម្មធ្វើការនិងស្នាក់នៅកន្លែងធ្វើការយ៉ាងច្រើន ដូចយុទ្ធជនយុទ្ធនារីនៃកងទ័ពបដិវត្តន៍របស់យើងដូច្នេះដែរ នៅក្នុងពេលដែលពួកគេប្រយុទ្ធកម្ទេចខ្មាំងក្នុងអំឡុងពេលសង្គ្រាម។ គឺថាគេបានជីករែកដីទាំងយប់ទាំងថ្ងៃក្រោមកំដៅថ្ងៃដ៏ក្តៅដោយ មិនមានការត្អូញត្អែរអ្វីឡើយ។” ហើយសេចក្តីសន្និដ្ឋាននៃឯកសារនេះពីរបីកថាខណ្ឌខាងក្រោម សូមដកស្រង់៖ “សរុបមក ដើម្បីចូលរួម និងសម្រេចផែនការឆ្នាំ១៩៧៧ ឬក៏ថាឲ្យលឿងជាងនេះទៅទៀត និងដើម្បីឲ្យមាតុភូមិកម្ពុជារបស់យើងរីកចម្រើននៅក្នុងផែនការមហាលោតផ្លោះ មហាអស្ចារ្យនេះ គឺថាពលកម្មទាំងប្រុសទាំងស្រីនៅបាត់ដំបងគឺក្លាហាននិងលះបង់អ្វីៗគ្រប់បែបយ៉ាង។” លោកសាក្សី តើនេះវាជួយរំឭកដល់ការចងចាំរបស់លោកទេ? តើនេះមិនមែនជាផែនការ ១៩៧៧ ឬទេ ដែលបានបញ្ជាក់ថាការលើកទំនប់ត្រពាំងថ្មនេះ គឺត្រូវតែបញ្ចប់ទៅតាមផែនការ?

[១៥:២២:៥៩]

**ផ៖** អត់ទេ ខ្ញុំអត់ដែលឮ ហើយមិនដែលដឹងទៀត មិនបាន មិនដែលបានទទួលផែនការទេ។ អត់មានផែនការដាក់មកដូចឯកសារដែលអានឲ្យខ្ញុំស្តាប់នេះទេ។ ហើយខ្ញុំមិនដែលឮ។

**ស៖** គឺថាមើលទៅហាក់ដូចជាលោកបានដឹងអំពីផែនការហ្នឹង តាមកិច្ចសម្ភាសន៍ជាមួយ គឺឯកសារ E3/9094 ដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ERN ជាភាសាខ្មែរ 00734066, អង់គ្លេស 00728667, បារាំង01123629។ គឺថាគេបានសួរលោកអំពីការដ្ឋានទំនប់ត្រពាំងថ្ម។ “សួរ៖ តើផែនការលើកទំនប់ត្រពាំងថ្មនេះចេញមកពីមជ្ឈិមបក្សឬ? លោកឆ្លើយថា៖ បាទ។” លោកសាក្សីលោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា គឺថាមានផែនការអំពីការអភិវឌ្ឍ និងការបញ្ចប់មិនមែនមានន័យថាមិនមានផែនការទេ គឺមានផែនការ ដែលត្រូវបានរៀបចំឡើងសម្រាប់ការលើកទំនប់ត្រពាំងថ្ម រួមទាំងពីទំហំនៃទំនប់ ចំនួនពលករ គឺថាបញ្ជាក់ចំណុចលម្អិតបែបនេះឯង។ តើនេះមិនមែនជាការបញ្ជាក់ចំណុចលម្អិតនៃផែនការនេះទេឬ?

[១៥:២៤:៥០]

**ឆ៖** ផែនការដែលខ្ញុំបានស្តាប់នេះ គឺខ្ញុំមិនដែលបានជួប ព្រោះខ្ញុំបានទទួលការណែនាំពី តាវ៉ាល់ មិនដែលឮគាត់និយាយមានផែនការសម្រេចអ៊ីចេះអ៊ីចុះ ស្អីពីមជ្ឈិមបក្សអី គឺខ្ញុំមិនដែលបានជួបទេ ទើបមកឮនេះឯង។ ខ្ញុំគ្រាន់ថា ការងារទាំងអស់ មិនអាចសម្រេចត្រឹម តាហ៊ីង្ស, តាវ៉ាល់ ទេបើមិនមានពីថ្នាក់លើ ខ្ញុំគ្រាន់តែនិយាយអ៊ីចេះ។ បើមិនមានថ្នាក់លើ អ្នកខាងក្រោមមិនអាចធ្វើបានទេ។ ខ្ញុំគ្រាន់តែនិយាយអ៊ីចេះទេ តែឲ្យផែនការពីមជ្ឈិម គឺខ្ញុំមិនដែលបានឮ មិនដែលបានទទួល។ គ្រាន់តែការស្មានទេ អានេះហ្នឹង គ្រាន់តែការស្មាន។ ថាបើមិនមានពីលើ អ្នកក្រោមមិនដែលធ្វើទេ។ នេះគ្រាន់តែការស្មានរបស់ខ្ញុំ។ តែបានឮពិត ថាពីមជ្ឈិម ពីអី អត់ដែលឮទេ។

**ស៖** លោកសាក្សី អ្នកណាជាអ្នកសម្រេចថា ការដ្ឋានទំនប់ត្រពាំងថ្មត្រូវលើកឲ្យហើយក្នុងរយៈពេលប៉ុន្មាន? ហើយថាតើបណ្តោយ ទទឹង មានត្រូវមានប្រវែងប៉ុន្មាន អ្នកណាជាអ្នកធ្វើសេចក្តីសម្រេច ដាក់ចេញនូវសេចក្តីសម្រេចនេះ?

**ឆ៖** ដែលណែនាំឲ្យខ្ញុំធ្វើនេះគឺ តាហ៊ីង្ស គាត់បញ្ជាមក តាវ៉ាល់, តាវ៉ាល់ បញ្ជាឲ្យខ្ញុំធ្វើប៉ុណ្ណោះឯង ខ្ញុំធ្វើតាមបទបញ្ជានេះឯង។ តែ តាហ៊ីង្ស គាត់ទទួលបទបញ្ជាពីណាពីណីទៀត ខ្ញុំអត់ដឹង។

**ស៖** ការណែនាំ ដែលលោកបានទទួលមកនោះ តើទទួលដោយផ្ទាល់មាត់ ឬក៏គឺជាការណែនាំលាយលក្ខណ៍អក្សរ?

**ឆ៖** បាទ ក្នុងការទទួលនេះ គឺទទួលការណែនាំផ្ទាល់មាត់ អត់មានលាយលក្ខណ៍ជាអក្សរអីទេ។ ហៅខ្ញុំ គ្នាខ្ញុំប្រាំមួយនាក់ ទៅជួបគាត់នឹងផ្ទះ ហើយគាត់ក៏បាននិយាយប្រាប់ខ្ញុំ ពីរឿងការរៀបចំអាងត្រពាំងថ្មនេះ។ អត់មានបានប្រជុំទៅថ្នាក់លើ ទៅតំបន់ ទៅអីឯណា អត់ទេ។

[១៥:២៨:០០]

**ស៖** នេះជាចម្លើយរបស់លោក ដែលថាលោកមិនធ្លាប់ដែលបានទទួលឯកសារ ឬក៏ការបញ្ជាជាលាយលក្ខណ៍អក្សរទាក់ទងទៅនឹងការដ្ឋាននោះទេ គឺថាមិនដែលមានឯកសារជាលាយលក្ខណ៍អក្សរដែលត្រូវបានគេបញ្ជូនមកលោកទេ។ តើអ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ ពិតប្រាកដហើយ គឺមិនដែលមានជាអក្សរ លាយលក្ខណ៍ជាអក្សរអីបញ្ជូនមកឲ្យខ្ញុំទេ។ ការងារអី គាត់ប្រាប់តែនឹងមាត់ផ្ទាល់ៗ។

**ស៖** សំណួរមួយនៅក្នុងសវនាការនេះ គឺបានសួរថា តើគេត្រួតពិនិត្យកងនីមួយៗ ក្រុមនីមួយៗដោយរបៀបយ៉ាងម៉េច ដើម្បីបញ្ជាក់ថាគេសម្រេចនូវផែនការការងាររបស់គេ? តើគេមានការតាមដាន

ដើម្បីពិនិត្យឱ្យដឹងថា បញ្ចប់ផែនការការងារក្នុងមួយថ្ងៃ ក្នុងមួយនាក់ដោយរបៀបណាហ្នឹង គេធ្វើរបៀបម៉េចដែរ លោក?

**ឆ៖** ក្នុងការងារបញ្ចប់ក្នុងមួយថ្ងៃបានប៉ុណ្ណោះ មួយថ្ងៃបានប៉ុណ្ណោះ អានោះគេហៅប្រធានវរៈទៅសួរ។ ប្រធានវរៈទទួលរបាយការណ៍ស្ថិតិដែលធ្វើខ្លួនឯងក្នុងមួយថ្ងៃបានប៉ុនណា គឺយកទៅឱ្យ តាវ៉ាល់ គាត់ត្រួតពិនិត្យ។ តែរឿងខ្ញុំ ខ្ញុំមិនបានដឹងទេ ព្រោះមិនមែនជាការងាររបស់ខ្ញុំ។

**ស៖** តើលោកបានដឹងទេ នៅក្នុងកងនីមួយៗនៅក្នុងការរាយការណ៍ជូន តាវ៉ាល់ នេះតើគេរាយការណ៍ថា ពលករម្នាក់ៗត្រូវកាប់រែកដីហ្នឹងឱ្យបានចំនួនប៉ុន្មានក្នុងមួយថ្ងៃ? លោកដឹងទេ គេរាយ-ការណ៍ផែនការនេះជូន តាវ៉ាល់ ដោយរបៀបណា?

[១៥:៣០:៤៧]

**ឆ៖** ខ្ញុំមិនដឹងថាគេរាយជូន -- រាយការណ៍ជូន តាវ៉ាល់ ដោយរបៀបណាទេ ក៏ប៉ុន្តែក្នុងល្ងាចឡើង គេតែងយកស្ថិតិដែលគេធ្វើការងារបានប៉ុនណា គេយកបញ្ជូនទៅឱ្យ តាវ៉ាល់ ពេលល្ងាច គឺគេឡើងទៅរាល់តែថ្ងៃអ៊ីចឹងឯង តែបច្ចេកទេសគេធ្វើយ៉ាងម៉េច ខ្ញុំអត់ដឹង។

**ស៖** តើមានអ្វីកើតឡើងទៅដល់ពលករដែលមិនអាចសម្រេចផែនការបាន ឬក៏ត្រូវបានចាត់ទុកថាជាមនុស្សខ្ជិល? តើគេធ្វើម៉េចដែរជាមួយនឹងមនុស្សប្រភេទនេះ?

**ឆ៖** ក្នុងក្រុមនីមួយៗ កាលណាវាមានកម្លាំងគេទន់ខ្សោយ ឬក៏កម្លាំងធ្វើការមិនគ្រប់ផែនការរបស់គេៗតែដកយកទៅចូលនៅមន្ទីរពេទ្យ ព្រោះថាសុខភាពមិនល្អ ឱ្យសម្រាកពេទ្យ។

**ស៖** ខ្ញុំមិននិយាយអំពីពលករដែលធ្លាក់ខ្លួនឈឺនោះទេ ខ្ញុំនិយាយពីពលករដែលពាក់ព័ន្ធទៅនឹងមូលហេតុផ្សេងៗនៅពេលដែលគេសម្រេចថាពលករនោះគឺជាមនុស្សខ្ជិលនោះ។ តើមានកងពិសេសដែលគេហៅថាកងករណីដែរទេ សម្រាប់ធ្វើគ្រប់គ្រងទៅលើពលករខ្ជិលអ៊ីចឹង?

**ឆ៖** បាទ អាហ្នឹងក្នុងកងរបស់គេនីមួយៗ គេតែងបញ្ជូន -- ថាកងករណី តែកងករណីនេះ គឺនៅក្នុងមន្ទីរពេទ្យនេះឯង។

**ស៖** ដូច្នេះលោកសាក្សី លោកឆ្លើយថា ពលករដែលត្រូវបានចាត់តាំងឱ្យទៅនៅក្នុងកងពិសេសឬកងករណី គឺថាត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យដើម្បីទទួលបាននូវការព្យាបាល។ លោកឆ្លើយថាអ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

បាទ ឆ្លើយ!

[១៥:៣៤:០១]

**លោក 2-TCW-918៖**

**ឆ៖** បាទ ព្រោះដែលគេហៅថាកងករណីនោះ គេបញ្ជូនទៅមន្ទីរពេទ្យឲ្យពេទ្យព្យាបាលមើល តើឈឺមែន ឬមិនមែន ឬខ្ជិល ឬយ៉ាងណា អានោះស្រេចនឹងបច្ចេកទេសពេទ្យ ខ្ញុំអត់ដឹងដែរ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ចុះពលករដែលមានកំហុស ឬក៏ពាក់ព័ន្ធទៅនឹងសកម្មភាពដែលគេចាត់ទុកថាជាសកម្មភាពមិនត្រឹមត្រូវ ដូចជាបញ្ហាសីលធម៌អីជាដើម។ តើមានអ្វីកើតឡើងទៅដល់ពលករជំពូកនេះ?

**ឆ៖** ពលករដែលប្រព្រឹត្តខុសអំពីច្បាប់ ហើយនិងវិន័យ គេហៅថា ខុសសីលធម៌ក្នុងសង្គម អានោះគេតែងតែដឹកនាំ លោកប្រធានគាត់ដឹកនាំទៅ ហៅទៅណែនាំ កសាង កុំឲ្យធ្វើរបៀបនោះទៅទៀត។ គាត់កសាងម្តង ជាពីរដង រហូតដល់បីដង។ បីដង កសាងមិនបានហើយ គាត់ក៏ផ្សំផ្គុំឲ្យបានជាគ្រួសារជាមួយគ្នាទៅ។ តែបើនារីខ្លះ ដែលមិនឯកភាពជាមួយការណែនាំ ក៏គាត់បញ្ជូនឲ្យទៅតាមសហករណ៍វិញ។ គាត់មិនមែនថា ខុសជើងយកជើង ខុសដៃយកដៃ គឺអត់មែនទេ ព្រោះខ្ញុំរស់នៅជាមួយគាត់ ខ្ញុំដឹងចិត្តគាត់ គាត់ណែនាំសាចុះសាឡើង ម្តងជាពីរដង។ ណែនាំមិនបាន គាត់បញ្ជូនទៅសហករណ៍វិញ ភូមិណា បញ្ជូនទៅភូមិនោះវិញ។

**ស៖** អម្បាញ់មិញនេះ ខ្ញុំគ្រាន់តែព្យាយាមសួរបញ្ជាក់ពីសហការីដើម្បីឲ្យច្បាស់។ នៅជាភាសាអង់គ្លេសមានការបកប្រែថា ប្រសិនណាអ្នកណាម្នាក់ត្រូវបានគេអប់រំកែប្រែមិនឡើងទេ គឺៗថាត្រូវឲ្យទៅរៀបការក្នុងចំណោមពួកខ្ជិលៗគ្នាគេហ្នឹង។ លោកឆ្លើយថាអីចឹង ឬក៏មិនមែនទេ ដែលថាបើថាអ្នកទាំងនោះ គឺថាអប់រំកែប្រែមិនឡើងទេ គេយកទៅផ្សំផ្គុំរៀបការក្នុងចំណោមអ្នកខ្ជិលដូចគ្នាហ្នឹង?

[១៥:៣៧:១៩]

**ឆ៖** មិនមែនទេ មិនមែនអ្នកខ្ជិលអ្នកអីទេ គឺចំពោះអ្នកដែលខុសសីលធម៌។ មិនថាអ្នកខ្ជិល មិនថាអ្នករអែងទេ ណែនាំសាចុះសាឡើង បើមិនបានទេ ក៏គេរៀបការឲ្យទៅ។

**ស៖** សូមសួរបញ្ជាក់ឲ្យបានយល់ឲ្យបានច្បាស់ ឧទាហរណ៍ថាប្តីប្រពន្ធដែលធ្លាប់លួចស្រឡាញ់គ្នាមុន វាខុសទៅនឹងវិន័យបក្ស ហើយលោកឆ្លើយថា អ្នកដែលអ្នកប្រព្រឹត្តខុសវិន័យបក្ស ខុសសីលធម៌

អ៊ីចឹង បើគឺថាអប់រំកែប្រែពីរបីដងហើយមិនតាម គឺថាគេត្រូវយកទាំងហ្នឹងទៅផ្សំផ្គុំរៀបការជាមួយគ្នា។ លោកកំពុងតែឆ្លើយថាអ៊ីចឹង ពេលនេះអ៊ីចឹងមែនទេ?

**ឆ៖** បាទ ណែនាំមិនបានហើយ ឲ្យវាបានគ្នាទៅ គេការឲ្យទៅ កុំឲ្យខុសសីលធម៌តទៅទៀត។

**ស៖** អ៊ីចុះគេបញ្ជូនទៅរៀបការឲ្យនៅឯណាទៅ?

**ឆ៖** រៀបការនៅក្នុងការដ្ឋានរៀងៗហ្នឹងឯង ដូចថា ការដ្ឋាននៅអាងត្រពាំងថ្ម ការដ្ឋានពីដើមនៅប៉ោយតាអុង ហើយគេរៀបការនៅកន្លែងការដ្ឋានហ្នឹងទៅ។

**ស៖** ខ្ញុំសូមលើកចម្លើយមួយ ដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតទៅលើប្រធានបទដែលយើងកំពុងតែនិយាយគ្នានេះ គឺឯកសារ E3/9567។ លោកបានឆ្លើយដូចតទៅ សូមដកស្រង់៖ “ប្រសិនណាពលករខ្ជិលនៅកន្លែងការងារ គឺថាយើងនឹងចាប់ខ្លួនពួកគេ បញ្ជូនគេទៅសហករណ៍វិញ។” បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំសួរថា ក្នុងស្ថានភាពបែបណាទើបគេចាប់ខ្លួនមនុស្សបញ្ជូនចេញពីទៅក្រៅការដ្ឋាន? ហើយអ្នកណាជាអ្នកមានសិទ្ធិអំណាចសម្រេចអំពីការចាប់ខ្លួននេះ?

**ឆ៖** ក្នុងនោះគេមិនមែនចាប់ខ្លួនទេ គេណែនាំមិនបានគេបញ្ជូនទៅសហករណ៍វិញ គេមិនមែនចាប់ទេ។ បញ្ជូនទៅនៅសហករណ៍ណា គេបញ្ជូនទៅសហករណ៍នោះទៅ។

[១៥:៤០:៥១]

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលក្នុងនោះនិយាយថា ការចាប់ខ្លួនសិស្ស និស្សិត បញ្ញវន្ត ហើយលោកខិតខំព្យាយាមជួយការពារពួកគេ។ តើលោកអាចជម្រាបជូនតុលាការបានទេ ថាមានអ្វីកើតឡើង? តើមានការចាប់ខ្លួននិស្សិត បញ្ញវន្តដែរឬទេ? ហើយបើមានអ៊ីចឹង តើសូមលោករៀបរាប់អំពីព្រឹត្តិការណ៍ដែលបានកើតឡើងនោះ?

**ឆ៖** ក្នុងពេលអំឡុងនោះមានពួកនិស្សិត បញ្ញវន្តមួយចំនួនដែលនៅក្នុងប្រឡូកក្នុងការដ្ឋានចល័តតំបន់ ហើយក៏មានផែនការមួយចំនួនដែលរៀបចំថា ចង់បើកទាមទារ ចង់បើកមហាវិទ្យាល័យនៅស្វាយស៊ីសុផុន។ នេះពួកនិស្សិត បញ្ញវន្ត គេទាមទារ។ ដូច្នោះហើយខាងលើក៏បានសម្រេចឲ្យពួកនិស្សិត បញ្ញវន្តនោះទៅប្រជុំដើម្បីបើកមហាវិទ្យាល័យ។ ហើយ តាវ៉ាល់ ក៏និង តាហ៊ឹង្ស ក៏គាត់ដឹងសភាពការណ៍យ៉ាងម៉េចដឹង ព្រោះខ្ញុំក៏មិនដឹងដែរ។ បានគាត់ប្រាប់ឲ្យខ្ញុំ តាវ៉ាល់ គាត់ប្រាប់ឲ្យខ្ញុំគឺថាកុំឲ្យនិស្សិត បញ្ញវន្ត នោះទៅប្រជុំ។ បើចង់បានសញ្ញាបត្រឲ្យខំលើកទំនប់ លើកប្រឡាយនេះទៅ ជីកទំនប់នោះ ជីកប្រឡាយលើកទំនប់នេះទៅ គឺអានេះគឺសញ្ញាឃើញតែម្ដង កុំពិបាករកសញ្ញាបត្រ រកសញ្ញា

ឃើញ ព្រោះតែគេហៅទៅហើយមិនដឹងថាគេយកទៅឯណាទេ អ៊ីចេះ។ បានជាគាត់ខ្សឹបប្រាប់ខ្ញុំ ឲ្យខ្ញុំកាក់បងប្អូនមួយចំនួនដែលនៅជាមួយខ្ញុំ។ ដល់ក្រោយមក បានឃើញឡានទៅ ឡានខាងពាយ័ព្យមិនដឹងជាឡានយ៉ាងម៉េចទេ ប៉ុន្តែគេថាពាយ័ព្យ។ ឡាននោះខ្ញុំចំណាំបាន គឺឡានទ្រុង ពីដើមឡានគេហៅឡានដឹកទំនិញ មានទ្រង់ ដំបូលខ្ពស់ដូចឡានដឹកជ្រូកអ៊ីចេះឯង។ គេទៅយកពួកនិស្សិត បញ្ញវន្តដើម្បីទៅបើកទាមទារបើកមហាវិទ្យាល័យ។ ហើយនៅកន្លែងអង្គភាពខ្ញុំអត់បានទៅទេ ព្រោះខ្ញុំបានធ្វើការពីល្ងាចប្រាប់ ហើយ តាវ៉ាល់ ក៏គាត់បានប្រាប់គ្រប់កង គ្រប់ក្រុម គឺមិនឲ្យទៅបើកមហាវិទ្យាល័យឯណាទេ គឺឲ្យនៅលើកទំនប់ប្រឡាយនេះហើយ ជាសញ្ញា យកអាសញ្ញាឃើញនេះហើយ កុំចង់បានសញ្ញាបត្រ។ តែត្រង់ឡានមកយកគឺមិនបានមនុស្សទៅទេ មានខ្លះឮថាចង់មានរត់ឡើងឡានបានខ្លះ តែមិនដឹងគេយកទៅខាងណា ខ្ញុំអត់ដឹង។

[១៥:៤៣:៤៣]

**ស៖** អ្នកណាជាអ្នកបញ្ជូនឡានហ្នឹងដើម្បីទៅដឹកយកនិស្សិត បញ្ញវន្តហ្នឹង?

**ឆ៖** មិនដឹងថាអ្នកណាទេ ខ្ញុំអត់ដឹងដែរ ប៉ុន្តែគ្រាន់តែគេថា ឡានមកពីភូមិភាគៗ។ ម្ល៉ោះហើយឃើញអ្នកដែលជិះនឹងឡាននោះ ឃើញយោធាភូមិភាគ ព្រោះស្លៀកពាក់ខោអាវភូមិភាគ។ តែមិនដឹងថានរណាៗ គឺខ្ញុំអត់ដឹង។

**ស៖** ខ្ញុំសូមអានសម្រង់មួយដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា អំពីព្រឹត្តិការណ៍នេះឯង គឺឯកសារ E3/9094 ERN ជាភាសាខ្មែរ 00734084, អង់គ្លេស 00728679 ដល់ 680, បារាំង 01123641។ សូមដកស្រង់៖ “អ្នកណាម្នាក់ដែលទាមទារឲ្យបើកសាលារៀនឡើងវិញ យើងតម្រូវគេឲ្យ -- យើងក៏ត្រូវរាយការណ៍ ហើយអ្នកទាំងនោះក៏គេយកទៅបាត់ទៅ។ ហើយលោករាយការណ៍ជូនទៅអ្នកណា? រាយការណ៍ជូនប្រធានតំបន់ នៅពេលលេខាតំបន់ឃើញរបាយការណ៍នោះ គេស្នើសុំឲ្យអ្នកទាំងនោះចូលរួមប្រជុំ។ គេយកឡានមកដឹកនិស្សិត បញ្ញវន្តទាំងនោះ អ្នកខ្លះបានទៅ អ្នកខ្លះអត់បានទៅទេ។ អ្នកដែលក្លាយជាមិត្តភក្តិល្អជាមួយខ្ញុំនោះ ខ្ញុំក៏ទាញគេទម្លាក់ពីលើឡានវិញ។ បើពួកគេទៅ ខ្ញុំដឹងច្បាស់ថា មុខជាស្លាប់ហើយ។ អ៊ីចឹងខ្ញុំតោងគេទម្លាក់មកឲ្យនៅលើកទំនប់វិញ។” បញ្ចប់ការដកស្រង់។ ហេតុអ្វីបានជាលោកជឿជាក់ និងយល់ថាបើឡើងជិះឡានទៅ ស្លាប់ហើយ? ហេតុម៉េចក៏លោកយល់ថាយ៉ាងដូច្នេះ?

[១៥:៤៧:០៥]

**ឆ៖** បាទ ការដែលយល់ដឹងនេះគឺខ្ញុំយល់ថា ពួកនិស្សិត បញ្ជូនទាមទារដូច្នេះ គឺខ្ញុំមិនទុកចិត្ត ព្រោះគេយកឡានមកដឹកដើម្បីទៅនេះ គឺខ្ញុំអត់ទុកចិត្តទេ ព្រោះថាគេមិនមែនទៅឲ្យយើងបើកសាលាវិទ្យាល័យ មហាវិទ្យាល័យអីទេ ព្រោះគេឲ្យយើងមកលើកទំនប់ប្រឡាយទេ។ ប៉ុនអានេះការទាមទារចង់បើកសាលា ចង់បើកអី អានោះគឺខ្ញុំមិនដឹងថា ចេញពីប្រភពណាដែរ មិនដឹងថាអ្នកណាជាអ្នកទាមទារដែរ។

**ស៖** លោកបានបញ្ជាក់នៅក្នុងចម្លើយដែលខ្ញុំទើបតែអាន គឺថាមានរបាយការណ៍បញ្ជូនទៅលេខាតំបន់ លេខាភូមិភាគអំពីបញ្ហាជន ដែលទាមទារឲ្យបើកសាលារៀន។ ដូច្នេះខ្ញុំចង់សួរថា អ្នកណាជាអ្នកបញ្ជូនរបាយការណ៍ហ្នឹង ទៅលេខាភូមិភាគ?

**ឆ៖** ខ្ញុំមិនដឹងទេ។ មិនដឹងជាអ្នកណាអ្នកបញ្ជូនរបាយការណ៍ ខ្ញុំអត់ដឹង។

**ស៖** តើលោកមានទទួលការបញ្ជា ឬក៏ការណែនាំណាមួយទាក់ទង ថាតើអំពើ ឬក៏ការប្រព្រឹត្តបែបណាដែលលោកត្រូវបញ្ជូនរបាយការណ៍ទៅថ្នាក់លើ? ឧទាហរណ៍ដូចជាថា ការដែលគេទាមទារបើកសាលាហ្នឹង ត្រូវបញ្ជូនទៅថ្នាក់លើ ឬក៏អត់។ ដូច្នេះអ្វីដែលខ្ញុំចង់សួរ គឺថាតើលោកមានទទួលបញ្ជាពីថ្នាក់លើថា ត្រូវរាយការណ៍សកម្មភាពមនុស្សបែបណាៗ ទៅថ្នាក់លើទេ?

**ឆ៖** អត់ទេ។ ខ្ញុំអត់មានតួនាទីអី មានសិទ្ធិអីរាយការណ៍ពីមនុស្សទេ ព្រោះតួនាទីរបស់ខ្ញុំមានដឹងតែទំនប់រៀច ទំនប់ត្រង់ ហើយវាស់ឆ្ងាយជិតអីប៉ុណ្ណោះទេ។ អារបាយការណ៍ រាយការណ៍ ខ្ញុំអត់ដែលដឹងទេ។

[១៥:៤៩:៣៥]

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរសំណួរមួយចំនួនទាក់ទងទៅនឹងរបបអាហារនៅត្រពាំងថ្ម។ ថាតើវាមានភាពខុសគ្នាដែរឬទេ រវាងការដ្ឋានត្រពាំងថ្ម ថារបបអាហារដែលគេផ្ដល់ទៅដល់កងចល័តតំបន់ហ្នឹង វាខុសគ្នាពីរបបអាហារដែលគេផ្ដល់ទៅឲ្យកងចល័តមកពីស្រុកដែរឬទេ ឬមួយក៏វាដូចគ្នា?

**ឆ៖** បាទ ក្នុងនោះរបបដែលត្រូវបើកឲ្យចល័ត ក្នុងចល័តតំបន់ គឺរបបអង្ករយកចេញពីតំបន់មក ដើម្បីដោះស្រាយកងចល័ត ឲ្យហូបបាយក្នុងមួយថ្ងៃបីដង ហើយរបបក្នុងម្នាក់បីកំប៉ុង។ ប៉ុន្តែក្នុងនោះ យើងមិនមានពេលហូបបីដងទេ យើងសរុបហូបតែពីរដង។ ប៉ុន្តែរបប គឺដឹងតែម្នាក់បីកំប៉ុង។ ក្នុងសហករណ៍ អានោះមិនដឹងជារបបគេប៉ុន្មានកំប៉ុងក្នុងម្នាក់ ខ្ញុំអត់ដឹងទេ ព្រោះអង្ករទាំងអស់នោះខាងសហករណ៍គេដោះស្រាយទៅតាមឃុំ-សង្កាត់ ស្រុករបស់គេ អង្ករគេផ្សេង ដោយឡែក។ ខាងចល័ត

តំបន់ អង្ករម្ហូបអាហារអីចេញពីតំបន់ផ្ទាល់។ ម្ល៉ោះហើយវាខុសគ្នា មិនដឹងថាគេហូបប៉ុន្មានកំប៉ុង គឺខ្ញុំអត់បានដឹង។ ប៉ុនខុសគ្នា ខ្ញុំដឹងថាខុសគ្នា។

**ស៖** លោកទើបតែនិយាយថា អត់មានពេលហូបបាយបីពេល ដូច្នេះខ្ញុំចង់ដឹងថា ហេតុអ្វីបានជាកម្មករអត់មានពេលហូបបាយបានបីពេលហ្នឹង?

**ឆ៖** ក្នុងការមិនមានហូបបាយបីពេលនេះ ព្រោះថាទី១ បញ្ហាទឹកដាំបាយ ទី២បញ្ហាអុសភ្លើងដែលយើងអត់មាន។ ម្ល៉ោះហើយសម្រេចគ្នាទាំងអស់គ្នាថា យើងហូបតែពីរដងក្នុងមួយថ្ងៃ បានជាសម្រេចដាំហូបពីរដងក្នុងមួយថ្ងៃ។

[១៥:៥២:៣០]

**ស៖** ខ្ញុំចង់អានន្ធូវចម្លើយនៅក្នុងកិច្ចសម្ភាសន៍គឺ E3/9483 នៅត្រង់សំណួរចម្លើយទី១គឺលោកបានឆ្លើយដូចតទៅនេះ៖ "កងចល័តនៅឃុំ សហករណ៍ និងស្រុក គឺមានជីវភាពពិបាកជាងខាងតំបន់។ ដូច្នេះពួកគេបានតែហូបបបរទេ ចំណែកប្រជាជនថ្នាក់ស្រុកគឺមានអាហារហូបគ្រប់គ្រាន់។ ឧទាហរណ៍ ខ្ញុំហូបបាយបីពេលក្នុងមួយថ្ងៃ ហើយគឺយើងហូបអង្ករគ្រប់ៗគ្នា។" ដូច្នេះខ្ញុំចង់ដឹងថាតើលោកធ្វើយ៉ាងណាដែលអាចដឹងថា កម្មករមកពីឃុំ ឬក៏ស្រុកគឺគេហូបតែបបរនោះ?

**ឆ៖** ការដែលដឹងថាគេហូបបបរនោះ ព្រោះខ្ញុំដើរទៅឃើញពេលដែលគេហូប ព្រោះគេចែករបបគ្នាឃើញថា មិនមែនបបររាវទឹកទេ បបរគឺថាប៉ិ របៀបបាយឈ្នោល បបរឈ្នោល របៀបបាយជ្រាយ។ វាមិនមែនបបរហុតគ្រូកៗនោះទេ។ នេះឃើញគេហូបអឺចុះឯងតាមសហករណ៍ ខ្ញុំដើរឃើញទៅឃើញពេលគេហូប។ ខ្ញុំក៏ទៅហូបកន្លែងខ្ញុំ គេក៏ហូបកន្លែងគេ គឺឃើញអឺចុះឯង។ តែមិនដឹងគេចែករបបគ្នាក្នុងមួយថ្ងៃប៉ុន្មានកំប៉ុង ហ្នឹងខ្ញុំអត់ដឹងដែរ។

**ស៖** លោកនិយាយថា ខាងស្រុកហ្នឹងទទួលរបបអាហារពីខាងសហករណ៍ ប៉ុន្តែថ្នាក់តំបន់ គឺមានរបបអាហារខ្លួនឯង។ ដូច្នេះខ្ញុំចង់ដឹងថា តើតំបន់ហ្នឹងទទួលបានរបបអង្ករពីណាមក? ថាតើតំបន់ហ្នឹងមានសហករណ៍ខ្លួនឯងដែលដាំដុះស្រូវខ្លួនឯង ឬមួយក៏គេយកអង្ករហ្នឹងមកពីសហករណ៍របស់ស្រុកទេ?

**ឆ៖** បាទ ត្រង់កន្លែងនោះ ខ្ញុំក៏មិនបានតាមដានទេ ខ្ញុំដឹងតែពីរឿងម្ហូប។ ព្រោះថាតំបន់បានអង្ករពីណាពីណីមក គឺខ្ញុំអត់ដឹងដែរ។ ខ្ញុំដឹងថារបបពួកខ្ញុំ ដឹងថាបីកំប៉ុងក្នុងមួយថ្ងៃ។

[១៥:៥៥:៣០]

PURL: http://www.legal-tools.org/doc/431d2b/

**ស៖** លោកសាក្សី តើវាត្រឹមត្រូវដែរឬទេ ដែលថាខាងតំបន់គឺដាំដុះស្រូវខ្លួនឯង ប៉ុន្តែខាងស្រុក ថាតើស្រុក ខាងស្រុក ហើយនិងខាងតំបន់ហ្នឹងទទួលបានអង្ករពីសហករណ៍ដូចគ្នា ឬមួយក៏ខុសគ្នា?

**ឆ៖** ខ្ញុំមិនដឹងថាទទួលបានអង្ករមកពីណា ព្រោះខាងតំបន់ ចល័តដែលត្រូវហូបបាយ ហូបបីកំប៉ុងគឺគេហៅថាចល័តតំបន់ធ្វើការខ្លាំង។ តែអារឿងអង្ករដែលថាបានពីណាពីណី គឺខ្ញុំមិនដឹង មិនដឹងជាអង្ករពីតំបន់ធ្លាក់ពីណាឲ្យមកតំបន់ គឺខ្ញុំមិនដឹង មិនដឹងថាឡើងពីសហករណ៍យកទៅជូនតំបន់ ក៏ខ្ញុំអត់ដឹង អ៊ីចេះ។

**ស៖** លោកនិយាយថា យើងធ្វើការធ្ងន់ធ្ងរ យើងធ្វើការខ្លាំងជាងគេ។ ដូច្នេះតើ "យើង" ហ្នឹងសំដៅលើអ្នកណាដែរ "យើង" ហ្នឹង?

**ឆ៖** ដែលយើងធ្វើការខ្លាំងជាងគេនេះ ដូចថាកម្លាំងចល័តតំបន់ធ្វើការខ្លាំងជាងសហករណ៍ ព្រោះចល័តតំបន់ទទួលផែនការក្នុងតំបន់សុទ្ធតែការងារធំៗ។ សហករណ៍ការងារក្នុងសហករណ៍ក្នុងស្រុក ការងារតូចៗ។ នេះខ្ញុំចង់បញ្ជាក់ប្រាប់អ៊ីចេះ។

**ស៖** នៅពេលកម្លាំងស្រុក ហើយនិងតំបន់ធ្វើការនៅទំនប់ត្រពាំងថ្ម គឺពួកគេធ្វើការលើផែនការការងារដូចគ្នា។ ថាតើការងារហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ការងាររែកដីដូចតែគ្នាហ្នឹង។ ប៉ុន្តែមិនដឹងជារែកដោយវិធីណាៗ យើងអត់ដឹង មិនដឹងជារែកជារួមក៏មិនដឹង គេរែកជាឯកជនម្នាក់ៗអីនោះ យើងអត់ដឹង។ បើក្នុងចល័តតំបន់ គឺដឹងថារែកឯកជនក្នុងម្នាក់៣ម៉ែត្រ ឯកជន។ ដល់ការងារនៅក្នុងស្រុកដែលគេទៅជួយ ជួនកាលគេរែកក្នុងកន្លែងទៅ ១០នាក់ ២០នាក់ ១០០នាក់ទៅមិនដឹង មិនដឹងគេរែកយ៉ាងម៉េច យើងអត់ដឹងផែនការរបស់គេ ព្រោះគេធ្វើទៅតាមដំណើររបស់គេ តាមកម្លាំងរបស់គេ។

[១៥:៥៨:៥៤]

**ស៖** លោកសាក្សី តើលោកដឹងទេអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការបែងចែកស្រូវទៅឲ្យតំបន់ ទៅឲ្យស្រុក ឬក៏ទៅឲ្យភូមិភាគ? លោកដឹងទេអ្នកណាជាអ្នកចែករបបស្រូវទៅតាមភូមិភាគ តំបន់ និងស្រុកនោះ?

**ឆ៖** ខ្ញុំមិនដឹងទេ។ ការចែកស្រូវ ខ្ញុំអត់ដឹងថាអ្នកណាអ្នកចែក ព្រោះខ្ញុំដឹងតែពីរឿងចល័ត។

**ស៖** នៅក្នុងឆ្នាំ៧៧ គឺថាមានមួយពេលហ្នឹងគឺមានការខ្វះខាតអាហារ ខ្វះខាតស្បៀងនៅក្នុងស្រុកភ្នំស្រុក ស្រុកព្រះនេត្រព្រះ ហើយនៅពេលនុ៎ង គឺគេកាត់បន្ថយរបបអាហារ។ តើលោកចាំទេថា

PURL: http://www.legal-tools.org/doc/431d2b/

ធ្លាប់មានហេតុការណ៍ដែលថាខ្វះខាតស្បៀង ហើយគេបន្ថយរបបអាហារទេ?

**ឆ៖** ខ្ញុំមិនដឹង។ អត់ដឹងថាគេខ្វះខាត អត់ដឹងថាគេបន្ថយ អត់ដឹង។

**ស៖** ខ្ញុំសូមអាននូវសម្រង់មួយ គឺមកពីឯកសារដែលនៅសេសសល់ គឺជារបាយការណ៍ប្រចាំសប្តាហ៍មកពីតំបន់៥ ចុះថ្ងៃទី២១ ឧសភា ១៩៧៧ គឺឯកសារ E3/178 ដែលមានលេខ ERN ភាសាខ្មែរ 00275597, ភាសាអង់គ្លេសមានលេខ 00342721, ភាសាបារាំងមានលេខ 00623318 ដល់ 19។ នៅក្នុងឯកសារហ្នឹង គឺជារបាយការណ៍មកពីតំបន់៥។ ខ្ញុំសូមដកស្រង់៖ “ចំពោះស្រុកភ្នំស្រុក គឺថាស្បៀងអាហារអស់តាំងពីពាក់កណ្តាលខែមេសា។ ឥឡូវនេះ គឺថាឡានដឹកអីវ៉ាន់របស់ភូមិភាគ គឺបានជួយដឹកស្រូវមកយ៉ាងសកម្ម។ ហើយការតាមស្ពាន គឺថាការផ្គត់ផ្គង់ស្រូវ គេដឹកមកពីថ្មពួក ប៉ុន្តែមិនអាចធានាថាឲ្យគ្រប់គ្រាន់ រហូតដល់ពេលដែលស្រុកភ្នំស្រុកហ្នឹងអាចប្រមូលផលស្រូវខ្លួនឯងនៅក្នុងខែកញ្ញា តុលា នោះឡើយ។ ដូច្នេះ គឺវាផ្អែកទៅលើរបបដែលអង្គការបានកំណត់។” ហើយរបាយការណ៍បានបន្តទៅទៀតអំពីការខ្វះស្បៀងនៅក្នុងស្រុកព្រះនេត្រព្រះ ហើយរបាយការណ៍បានបញ្ចប់ដូចតទៅនេះ៖ “ចំពោះរបបស្បៀងនៅសមរភូមិមុខដែលទទួលខុសត្រូវលើការវាយប្រយុទ្ធចំពោះស្រូវស្រាល គឺថាក្នុងពេលបច្ចុប្បន្នហ្នឹង គឺគេអាចទទួលបានតែត្រឹមតែពីរកំប៉ុងប៉ុណ្ណោះ ដោយសារតែរបបបី -- ព្រោះថាប្រសិនបើរបបបីកំប៉ុងនៅតែបន្ត គឺវាមិនអាចគ្រប់គ្រាន់នោះឡើយ។ ដូច្នេះប្រសិនបើយើងកំណត់តែពីរកំប៉ុងទេ គឺថាយើងអាចសល់មួយកំប៉ុង បញ្ជូនទៅឲ្យស្រុកដែលខ្វះខាត។”

ដូច្នេះខ្ញុំមានសំណួរមួយដើម្បីសួរលោកទៅចំណុចនេះ។ ទី១ គឺរបាយការណ៍មកពីតំបន់៥ ដែលនិយាយអំពីរបបបីកំប៉ុងក្នុងមួយថ្ងៃ គឺជារបបដែលអង្គការកំណត់ ហើយគេត្រូវបន្ថយរបបហ្នឹង ដោយសារតែខ្វះស្បៀងនៅស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះ។ លោកសាក្សី លោកចាំទេ ថាតើអង្គការហ្នឹងសំដៅលើអ្នកណាដែរ? ថាតើអ្នកណាជាអ្នកកំណត់របបអាហារបីកំប៉ុងក្នុងម្នាក់ក្នុងមួយថ្ងៃនោះ?

[១៦:០៣:៣៦]

**ឆ៖** អានេះក្នុងការបន្ថយរបប ទៅពីរកំប៉ុងក្នុងមួយថ្ងៃ ខ្ញុំអត់បានដឹងទេ ព្រោះនៅកន្លែងចល័តខ្ញុំ នៅតែរបបអង្ករនៅតែដដែល។ តែតាមសហករណ៍ តាមស្រុក តាមឃុំ គេបន្ថយ អានោះជាផែនការរបស់ខាងស្រុក ខាងឃុំ ព្រោះខ្ញុំអត់បានដឹង ព្រោះកន្លែងខ្ញុំអត់មានបន្ថយ។

**ស៖** ដូច្នេះខ្ញុំចង់សួរលោកថា ព្រោះនៅក្នុងរបាយការណ៍ហ្នឹង គេនិយាយថាអង្គការជាអ្នកណាកំណត់របបអាហារបីកំប៉ុង។ ដូច្នេះខ្ញុំចង់ដឹងថាតើកម្រិតណា ឬក៏ថ្នាក់ណាជាអ្នកកំណត់របបហ្នឹង? ថា

តើថ្នាក់តំបន់ ថ្នាក់ភូមិភាគ ឬមួយក៏អ្នកណាផ្សេងទេ? តើលោកដឹងអំពីចំណុចនេះទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ត្រង់ចំណុចហ្នឹង ខ្ញុំមិនដឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសហព្រះរាជអជ្ញារងអន្តរជាតិ។ បាទ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកថ្ងៃអង្គារ ទី០១ ខែធ្នូ ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីរូបនេះបន្តបញ្ចប់។ ហើយពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្ម ហើយសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកសាក្សី ដំណើរការសវនាការស្ដាប់សក្ខីកម្មសាក្សីរបស់លោកក្នុងឋានៈជាសាក្សី នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ អរគុណលោកមេធាវី ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី ពេលនេះលោកអាចសម្រាកបានហើយ ហើយអង្គជំនុំជម្រះអញ្ជើញលោកមកបន្តប្រឹក្សាសាក្សីរូបនេះនៅថ្ងៃស្អែកទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកសាក្សីដែលមានរហស្សនាម 2-TCW-918 ត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ និងសូមឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកវិញ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

បាទ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*